នៅចំពោះមុខអង្គបុរេជំនុំជម្រះ
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 26-Aug-2011, 13:23
CMS/CFO: Uch Arun

**ព័ត៌មានពិស្ដារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០៣/០៧-០៩-២០០៩-អវតក/កសចស |
| ដាក់ទៅ | : | អង្គបុរេជំនុំជម្រះ |
| ថ្ងៃដាក់ | : | ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត: សម្ងាត់/Confidential

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

# បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ជំទាស់នឹង “សេចក្ដីសម្រេចលើការដាក់ឡើងវិញនូវសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបី របស់សហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣”

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញាអន្តរជាតិ:
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គបុរេជំនុំជម្រះ:
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម CHUNG Chang-ho
ចៅក្រម ហួត វុទ្ធី

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:
លោក ពេជ អង្គ
Elisabeth SIMMONEAU FORT

**ចម្លងជូន:**

សហព្រះរាជអាជ្ញាជាតិ:
លោកស្រី ជា លាង

# មាតិកា


១. សេចក្តីផ្តើម ....................................................................................................4

២. ប្រវត្តិនីតិវិធី....................................................................................................5

៣. ច្បាប់ជាធរមាន ..................................................................................................13

៤. ទឡ្ហីករណ៍.......................................................................................................16

ក. បទដ្ឋានជាធរមានសំរាប់ការពិនិត្យឡើងវិញលើបណ្តឹងឧទ្ធរណ៍ត្រូវបានដោះស្រាយនៅក្នុងយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ.......................................................................16

ខ. ការបដិសេធលើសំណើសុំនានាដោយផ្អែកលើមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ដែលកំពុងរង់ចាំសវនាការឱ្យបំពេញឲ្យបានគ្រប់ទៅតាមលក្ខខណ្ឌនៃបទដ្ឋានសំរាប់ការពិនិត្យឡើងវិញលើបណ្តឹងឧទ្ធរណ៍ .......................................................................................17

i. ដីកាសំរេចបកស្រាយដោយមិនត្រឹមត្រូវលើច្បាប់ជាធរមាន .......................................17

ii. ដីកាសម្រេច គ្មានសំអាងហេតុ និងមានតម្លៃស្មើនឹងការបំពានឆន្ទានុសិទ្ធិតុលាការ..................20

គ. ការបដិសេធសំណើដោយផ្អែកលើមូលដ្ឋាននៃភាពមិនទាន់ពេលវេលាគឺជាការបំពេញទៅតាមលក្ខខណ្ឌតម្រូវនៃបទដ្ឋានស្តីពីការពិនិត្យឡើងវិញលើបណ្តឹងឧទ្ធរណ៍ .........21

i. ដីកាសំរេចបានផ្អែកយ៉ាងជាក់ស្តែងទៅលើសេចក្តីសន្និដ្ឋានខាងអង្គហេតុដែលមិនត្រឹមត្រូវ........21

ii. ដីកាសំរេចនេះគឺមិនត្រឹមត្រូវ ហើយទុកដូចជាការរំលោភលើឆន្ទានុសិទ្ធិរបស់តុលាការ ............23

iii. ដីកាសម្រេចគឺមិនសមហេតុសមផល ហើយទុកដូចជាការរំលោភលើឆន្ទានុសិទ្ធិរបស់តុលាការ .......................................................................................................................24

ឃ. ការបដិសេធសំណើសុំដោយសារមិនមានយុត្តាធិការចំពោះបុគ្គលស្របទៅនឹងបទដ្ឋានសម្រាប់ពិនិត្យលើបណ្តឹងឧទ្ធរណ៍..........................................................................26

i. ដីកាសម្រេចគឺមិនយុត្តិធម៌ និងមានភាពមិនសមហេតុផលផង និង ជាការរំលោភបំពានលើអំណាចឆន្ទានុសិទ្ធិរបស់តុលាការផង ..........................................................................27

ii. ដីកាសម្រេចទំនងជាផ្អែកលើការបកស្រាយមិនត្រឹមត្រូវទៅច្បាប់ដែលពាក់ព័ន្ធ .....................29

iii. ដីកាសម្រេចបានសម្អាងទៅលើសេចក្តីសន្និដ្ឋានដែលមិនត្រឹមត្រូវទាល់តែសោះទាក់ទងទៅនឹងតួនាទីតាមឋានានុក្រម និងឋានៈរបស់ជនសង្ស័យ និងភាពជាក់ស្តែង ឬភាពធ្ងន់ធ្ងរនៃអំពើព្រហ្មទណ្ឌរបស់ពួកគេ ដែលត្រូវបានចោទប្រកាន់នេះ ....................43

**៥. ដំណោះស្រាយដែលស្នើសុំ** ....................54

## ១. សេចក្តីផ្តើម

១. អនុលោមតាមវិធាន ៦៦.២, ៦៦.៣, ៧៤.២, ៧៥.៣ និង ២១ នៃវិធានផ្ទៃក្នុង ("វិធាន") សហព្រះរាជអាជ្ញាអន្តរជាតិសូមដាក់ជូនបណ្តឹងឧទ្ធរណ៍នេះ ជំទាស់នឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត("ស.ច.ស" ឬ "ក.ស.ច.ស")[1] ដែលមានចំណងជើងថា "សេចក្តីសម្រេចលើការដាក់ឡើងវិញនូវសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបី របស់សហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿងលេខ ០០៣" ("ដីកាសម្រេច")[2] ។

២. បណ្តឹងឧទ្ធរណ៍នេះ គឺអាចទទួលយកបាន។ បណ្តឹងឧទ្ធរណ៍នេះត្រូវបានចុះក្នុងកំណត់ហេតុដោយក្រឡាបញ្ជីរបស់ កសចស នៅថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០១១[3]។ បណ្តឹងឧទ្ធរណ៍នេះបានដាក់ជូននៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១១ ហេតុដូច្នេះ គឺជាការអនុវត្តតាមពេលវេលាកំណត់ដែលមានចែងក្នុងវិធាន ៧៥.១ និង ៧៥.៣។ សហព្រះរាជអាជ្ញាអន្តរជាតិ សន្និដ្ឋានថាខ្លួនមានសិទ្ធិដើម្បីដាក់បណ្តឹងឧទ្ធរណ៍នេះតែម្នាក់ឯង ដោយពុំចាំបាច់ទាល់តែទទួលបានការផ្ទេរអំណាច តាមវិធាន ១៣.៣ ឬ ធ្វើកំណត់ហេតុស្តីពីការខ្វែងយោបល់គ្នា តាមវិធាន ៧១.១ ទេ។ បច្ចុប្បន្ន បញ្ហានេះកំពុងស្ថិតនៅចំពោះមុខអង្គបុរេជំនុំជម្រះ ("អបជ") លើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចរបស់ កសចស ដែលកំពុងតវ៉ានេះ ("បណ្តឹងឧទ្ធរណ៍ទីមួយ")[4]។ បើមិនមានខូចប្រយោជន៍ដល់បណ្តឹងឧទ្ធរណ៍ទីមួយ និងដោយមានការប្រុងប្រយ័ត្នបំផុតនោះ ការខ្វែងយោបល់គ្នា

---

[1] ទោះបីជាដីកាសម្រេចនេះដាក់ចំណងជើងថា "សេចក្តីសម្រេច" ក៏ដោយ ក៏គេគ្មានមន្ទិលសង្ស័យទេថា វិធានផ្ទៃក្នុងប្រើពាក្យ "សេចក្តីសម្រេច" និង "ដីកាសម្រេច" ដែលបានប្រើដោយសហចៅក្រមស៊ើបអង្កេត គឺជាពាក្យដែលអាចប្រើជំនួសគ្នាទៅវិញទៅមកបាន: ដោយប្រៀបធៀបវិធាន៦៦(២) និង(៣) វិធាន៧៤(១) វិធាន៧៤(២) និង(៤) វិធាន៧៥ ។

[2] **D26** ដីកាសម្រេចស្តីពីការដាក់សារជាថ្មីនូវសំណើសុំបំពេញកិច្ចសួរចំនួនបី របស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងសំណុំរឿង ០០៣, ២៧ កក្កដា ២០១១, ERN 00721129-32 ។

[3] **D26/1** សៀវភៅចុះបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្តឹងឧទ្ធរណ៍នឹង "ដីកាសម្រេចស្តីពីការដាក់សារជាថ្មីនូវសំណើសុំបំពេញកិច្ចសួរចំនួនបី របស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងសំណុំរឿង ០០៣", ០៤ សីហា ២០១១, ERN 00722372-74 ។

[4] **D20/4/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់នឹង "ដីកាសម្រេចស្តីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹងសំណុំរឿង ០០៣", ០៧ កក្កដា ២០១១, ERN 00712851-75 ។

មួយទាក់ទងនឹងការដាក់បណ្តឹងឧទ្ធរណ៍នេះ ត្រូវបានធ្វើកំណត់ហេតុជាផ្លូវការណ៍តាមការផ្តួចផ្តើមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងឯកសារដែលមានចុះហត្ថលេខា និងកាលបរិច្ឆេទ ដែលបានដាក់ក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នា រក្សាទុកដោយក្រឡាបញ្ជីរបស់សហព្រះរាជអាជ្ញា ។

៣. បណ្តឹងឧទ្ធរណ៍នេះកំណត់អំពីប្រវត្តិនីតិវិធីដែលពាក់ព័ន្ធនានា (វាក្យខ័ណ្ឌ II) ច្បាប់ជាធរមាន (វាក្យខ័ណ្ឌ III) និងអំណះអំណាងជាសារធាតុ (វាក្យខ័ណ្ឌ IV) ។ សហព្រះរាជអាជ្ញាអន្តរជាតិស្នើឲ្យ អបជ ទុកដីកាសម្រេចដែលបដិសេធលើសំណើសុំបំពេញកិច្ចស៊ើបសួរទាំងបីមួយអន្លើសិន ហើយបង្គាប់ឲ្យ សចស ដោះស្រាយលើអង្គសេចក្តី ។ ដីកាសម្រេចនេះគួរទុកមួយអន្លើសិនដោយសារ ដីកាសម្រេចនេះ បកស្រាយមិនត្រឹមត្រូវចំពោះច្បាប់ជាធរមាន អំពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដោយពឹងផ្អែកលើសេចក្តីសន្និដ្ឋានផ្អែកអង្គហេតុដែលខុសឆ្គងយ៉ាងជាក់ស្តែង ទាក់ទននឹងមុខតំណែងក្នុងឋានានុក្រម និងភាពធ្ងន់ធ្ងរនៃអំពើព្រហ្មទណ្ឌដែលបានចោទប្រកាន់របស់ ស៊ូ ម៉េត និងមាស មុត ហើយមានតម្លៃស្មើនឹងការបំពានឆន្ទានុសិទ្ធិតុលាការ ចំពោះមូលដ្ឋានដែលខ្លួនយកធ្វើជាសំអាងសម្រាប់ការបដិសេធលើសំណើសុំនានា ទាំងនៅលើទឡ្ហីករណ៍ដែលមិនត្រឹមត្រូវយុត្តិធម៌ និងទាំងគ្មានសំអាងហេតុ។

## ២. ប្រវត្តិនីតិវិធី

៤. នៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១០ ដោយចាត់បំពេញកិច្ចលើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២[5] សហចៅក្រមស៊ើបអង្កេត (ចៅក្រម Marcel Lemonde) បានចេញដីកាចាត់ឲ្យស៊ើបសួរជំនួសមួយដោយផ្តល់បេសកកម្មនេះទៅឲ្យអ្នកស៊ើបអង្កេតរបស់ កសចស ដើម្បីចុះស៊ើបសួរដល់ទីកន្លែង[6]។ អនុលោមតាមដីកាចាត់ឲ្យស៊ើបសួរជំនួសនេះ កំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន១៧

[5] **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីពីរ ពាក់ព័ន្ធកងទ័ពបដិវត្តន៍កម្ពុជា, ២០ វិច្ឆិកា ២០០៨, ERN 00292056-173 ។

[6] **D2** ដីកាចាត់ឲ្យស៊ើបសួរជំនួស, ០៩ មិថុនា ២០១០, ERN 00529726-28 ("ដីកាចាត់ឲ្យស៊ើបសួរជំនួស"); ឯកសារនេះត្រូវបានចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិតែម្នាក់ឯង បើតាមការសន្មត ទៅតាមការខ្វែងយោបល់គ្នាដែលគេបានធ្វើកំណត់ហេតុ រវាងសហចៅក្រមស៊ើបអង្កេត ។ សូមអានសេចក្តីថ្លែងការណ៍ពីសហចៅក្រមស៊ើបអង្កេត, ០៩ មិថុនា ២០១០, នៅលើគេហទំព័រ:

ត្រូវបានធ្វើឡើងដោយអ្នកស៊ើបអង្កេត កសចស នៅចន្លោះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១០ និងថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១០[7] ។ ប៉ុន្តែ កំណត់ហេតុស្តាប់ចម្លើយសាក្សីទាំង១៧ មិនត្រូវបានដាក់ទៅក្នុងសំណុំរឿងទេ ហើយការជូនដំណឹងមកសហព្រះរាជអាជ្ញាអន្តរជាតិក៏មិនបានធ្វើដែររហូតដល់ថ្ងៃទី ១០ ខែមីនា ឆ្នាំ២០១១ ។ ដីកាចាត់ឲ្យស៊ើបសួរជំនួសនេះ មិនត្រូវបានគេធ្វើចំណាច់ថ្នាក់ឡើងវិញពីសម្ងាត់បំផុតទេ ហើយការជូនដំណឹងមកសហព្រះរាជអាជ្ញាអន្តរជាតិក៏មិនបានធ្វើដែរ រហូតដល់ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១១ ។

៥. នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១០ ចៅក្រម Siegfried Blunk ក៏បានចូលជំនួស ចៅក្រម Marcel Lemonde ជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ[8] ។ នៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង និង Siegfried Blunk បានចេញសេចក្តីប្រកាសព័ត៌មានមួយដោយថ្លែងថា ពួកគាត់បានបង្កើតក្រុមការងាររួមដើម្បី "ផ្តោតទៅលើការពិនិត្យ និងវិភាគឯកសារនានាដែលមាននៅក្នុងសំណុំរឿង ជាពិសេសឯកសារដែលមានស្រាប់ក្នុងសំណុំរឿងមុនៗ គឺសំណុំរឿង

http://www.eccc.gov.kh/sites/default/files/media/PROCIJ(June2010.pdf.

ការកើតមានឡើងនូវការខ្វែងយោបល់គ្នាដូច្នេះត្រូវបានទទួលស្គាល់នៅក្នុងឯកសារ**D20/3** ដីកាសម្រេចស្តីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹងសំណុំរឿង ០០៣", ០៧ កក្កដា ២០១១, ERN 00702797-802 ត្រង់កថាខ័ណ្ឌទី៦(ii) ។

[7] កំណត់ហេតុស្តាប់ចម្លើយសាក្សី: **D2/2** អ៊ូ លាង (OU Leang), ១៣ កក្កដា ២០១០, ERN 00590271-77 **D2/3** ណុប ហាត (NOP Hat) ហៅ គី ហាត (KY Hat) ហៅ ណុប ហុន (NOP Hon), ២០ កក្កដា ២០១០, ERN 00590265-70 **D2/4** ប៉ូច កុយ (PAUCH Koy), ២៨ កក្កដា ២០១០, ERN 00597436–43 **D2/5** ហ៊ាន រុំ (HEAN Rum), ២៤ សីហា ២០១០, ERN 00623556–64, **D2/11** អ៊ុំ កែវ (OUM Keo), ២៨ កញ្ញា ២០១០, ERN 00616937–43, **D2/12** ម៉ៅ ផាត (MAO Phat), ២៩ កញ្ញា ២០០១, ERN 00615442–47, **D2/13** សាយ តាយ (SAY Tay), ២៥ កញ្ញា ២០១០, ERN 00616931–36, **D2/14** មៀង ប៊ូលិន (MEANG Buolin), ២៦ កញ្ញា ២០១០, ERN 00623859–69, **D2/4** ប៉ូច កុយ (PAUCH Koy), ២៨ កក្កដា ២០១០, ERN 00597436–43, **D2/6** ញូង ជ្រោង (NHOUNG Chrong), ២៤ សីហា ២០១០, ERN 00607253–62, **D2/7** ប៉ែន សារិន (PEN Sarin), ២៦ សីហា ២០១០, ERN 00607253–58, **D2/8 D2/9 D2/10** សាយ ប៊ន (SAY Born), ៦, ៧ និង ៩ កញ្ញា ២០១០, ERN 00613007–15, 00613016–26, 00615360–70, **D2/15 D2/16** ទូច សឿលី (TOUCH Soeuli), ១០ និង ១១ វិច្ឆិកា ២០១០, ERN 00628182-90, 00629460–65, **D2/17** អ៊ិន សារឿន (IN Saroeun), ១២ វិច្ឆិកា ២០១០, 00628142–48, ERN 00590265 និង **D2/18** ស្រេង ធី (Sreng Thi), ១ ធ្នូ ២០១០, ERN 00630429–36 ។

[8] បណ្ឌិត Siegfried Blunk ត្រូវបានតែងតាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មី, ១ ធ្នូ ២០១០, នៅលើគេហទំព័រ៖ http://www.eccc.gov.kh/sites/default/files/media/ECCC_1_Dec_2010_(Eng).pdf.

០០១ និង ០០២” ។ សេចក្តីប្រកាសព័ត៌មានរបស់ សចស ក៏បានបង្ហាញឲ្យដឹងផងដែរថា “នៅក្នុងដំណាក់កាលនេះ មិនមានកិច្ចស៊ើបសួរដល់ទីកន្លែងត្រូវបានធ្វើឡើងទេ”[9] ។

៦. សហព្រះរាជអាជ្ញា មិនបានទទួលការជូនដំណឹងអំពីកិច្ចស៊ើបសួរសំខាន់ៗត្រូវបានធ្វើឡើងដោយ សចស ក្នុងសំណុំរឿង ០០៣ ទេ រហូតដល់ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១ ។ នៅថ្ងៃនោះដែរ សចស បានដាក់ទៅក្នុងសំណុំរឿងនូវ របាយការណ៍ស្តីពីការបំពេញបញ្ជប់ដីកាចាត់ឲ្យស៊ើបសួរជំនួសមួយ និងការស្តាប់ចម្លើយសាក្សីដល់ទីកន្លែងចំនួន១៧ ដែលបានធ្វើឡើងនៅចន្លោះ ខែកក្កដា និង ខែធ្នូ ឆ្នាំ២០១០[10] ។

៧. នៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០១១, សចស បានដាក់ទៅក្នុងសំណុំរឿងនូវការជូនដំណឹងមួយ អំពីឯកសារដែលបានផ្ទេរពីសំណុំរឿង០០២ ទៅក្នុងសំណុំរឿង០០៣[11] ។ ដំណើរការនៃបញ្ជូនឯកសារទាំងនោះទៅក្នុងសំណុំរឿង០០៣ បានចាប់ផ្តើមនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ ហើយនៅបន្តរហូតដល់ថ្ងៃនេះ ។ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ នេះដែរ មានរបាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងចំនួនប្រាំ(០៥) ត្រូវបានដាក់ចូលក្នុងសំណុំរឿង ដោយរៀបរាប់អំពីកិច្ចខិតខំប្រឹងប្រែងនានាធ្វើឡើងដោយអ្នកស៊ើបអង្កេត កសចស ក្នុងឆ្នាំ២០១០ ដើម្បីពិនិត្យទីតាំងឧក្រិដ្ឋកម្មសម្រាប់សំណុំរឿង ០០៣ ។ របាយការណ៍ទាំងអស់នោះ ចុះកាលបរិច្ឆេទក្នុង ខែវិច្ឆិកា ឬ ខែធ្នូ ឆ្នាំ២០១០[12] ។ នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១១ សហព្រះរាជអាជ្ញា បានការសេចកក្តីជូនដំណឹងអំពី

[9] សេចក្តីថ្លែងការណ៍ពីសហចៅក្រមស៊ើបអង្កេត, ២ កុម្ភៈ ២០១១, នៅលើគេហទំព័រ: http://www.eccc.gov.kh/sites/default/files/media/ECCC_OCIJ_2_Feb_2011(Eng).pdf.

[10] **D2/1** របាយការណ៍ស្តីពីការបំពេញបញ្ជប់ដីកាចាត់ឲ្យស៊ើបសួរជំនួស, ១០ កុម្ភៈ ២០១១, ERN 00649195-96 ។

[11] ឯកសារលេខ **D4** កំណត់សំគាល់ស្តីពីការដាក់បញ្ចូលឯកសារនៅក្នុងសំណុំរឿងលេខ ០០៣, ចុះថ្ងៃទី៥ មេសា ២០១១, ERN 00658994-95។ សេចក្តីជូនដំណឹងបន្ថែមមួយអំពីឯកសារបន្ថែមដែលត្រូវផ្ទេរពីសំណុំរឿងលេខ០០២ ត្រូវបានជូនដំណឹង កាលពីថ្ងៃទី២៦ មេសា ២០១០ រួចហើយ ។ ឯកសារលេខ **D10** កំណត់សំគាល់ស្តីពីការដាក់បញ្ចូលឯកសារនៅក្នុងសំណុំរឿងលេខ ០០៣, ចុះថ្ងៃទី២៥ មេសា ២០១១, ERN 00679647-48។

[12] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំង: ឯកសារលេខ **D2/19** ចុះថ្ងៃទី៤ វិច្ឆិកា ២០១០, ERN 00622545–58, ឯកសារលេខ **D2/20** ចុះថ្ងៃទី៤ វិច្ឆិកា ២០១០, ERN 00622533-44, ឯកសារលេខ **D2/21** ចុះថ្ងៃទី៩ ធ្នូ ២០១០, ERN 00630523-36, ឯកសារលេខ **D2/22** ចុះថ្ងៃទី២៩ ធ្នូ ២០១០, ERN 00634138-76, និង ឯកសារលេខ **D2/23** ចុះថ្ងៃទី៣០ ធ្នូ ២០១០, ERN 00644146-84។

ការស្តាប់ចម្លើយសាក្សីចំនួនពីរ(០២) ដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី ២៤ និង ២៥ ខែមីនា ឆ្នាំ២០១១ ហើយថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១១ មានកំណត់ហេតុនៃស្តាប់ចម្លើយសាក្សីមួយដែលបានធ្វើឡើងដោយ សចស ទាំងពីររូបពីមួយថ្ងៃមុននេះ ត្រូវបានគេដាក់នៅលើសំណុំរឿង[13] ។

៨. នៅវេលាម៉ោង ៤:៤៩ រសៀល ថ្ងៃសុក្រ ទី២៩ ខែមេសា ឆ្នាំ២០១១ មានរយៈពេលតែប្រាំពីរ(០៧) សប្តាហ៍ប៉ុណ្ណោះ ក្រោយពីលទ្ធផលទីមួយនៃកិច្ចស៊ើបសួរសំណុំរឿង០០៣ ត្រូវបានគេដាក់ទៅក្នុងសំណុំរឿង សចស បានជូនដំណឹងដល់សហព្រះរាជអាជ្ញាថា ពួកគាត់បានពិចារណាថា កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ បានបញ្ចប់ហើយ[14] ។

៩. មកទល់នឹងថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ គ្មានព័ត៌មានត្រូវបានគេផ្សព្វផ្សាយជាសាធារណៈដើម្បីផ្តល់លទ្ធភាពឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីសំខាន់ៗបានដឹងនិងសម្រេចថាតើ ពួកគាត់បានបំពេញតាមលក្ខនៈវិនិច្ឆ័យសម្រាប់ការទទួលយក ស្របតាមវិធាន២៣(១)(ខ) ដែរឬទេ ។ ទន្ទឹមនេះ នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិ បានចេញសេចក្តីប្រកាសព័ត៌មានមួយដោយគូសបញ្ជាក់អំពី ឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់ និងទីតាំងឧក្រិដ្ឋកម្មទាំងឡាយ ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០៣ ។ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សំណើមួយ សុំឲ្យពន្យារពេលវេលាកំណត់ប្រាំមួយ(០៦) សប្តាហ៍សម្រាប់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០៣ គឺចាប់ពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ ដល់ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១១[15] ។

[13] កំណត់ហេតុស្តាប់ចម្លើយសាក្សី: ឯកសារលេខ **D6** ឈួក រិន (Chhouk Rin), ចុះថ្ងៃទី២៤ មិនា ២០១១, ERN 00725149-55។ ឯកសារលេខ **D8** សំ ប៊ុនឡេង (Sam Bung Leng, ចុះថ្ងៃទី២៥ មីនា ២០១១, ERN 00680152-54។ និងឯកសារលេខ **D12** កាំង្កេកអ៊ាវ ហៅ ឌុច (Kaing Guek Eav alias Duch), ចុះថ្ងៃទី២៧ មេសា ២០១១, ERN 00680795-99។

[14] ឯកសារលេខ **D13** សេចក្តីជូនដំណឹងស្តីពីការបិទកិច្ចស៊ើបសួរ, ចុះថ្ងៃទី២៩ មេសា ២០១១, ERN 00681129-30។

[15] ឯកសារលេខ **D15** សំណើរបស់របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំពន្យារពេលបន្ថែមពីលើពេលវេលាកំណត់សំរាប់ការដាក់ពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿងលេខ០០៣, ចុះថ្ងៃទី១០ ឧសភា ២០១១, ERN 00698581-85។

១០. ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបី (“សំណើ”) ទៅ សចស អនុលោមតាមវិធាន៦៦(១) ដោយសហព្រះរាជអាជ្ញាបានស្នើឲ្យៈ ដាក់ឯកសារបន្ថែមទៅក្នុងសំណុំរឿង និងធ្វើសេចក្តីសង្កេតផ្សេងៗនៅលើស្ថានភាពនៃ កិច្ចស៊ើបសួរ[16]។ បំពេញកិច្ចស៊ើបសួរបន្ថែមទាក់ទងនឹង ស៊ូ ម៉េត និង ទីតាំងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ[17], និងបំពេញកិច្ចស៊ើបសួរបន្ថែមទាក់ទងនឹង មាស មុត និង ទីតាំងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ[18] ។

១១. ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាត្រូវបានគេជូនដំណឹងអំពីដីកាសម្រេចរបស់ កសចស លើសំណើសុំពន្យារពេលកំណត់ និងសំណើសុំបំពេញកិច្ចស៊ើបសួរធ្វើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១ ។ ដីកាសម្រេចនេះបានបង្គាប់ឲ្យសហព្រះរាជអាជ្ញាផ្តល់យោបល់ថា តើសំណើសុំដូចខាងលើទាំងនេះ ត្រូវបានធ្វើឡើងដោយមានការផ្ទេរអំណាច ស្របតាមវិធាន១៣(៣) ឬការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាទាំងពីរត្រូវបានធ្វើកំណត់ហេតុ ស្របតាមវិធាន៧១(១)[19] ដែរឬទេ ។ សហព្រះរាជអាជ្ញាជាតិបានចេញចម្លើយតបមួយទៅនឹងសំណើនេះ នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១១ ដែលក្នុងចម្លើយតបនេះ លោកស្រីបានថ្លែងថា លោកស្រីមិនបានផ្ទេរការទទួលខុសត្រូវរបស់លោកស្រីទៅឲ្យសហព្រះរាជអាជ្ញាអន្តរជាតិទេ និងបានបញ្ជាក់ថា គ្មានការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាទាំងពីរត្រូវ

[16] ឯកសារលេខ **D17** សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរនៅក្នុងសំណុំរឿងលេខ០០៣ លើកទី១ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីឲ្យទទួលយកនូវឯកសារបន្ថែម និងសេចក្តីសង្កេតលើស្ថានភាពនៃកិច្ចស៊ើបសួរ, ចុះថ្ងៃទី១០ មិថុនា ២០១១, ERN 00698659-69(“សំណើសុំឲ្យបំពេញកិច្ចសុំឲ្យបំពេញកិច្ចស៊ើបសួរ លើកទី១”)។

[17] ឯកសារលេខ **D18** សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែមនៅក្នុងសំណុំរឿងលេខ០០៣ លើកទី២ របស់សហព្រះរាអាជ្ញាអន្តរជាតិ ទាក់ទងនឹងឈ្មោះ ស៊ូ ម៉េត (SOU Met ) និងទីកន្លែងឧក្រិដ្ឋកម្មនានាដែលពាក់ព័ន្ធ, ចុះថ្ងទី១០ មិថុនា ២០១០, ERN 00698601-21 (“សំណើសុំឲ្យបំពេញកិច្ចសុំឲ្យបំពេញកិច្ចស៊ើបសួរ លើកទី២”)។

[18] ឯកសារលេខ **D19** សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែមនៅក្នុងសំណុំរឿងលេខ០០៣ លើកទី៣ របស់សហព្រះរាអាជ្ញាអន្តរជាតិ ទាក់ទងនឹងឈ្មោះ មាស មុត (MEAS Mut) និងទីកន្លែងឧក្រិដ្ឋកម្មនានាដែលពាក់ព័ន្ធ, ចុះថ្ងៃទី១០ មិថនា ២០១១, ERN 00698637-58។

[19] ឯកសារលេខ **D20** ដីកាសំរេចលើសំណើសុំពន្យារពេលបន្ថែមពីលើពេលវេលាកំណត់ និងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ក្នុងសំណុំរឿងលេខ ០០៣ របស់សហព្រះរាជអាជ្ញាអន្តរជាតិ, ចុះថ្ងៃទី១៩ ឧសភា ២០១១, ERN 00698907-09។

បានធ្វើកំណត់ហេតុឡើយ[20] ។ នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិបានឆ្លើយតបទៅសំណើរបស់ សចស ដោយតវ៉ាថា ទាំងការធ្វើកំណត់ហេតុនៃការខ្វែងយោបល់គ្នា និងទាំងការផ្ទេរអំណាចមិនមែនជាលក្ខខណ្ឌតម្រូវទេ[21]។ សហព្រះរាជអាជ្ញាអន្តរជាតិបានសន្និដ្ឋានថា (១) គេមានការទទួលស្គាល់ចំពោះទម្លាប់នៃការអនុវត្តរបស់តុលាការ អំពីគូភាគីដែលដាក់ឯកសារតែម្នាក់, (២) សហព្រះរាជអាជ្ញាជាតិបានជ្រើសរើសមិនផ្ទេរអំណាច ឬធ្វើកំណត់ហេតុអំពីការខ្វែងយោបល់គ្នាណាមួយទេ និង (៣) ការខ្វែងយោបល់គ្នាដំបូង រវាងសហព្រះរាជអាជ្ញាទាំងពីរទាក់ទងនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក្នុងសំណុំរឿង០០៣ បានគ្រប់ដណ្តប់ទៅលើគ្រប់សកម្មភាពឯករាជ្យរបស់ការិយាល័យអយ្យការទាំងអស់នៅក្នុងករណីនេះ ។

១២. សចស បានបដិសេធទាំងលើសំណើសុំពន្យារពេលកំណត់សម្រាប់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងទាំងសំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិតាមរយៈដីកាសម្រេចមួយចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១១[22] ។ សេចក្តីសម្រេចនេះ មិនបានលើកមកដោះស្រាយអំពីអង្គសេចក្តី ដែលមានក្នុងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិទេ ។ ផ្ទុយទៅវិញ សំណើសុំទាំងនោះត្រូវបានច្រានចោលដោយឈរលើមូលដ្ឋាននៃការកំណត់របស់ សចស ថា សហព្រះរាជអាជ្ញាអន្តរជាតិមិនបានអនុវត្តតាមលក្ខខណ្ឌតម្រូវផ្នែកនីតិវិធី ដូចមានចែងនៅក្នុងវិធាន១៣ និង វិធាន៧១ ។

១៣. ក្រោយពេលបានទទួលសេចក្តីសម្រេចរបស់ សចស ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១១ រួចហើយសហព្រះរាជអាជ្ញាអន្តរជាតិបានធ្វើកំណត់ហេតុតាមទម្រង់ការស្តីពីការខ្វែងយោបល់គ្នាជាមួយនឹង

---

[20] ឯកសារលេខ **D20/1** ចម្លើយតបរបស់សហព្រះរាអាជ្ញាអន្តរជាតិទៅនឹងដីកាសំរេចរបស់សហចៅក្រមស៊ើបអង្កេតស្តីពីការសុំពន្យារពេលបន្ថែមពីលើពេលវេលាកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមក្នុងសំណុំរឿងលេខ០០៣ របស់សហព្រះរាជអជ្ញាអន្តរជាតិ, ចុះថ្ងៃទី២៥ មេសា ២០១១, ERN 00699836–37។

[21] ឯកសារលេខ D20/2 ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំពន្យារពេលបន្ថែមពីលើពេលវេលាកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ក្នុងសំណុំរឿងលេខ០០៣ របស់សហព្រះរាជអាជ្ញាអន្តរជាតិ, ចុះថ្ងៃទី២៦ ឧសភា ២០១១, ERN 00699776–83។

[22] ឯកសារលេខ **D20/3** ដីកាសំរេចលើសំណើសុំពន្យារពេលបន្ថែមពីលើពេលវេលាកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ក្នុងសំណុំរឿងលេខ ០០៣ របស់សហព្រះរាជអាជ្ញាអន្តរជាតិ, ចុះថ្ងៃទី៧ មិថុនា ២០១១, ERN 00702797-802។

សហព្រះរាជអាជ្ញាជាតិ ពាក់ព័ន្ធនឹងការស្នើសុំពន្យារពេលដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរនីមួយៗ ។ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សំណើនីមួយៗទាំងនោះសារជាថ្មីម្តងទៀត សុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែមទៀត ហើយនិងសុំពន្យារពេលដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។ សហព្រះរាជអាជ្ញាអន្តរជាតិ ដោយអនុលោមតាមវិធាន៣៩.៤ បានស្នើសុំឲ្យ សចស អនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការទទួលស្គាល់នូវសុពលភាពនៃ "សកម្មភាពកំពុងត្រូវបានអនុវត្តនេះ បន្ទាប់ពីការផុតពេលវេលាកំណត់...តាមលក្ខខណ្ឌដែលខ្លួនយល់ឃើញថាសមស្រប" [23] ។

១៤. នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិ បានប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចរបស់ សចស ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១១ ទៅ អបជ[24] ។ បណ្តឹងឧទ្ធរណ៍បានពោលអះអាងថា វិធានបានអនុញ្ញាតឲ្យមានសិទ្ធិក្នុងការផ្ទេរនូវសិទ្ធិអំណាច ឬ ធ្វើកំណត់ហេតុមួយស្តីពីការខ្វែងយោបល់គ្នា ប៉ុន្តែការអនុវត្តនូវសិទ្ធិបែបដូច្នេះគឺមិនចាំបាច់ដើម្បីធ្វើឲ្យសហព្រះរាជអាជ្ញាអន្តរជាតិ មានលទ្ធភាពបំពេញកិច្ចតែម្នាក់ឯងនោះទេ ។ ជាជម្រើសម្យ៉ាងទៀត សហព្រះរាជអាជ្ញាអន្តរជាតិ សូមជូនសេចក្តីសន្និដ្ឋានថា៖(ក) ទាក់ទងទៅនឹងវិធាន ២១.ក នៃវិធានផ្ទៃក្នុង លក្ខខណ្ឌតម្រូវដែលថាដំណើរការនីតិវិធី "រក្សានូវតុល្យភាពមួយរវាងភាគីនានា" សចស គួរតែបានផ្តល់ដល់សហព្រះរាជអាជ្ញាអន្តរជាតិ នូវកាលានុវត្តភាពមួយដើម្បីដោះស្រាយនូវកំហុសនីតិវិធីដែលបានយល់ឃើញ និង(ខ) ការខកខានរបស់ សចស ក្នុងការពិចារណាលើខ្លឹមសារនៃសំណើរបស់សហព្រះរាជអាជ្ញា អន្តរជាតិ គឺល្មើសទៅនឹងកាតព្វកិច្ចរបស់ សចស ក្នុងការបំពេញកិច្ច

[23] ឯកសារលេខ **D22** ការដាក់ជាសារថ្មីឡើងវិញនូវសំណើលើកទី១របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យបំពេញកិច្ចស៊ើបសួរនៅក្នុងសំណុំរឿងលេខ០០៣ ដើម្បីឲ្យទទួលយកនូវឯកសារបន្ថែមនិងការសង្កេតលើស្ថានភាពនៃកិច្ចស៊ើបសួរ,ចុះថ្ងៃទី១០ មិថុនា ២០១១, ERN 00720695-704, កថាខណ្ឌទី១។ ឯកសារលេខ **D23** ការដាក់ជាសារថ្មីឡើងវិញនូវសំណើលើកទី២របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែមទាក់ទងនឹងឈ្មោះ ស៊ូ ម៉េត (Sou Met) និងទីកន្លែងឧក្រិដ្ឋកម្មនានាដែលពាក់ព័ន្ធ, ចុះថ្ងៃទី ១០ មិថុនា ២០១១, ERN 00720752-74, កថាខណ្ឌទី១។ ឯកសារលេខ **D24** ការដាក់ជាសារថ្មីឡើងវិញនូវសំណើលើកទី៣របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែមទាក់ទងនឹងឈ្មោះ មាស មុត (Meas Mut) និងទីកន្លែងឧក្រិដ្ឋកម្មនានាដែលពាក់ព័ន្ធ ,ចុះថ្ងៃទី១០ មិថុនា ២០១១, ERN 00720814–29, កថាខណ្ឌទី១ ។

[24] ឯកសារលេខ **D20/4** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹង "ដីកាសំរេចលើសំណើសុំពន្យារពេលបន្ថែមពីលើពេលវេលាកំណត់ និងសំណើសុំឲ្យបំពេញកិច្ចស៊ើសួរនៅក្នុងសំណុំរឿងលេខ០០៣", ចុះថ្ងៃទី៧ កក្កដា ២០១១, ERN 00712876-906 ។

ស៊ើបសួរទាំងស្រុងមួយ និងដែលមានលក្ខណៈមិនលម្អៀង។ អបជ នៅមិនទាន់បានសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១១ នៅឡើយទេ។

១៥. នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១ សចស បានបដិសេធចោលនូវសំណើទាំងនោះ ដែលសហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សាជាថ្មីឡើងវិញនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១ ដោយមានទឡ្ហីករណ៍ ដូចតទៅ៖

(ក) បណ្តឹងឧទ្ធរណ៍ដែលកំពុងរង់ចាំនេះ ស្តីពីសុពលភាពនៃសំណើទាំងនេះ “មិនត្រឹមតែនៅលើទឡ្ហីករណ៍ទម្រង់ការប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងនៅលើខ្លឹមសារ ទៀតផង - បង្គាប់ឲ្យ កសចស មិនឲ្យ “ចៀសវាងពីយុត្តាធិការរបស់ អបជ ដោយការធ្វើសេចក្តីសម្រេច នៅលើបញ្ហានេះដោយខ្លួនឯងផ្ទាល់នោះឡើយ (“ការបដិសេធដោយផ្អែកលើទឡ្ហីករណ៍នានានៃបណ្តឹងឧទ្ធរណ៍ដែលកំពុងព្យួរបច្ចុប្បន្ន”, កថាខណ្ឌទី២៣ ដល់២៩ខាងក្រោម) ។

(ខ) សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សាជាថ្មីម្តងទៀតនូវសំណើនានារបស់ខ្លួនសុំឲ្យធ្វើការស៊ើបសួរបន្ថែមទៀត ទៅតាមវិធាន ៦៦.១ នៃវិធានផ្ទៃក្នុង នៅក្រៅរយៈពេលចំនួន ១៥ថ្ងៃ និង មិនបានប្រើប្រាស់ឲ្យមានប្រយោជន៍នូវនីតិវិធីដែលបានចែងនៅក្នុងវិធាន ៥៥.១០ នៃវិធានផ្ទៃក្នុង ដែលបានអនុញ្ញាតឲ្យធ្វើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ នៅដំណាក់កាលណាមួយក៏បានក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ (“ការបដិសេធដោយផ្អែកលើមូលដ្ឋាននៃភាពគ្មានពេលវេលាកំណត់”, កថាខណ្ឌទី៣០ដល់៣៧ ខាងក្រោម), ហើយនិង

(គ) សំណើនានារបស់សហព្រះរាជអាជ្ញាអន្តរជាតិ មិនបានផ្តល់នូវ “ការពិចារណាល្អិតល្អន់គ្រប់គ្រាន់” អំពី “យុត្តាធិការជាមូលដ្ឋាន” នៃមាត្រា២ នៃច្បាប់ អវតក ទេ ហើយ សចស ត្រូវបានបង្គាប់ដោយវិធាន ៥៥.១ នៃវិធានផ្ទៃក្នុង ដែលបានចែងថាអនុញ្ញាតឲ្យធ្វើការ

ស៊ើបសួរតែ "នៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ" ប៉ុណ្ណោះ[25] ("ការបដិសេធដោយផ្អែកលើមូលដ្ឋាននៃយុត្តាធិការបុគ្គល", កថាខណ្ឌទី៣៨ដល់៤០ ខាងក្រោម) ។

## ៣. ច្បាប់ជាធរមាន

១៦. ច្បាប់ជាធរមានដែលពាក់ព័ន្ធ រួមមាន បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង, ច្បាប់ អវតក, វិធានផ្ទៃក្នុង ("វិធាន"), ច្បាប់ស្ដីពីនិតិវិធី និងការអនុវត្តន៍របស់កម្ពុជា។

១៧. <u>បុព្វកថា និងផ្នែកសំរាប់អនុវត្តនៃកិច្ចព្រមព្រៀង</u> ចែងថា៖

*ដោយហេតុថា អាជ្ញាធរកម្ពុជាបានស្នើសុំជំនួយពីអង្គការសហប្រជាជាតិដើម្បីកាត់សេចក្ដីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលត្រូវទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអម្លុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ៦ មករា ១៩៧៩។*

<u>មាត្រា១("គោលបំណង")</u>៖

*គោលបំណងរបស់កិច្ចព្រមព្រៀងនេះ គឺកំណត់អំពីកិច្ចសហប្រតិបត្តិការ រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់សេចក្ដីមេដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអម្លុងថ្ងៃ ១៧ មេសា ១៩៧៥*

[25] ឯកសារលេខ **D26** ដីកាសំរេច, កំណត់សំគាល់លេខ២ ខាងលើ ត្រង់កថាខណ្ឌទី៥, ៦(ក)-(ឃ)។

*ដល់ថ្ងៃ៦ មករា ១៩៧៩។ ក្នុងចំណោមប្រការផ្សេងៗទៀតកិច្ចព្រមព្រៀងនេះផ្តល់មូលដ្ឋានគតិយុត្តិ គោលការណ៍ និងបែបបទសំរាប់កិច្ចប្រតិបត្តិការនេះ។*

<u>មាត្រា២(១) ("ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ")</u>៖

[...] *កិច្ចព្រមព្រៀងនេះទទួលស្គាល់ផងដែរថា អង្គជំនុំជម្រះនេះមានយុត្តាធិការលើរូបបុគ្គលជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានចែងក្នុងមាត្រា១ នៃកិច្ចព្រមព្រៀង។*

១៨. មាត្រា ២ថ្មី នៃច្បាប់ អវតក ចែងថា៖

*ត្រូវបានបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញ [...] ដើម្បីជំនុំជម្រះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជា ដែលពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋ ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ និងការរំលោភទៅលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយ ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩ ។ មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង អ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើឧក្រិដ្ឋខាងលើនេះ ហៅថា "ជនសង្ស័យ" ។*

១៩. វិធាន ៣៩.៤ ("ពេលវេលាកំណត់ និង លក្ខខណ្ឌក្នុងការដាក់ឯកសារ") ចែងថា៖

*តាមរយៈពាក្យសុំរបស់ភាគីពាក់ព័ន្ធ ឬ តាមគំនិតផ្តួចផ្តើមរបស់ខ្លួន សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ អាច៖ (ក) ពន្យារពេលវេលាកំណត់ ដែលខ្លួនបានសម្រេច, ឬ (ខ) ទទួលស្គាល់ថាមានសុពលភាព ចំពោះកិច្ចទាំងឡាយណាដែលបានធ្វើក្រោយពីពេលកំណត់ដែលមានចែងក្នុងវិធានផ្ទៃក្នុងនេះត្រូវបានផុតរលត់ ប្រសិនបើខ្លួនយល់ឃើញថាត្រឹមត្រូវសមហេតុផល ។*

២០. វិធាន ៦៦.១ ("ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា [សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ]") ចែងថា៖

*នៅពេលដែលសហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការស៊ើបសួរត្រូវបានបញ្ចប់ សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងដល់ភាគី និង មេធាវីរបស់ភាគី ។ សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរនេះត្រូវប្រកាសជាសាធារណៈ ។ ភាគីទាំងអស់មានរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ ដើម្បីសុំឱ្យមានកិច្ចស៊ើបសួរបន្ថែម ។ ភាគីទាំងអស់អាចលះបង់ថិរវេលានេះបាន ។*

២១. វិធាន ៥៥ ("បទប្បញ្ញត្តិទូទៅទាក់ទងទៅនឹងការស៊ើបសួរ") ចែងថា៖

*១. ការស៊ើបសួរត្រូវតែធ្វើដោយខានពុំបានចំពោះឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។*

*២. សហចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបសួរតែអង្គហេតុណា ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ។*

*៥. ក្នុងការដឹកនាំកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត ដោយអនុលោមតាមច្បាប់ ។ ក្នុងគ្រប់ករណីទាំងអស់ សហចៅក្រមស៊ើបអង្កេតត្រូវដឹកនាំកិច្ចស៊ើបសួរដោយអនាគតិ ទោះបីជាភស្តុតាងដែលនឹងរកបាននោះជាភស្តុតាងដាក់បន្ទុក ឬភស្តុតាងដោះបន្ទុកក៏ដោយ ។ [...]*

## ៤. ឧឡារិករណ៍

### ក. បទដ្ឋានជាធរមានសំរាប់ការពិនិត្យឡើងវិញលើបណ្ដឹងឧទ្ធរណ៍ត្រូវបានដោះស្រាយនៅក្នុង យុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ

២២. យុត្តិសាស្ត្រដែលបានដោះស្រាយរួចរបស់អង្គបុរេជំនុំជម្រះ ដែលចាប់ផ្ដើមដោយដីកាសំរេចស្ដីពីឃ្លាំងផ្ទុកឯកសាររួមនៅក្នុងកុំព្យូទ័រ(SMD) ក្នុងឆ្នាំ២០០៩ និងបានពង្រឹងបន្ថែមនៅក្នុងដីកាសំរេចជាបន្តបន្ទាប់មកទៀតនោះ[26] បានបង្ហាញឲ្យឃើញថា បទដ្ឋានសំរាប់ការពិនិត្យឡើងវិញលើបណ្ដឹងឧទ្ធរណ៍ ដែលអាចអនុវត្តបានចំពោះការអនុវត្តឆន្ទានុសិទ្ធិរបស់តុលាការ ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត នឹងអាចត្រូវបានបំពេញសពគ្រប់ បើសិនជាដីកាសំរេចនោះផ្អែក លើមូលដ្ឋាន៖ (១) នៃការបកស្រាយដោយមិនត្រឹមត្រូវណាមួយ លើច្បាប់ជាធរមាន(ឬ លើ"មូលដ្ឋាននៃការភាន់ច្រឡំណាមួយខាងអង្គច្បាប់")។ ឬ (២) នៃសេចក្ដី សន្និដ្ឋានលើអង្គហេតុដែលខុសយ៉ាងច្បាស់ក្រឡែត(" ឬ លើការរកឃើញអង្គហេតុដែលខុស យ៉ាងច្បាស់") ។ ឬ បើសិនជាការ បកស្រាយនោះស្មើនឹងការរំលោភបំពានទៅលើឆន្ទានុសិទ្ធិរបស់ តុលាការដោយសារមូលហេតុមកពី (ក) មិនមានភាពត្រឹមត្រូវ ។ ឬ (ខ) មិនមានភាពសមហេតុសមផល ។

---

[26] **D164/4/13,** សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម, ថ្ងៃទី១៨ វិច្ឆិកា ២០០៩, លេខERN 00402746-62, ត្រង់កថាខណ្ឌទី ២២-២៧ (ដោយបានលើកឡើងពី *Milošević ទល់នឹង រដ្ឋអាជ្ញា,* សំណុំរឿងលេខ IT 02-S4-AR73.7, សាលដីកាលើបណ្ដឹងឧទ្ធរណ៍បន្ទាន់បង្ខំលើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីការ ចាត់តាំងក្រុមមេធាវីការពារក្ដី, អង្គជំនុំជម្រះសាលាឧទ្ធរណ៍តុលាការ ICTY, ថ្ងៃទី១ វិច្ឆិកា ២០០៤ ត្រង់កថាខណ្ឌទី ៩-១០) ។ **D140/9/5,** សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបដិសេធសំណើរបស់ខ្លួនសុំការតែង
តាំងអ្នកជំនាញផ្នែកប្រជាសាស្ត្របន្ថែមដើម្បីពិនិត្យឡើងវិញនូវខ្លឹមសារនៃរបាយការណ៍របស់អ្នកជំនាញដាក់ជូនដោយលោកស្រី Ewa Tabeau និងលោក ថឺ ឃាម, ថ្ងៃទី២៨ មិថុនា ២០១០, លេខERN 00542271-83 ត្រង់កថាខណ្ឌទី ១៥-១៧ ។ **D356/2/9,** សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធលើសំណើសុំយោបល់ពីអ្នក ជំនាញជាលើកទីពីរ, ថ្ងៃទី១ កក្កដា ២០១០, លេខERN 00539166-00539175 ត្រង់កថាខណ្ឌទី ១៦-១៨ ។

## ខ. ការបដិសេធលើសំណើសុំនានាដោយផ្អែកលើមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ដែលកំពុងរង់ចាំ សវនាការឱ្យបំពេញឱ្យបានគ្រប់ទៅតាមលក្ខខណ្ឌនៃបទដ្ឋានសំរាប់ការពិនិត្យឡើងវិញលើបណ្តឹងឧទ្ធរណ៍

### *i. ដីកាសំរេចបកស្រាយដោយមិនត្រឹមត្រូវលើច្បាប់ជាធរមាន*

២៣. ២៣. មូលហេតុទីមួយនៃការបដិសេធលើសំណើសុំទាំងនេះ គឺអង្គបុរេជំនុំជម្រះត្រូវបានប្តឹងមក "អំពីថាតើសំណើសុំទាំងនេះមានសុពលភាពដែរឬទេ?" ដែលអាស្រ័យហេតុនេះសហចៅក្រមស៊ើបអង្កេត(សចស) មិនអាច "ធ្វើការជ្រៀតជ្រែកនៅក្នុងសមត្ថកិច្ចរបស់អង្គបុរេជំនុំ ជម្រះបានទេ" ...ហើយដើម្បីរកផ្លូវបញ្ចៀសបញ្ហាអំពីយុត្តាធិការរបស់អង្គបុរេជំនុំជម្រះ ដោយធ្វការសំរេចលើបញ្ហានេះដោយ (សចស) ខ្លួនឯង"[27] ។ ដើម្បីគាំទ្រចំពោះមូលដ្ឋាននៃការបដិសេធលើ សំណើទាំងនេះ សចស បានយោងទៅលើការសំរេចរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលមិនគ្រាន់តែផ្អែកបណ្តឹងឧទ្ធរណ៍លើកទីមួយរបស់ខ្លួនទៅលើមូលហេតុជាផ្លូវការណ៍តែប៉ុណ្ណោះទេ ក៏ប៉ុន្តែជាជំរើសសម្រាប់ជំនួសគឺផ្អែកទៅលើខ្លឹមសារទៀតផង ។ សព្រះរាជអាជ្ញាអន្តរជាតិបានចោទថា "បរាជ័យរបស់ សចសក្នុងការមិនបានពិត្យពិចារណាទៅលើខ្លឹមសារនៃសំណើសុំគឺជាការល្មើសនឹងកាតព្វកិច្ចតាមផ្លូវច្បាប់របស់ សចស ក្នុងការដឹកនាំធ្វើកិច្ចស៊ើបសួរដោយមិនលំអៀង និងឱ្យ បានចប់សព្វគ្រប់"[28] ។សចស ហាក់ដូចជាយល់ឃើញថា ការដាក់ជូននូវមូលហេតុនៃការប្តឹងឧទ្ធរណ៍ដែលជាជំរើសសំរាប់ជំនួសនេះ គឺបានព្យួរនូវសមត្ថកិច្ចទាំងស្រុងរបស់ សចស ក្នុងការពិនិត្យពិចារណាទៅលើអង្គសេចក្តីនៃសំណើសុំនៅក្នុងពេលរង់ចាំការសំរេចលើបណ្តឹងឧទ្ធរណ៍ ។ ដោយគោរពជូនយោបល់ថា ការវែកញែកហេតុផលនេះគឺជាការមិនត្រឹមត្រូវទេខាងអង្គច្បាប់ ។

២៤. ២៤. សមត្ថកិច្ចទៅលើកិច្ចស៊ើបសួរគឺវាស្ថិតនៅជារបស់ កសចស រហូតទល់នឹងពេលបិទសំណុំរឿងអនុលោមតាមវិធាន៦៨.២ នៃវិធានផ្ទៃក្នុង ហើយការទទួលខុសត្រូវនេះ ស្ថិតនៅជា

[27] **D26**, ដីកាសម្រេច, កំណត់សម្គាល់*ខាងលើ* លេខ២ ត្រង់កថាខណ្ឌទី ៥ ។

[28] **D20/4/1**, បណ្តឹងឧទ្ធរណ៍ទីមួយ, កំណត់សម្គាល់*ខាងលើ* លេខ៣ ត្រង់កថាខណ្ឌទី ៩.គ(ii) ។ **D26**, ដីកាសម្រេច, កំណត់សម្គាល់*ខាងលើ* លេខ២ ត្រង់កថាខណ្ឌទី ៤-៥ ។

ដដែលនៅក្នុងពេលរង់ចាំការធ្វើបណ្តឹងឧទ្ធរណ៍ណាមួយលើបញ្ហាបន្ទាន់បង្ហំ។ ការធ្វើបណ្តឹងឧទ្ធរណ៍ផ្សេងៗចំពោះដីកាសម្រេចរបស់ កសចស ដោយសហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៧៣.ក និង ៧៤.២ គឺត្រូវដាក់ឲ្យស្ថិតក្រោមវិធាន ៧៧.១១ នៃវិធានផ្ទៃក្នុង ដែលចែងថា ក្នុងពេលរង់ចាំការសំរេចលើបណ្តឹងឧទ្ធរណ៍ សចស "អាចបន្តការស៊ើបសួររបស់ខ្លួននៅពេលនាដែលអាចធ្វើទៅបាន" ។ ហេតុ ដូចនេះ ថ្វីត្បិតតែមានការជូនដំណឹងអំពីការបិទកិច្ចស៊ើបសួចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ក៏ដោយក៏ការទទួលខុសត្រូវក្នុងការពិនិត្យ និងចាត់វិធានការទៅលើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែមនានា គឺស្ថិតលើឆន្ទានុសិទ្ធិតុលាការរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតជាដដែល ។

២៥. នៅពេលដែលមិនយល់ព្រម និងធ្វើបណ្តឹងឧទ្ធរណ៍ចំពោះទិដ្ឋភាពមួយនៃសេចក្តីសំរេចរបស់ សចស គឺបានន័យថាការបកស្រាយរបស់ កសចស អំពីវិធាន១៣.៣, និងវិធាន៧១.១ នៃវិធានផ្ទៃក្នុងនោះ គឺសហព្រះរាជអាជ្ញាបានគោរពតាមសេចក្តីសំរេចរបស់ សចស ត្រូវបានទទួលនូវការដោះស្រាយបញ្ហាបានយ៉ាងឆាប់រហ័សស្តីពីការចោទប្រកាន់ក្នុងសំណើសុំនានាដែលថា មានការខ្វះខាតផ្នែកបច្ចេកទេស ហើយបានដាក់សំណើនានាជាថ្មីម្តងទៀតសុំឲ្យពិនិត្យពិចារណាលើអង្គសេចក្តី។ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ គឺមិនមែន "លើខ្លឹមសារ" ដូចដែលបានពោលអះអាងនៅក្នុងដីកាសំរេចនោះទេ[29] ប៉ុន្តែផ្ទុយទៅវិញ មានការព្រួយបារម្ភ ដោយផ្នែកខ្លះ ទៅលើ*ការខកខានរបស់ សចស ដែលមិនបានពិនិត្យពិចារណាទៅលើខ្លឹមសារ*នៃសំណើទាំងនេះ ។ ការធ្វើដូច្នេះ គឺសហព្រះរាជអាជ្ញាអន្តរជាតិបានធ្វសកម្មភាពដោយសុទ្ធចិត្ត ដែលស្របទៅនឹងការចាំបាច់ឲ្យមានភាពឆាប់រហ័សនៅក្នុងដំណើរការនីតិវិធី[30] និងការគិតគូរពិចារណាដ៏ច្រើនសន្ធឹកសន្ធាប់នៅក្នុងកិច្ចព្រមព្រៀង និងនៅក្នុងច្បាប់អវតក ដែលថាក្នុងករណីដែលមានការខ្វែងយោបល់គ្នា ការកាត់សេចក្តី "ត្រូវតែបន្តធ្វើ"[31] ។

[29] **D26**, ដីកាសម្រេច, កំណត់សម្គាល់*ខាងលើ* លេខ២ ត្រង់កថាខណ្ឌទី ៥ ។

[30] វិធាន ២១.៤ នៃវិធានផ្ទៃក្នុង ។

[31] កិច្ចព្រមព្រៀង, កំណត់សំគាល់*ខាងដើម* លេខ៧០, *មាត្រា* ៦.៤ ។ ច្បាប់ អវតក, កំណត់សំគាល់*ខាងដើម* លេខ៧១, មាត្រា ២០(ថ្មី) ។

២៦. បណ្តឹងឧទ្ធរណ៍មួយស្តីពីបញ្ហាបន្ទាន់បង្ខំអំពីមូលដ្ឋានខាងបច្ចេកទេសចំពោះការបដិសេធលើសំណើសុំទានា គឺវាមិនធ្វើឱ្យផ្អាកដល់សមត្ថកិច្ចរបស់ កសចស ទាំងស្រុងលើបណ្តឹងទាំងនេះទេ ។ អង្គបុរេជំនុំជម្រះធ្លាប់បានសំរេចកាលពីមុនថា បណ្តឹងឧទ្ធរណ៍លើបញ្ហាបន្ទាន់បង្ខំនៅក្នុងដំណាក់កាលមុនការជំនុំជម្រះក្តី គឺមិនមានឥទ្ធិពលដែលធ្វើឱ្យផ្អាកជាស្វ័យប្រវត្តិនោះឡើយ[32] ហើយថាមាន*ការចន្លោះប្រហោង* នៅក្នុងវិធានផ្ទៃក្នុង និងនៅក្នុងច្បាប់កម្ពុជាអំពីរឿងនេះ[33] ។ នេះគឺមានលក្ខណៈផ្ទុយគ្នា ជាពិសេសទៅនឹងយុត្តាធិការនានានៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ដែលគួរឱ្យកត់សំគាល់នោះ គឺប្រព័ន្ធច្បាប់របស់ប្រទេសអាល្លឺម៉ង់[34] ។ ហេតុដូចនេះ មិនមានមូលហេតុណាដើម្បីឱ្យ កសចស ធ្វើការផ្អាក មិនធ្វើការពិនិត្យពិចារណាទៅលើសំណើសុំទានានោះឡើយ។ ការផ្អាកនឹងក្លាយជាដំណោះស្រាយត្រឹមត្រូវតាមផ្លូវច្បាប់មួយ "បើសិនជាការអនុវត្តនូវសេចក្តីសំរេចណាមួយនៅមុនពេលកំណត់សំរេចលើបណ្តឹងឧទ្ធរណ៍និងធ្វើឱ្យសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ប្រែទៅជាគ្មានន័យ"[35] ។ សហព្រះរាជអាជ្ញាអន្តរជាតិសូមលើកឡើងថា គ្មានមូលហេតុណាដើម្បីផ្អាកការមិនធ្វើការពិនិត្យពិចារណាលើសំណើដែលមានអត្ថិភាពនៅក្នុងរឿងក្តីនេះទេ ។ ការផ្អាកមិនត្រូវបានស្នើសុំនោះឡើយ ហើយក៏មិនត្រូវបានបង្គាប់ដោយអង្គបុរេជំនុំជម្រះ ដោយមាន*មូលហេតុសមស្រប*នោះដែរ[36] ។

២៧. ដោយសារមូលហេតុទាំងនះ សហព្រះរាជអាជ្ញាអន្តរជាតិសូមសន្និដ្ឋានថា អត្ថិភាពនៃការរង់ចាំការសម្រេចលើបណ្តឹងឧទ្ធរណ៍ មិនមែនជាដាក់ការបង្ហាញនូវមូលហេតុស្របច្បាប់ណាមួយសម្រាប់ឱ្យបដិសេធលើសំណើសុំទានាឡើយ និងថាការភាន់ច្រឡំផ្នែកច្បាប់នេះ បានបំពេញតាមបទដ្ឋានសម្រាប់ការពិនិត្យលើបណ្តឹងឧទ្ធរណ៍ដោយអង្គបុរេជំនុំជម្រះ ។

---

[32] **D14/1/2**, ដីកាសម្រេចព្យួរការអនុវត្ត "ដីកាសម្រេចស្តីពីសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣", ថ្ងៃទី១៣ មិថុនា ២០១១, លេខERN 00704894-97 ត្រង់កថាខណ្ឌទី ៣ ("ដីកាព្យួរ") ។

[33] *ដដែលដូចមុន*, ត្រង់កថាខណ្ឌទី ៤ ។

[34] សូមមើល ឧទា. *Verwaltungsgerichtsordnung* (VwGO), ss. 80, 80(b) ។

[35] **D14/1/2**, ដីកាព្យួរ, កំណត់សម្គាល់*ខាងលើ* លេខ៣២ ត្រង់កថាខណ្ឌទី ៣ ។

[36] *ដដែលដូចមុន*, ត្រង់កថាខណ្ឌទី ៤ ។

### *ii. ដីកាសម្រេច គ្មានសំអាងហេតុ និងមានតម្លៃស្មើនឹងការបំពានផ្ទុយនឹងសិទ្ធិតុលាការ*

២៨. ការបដិសេធលើសំណើសុំដែលឈរលើមូលដ្ឋាននៃការរង់ចាំការសម្រេចលើបណ្តឹងឧទ្ធរណ៍ វាមានន័យយ៉ាងសាមញ្ញថា មិនស៊ីសង្វាក់គ្នានឹងសេចក្តីសម្រេចមុនៗរបស់ កសចស ទេ ហើយក៏មិនបានបង្ហាញអំពីមូលហេតុត្រឹមត្រូវណាមួយ ដែលនាំឲ្យខ្លួនងាកចេញពីការសម្រេចមុនៗយ៉ាងដូច្នេះ ។ អាស្រ័យហេតុនេះ ដីកាសម្រេចនេះ គឺជាការធ្វើតាមទំនើងចិត្ត និងធ្វើឲ្យខូចដល់ភាពប្រាកដប្រជានៃច្បាប់[37] ។ ជាពិសេស មេធាវីការពារក្តី អៀង សារី បានដាក់ជូនសំណើសុំបំពេញកិច្ចស៊ើបសួរមួយទៅ កសចស ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ ពាក់ព័ន្ធនឹងយុទ្ធសាស្ត្រនៃកិច្ចស៊ើបសួរ[38] ។ ដោយសារការឆ្លើយតបពី កសចស នឹងមិនមានការកើតឡើង មេធាវីការពារក្តី អៀង សារី បានដាក់សេចក្តីជូនដំណឹងមួយអំពីបណ្តឹងឧទ្ធរណ៍ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩ ដែលបញ្ចេះឲ្យមានការប្តឹងឧទ្ធរណ៍ចំពោះយុត្តាធិការរបស់ អបជ[39] ។ ពីរខែក្រោមមក នៅពេលរង់ចាំការសម្រេចលើបណ្តឹងឧទ្ធរណ៍នេះ កសចស បានដាក់លិខិតក្នុងសំណុំរឿង ផ្ញើជូនមេធាវីការពារក្តី អៀង សារី (រួមជាមួយក្រុមមេធាវីការពារក្តីផ្សេងទៀតដែលគាំទ្រសំណើ) ពាក់ព័ន្ធទាំងបែបបទ និងខ្លឹមសារនៃសំណើ[40] ។ សកម្មភាពរបស់ កសចស នេះ បង្ហាញឲ្យឃើញយ៉ាងសាមញ្ញថា សូម្បីតែបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ថែមួយដែលមានលក្ខណៈទូលំទូលាយអំពី "ការច្រានចោលតាមការសន្មត" ចំពោះសំណើរបស់គូភាគីក៏ដោយ ក៏មិនបានព្យួរសមត្ថកិច្ច កសចស មិនឲ្យលើកឡើងពីទម្រង់បែបបទ និងខ្លឹមសារនៃសំណើនោះដែរ ។

---

[37] **E50**, សេចក្តីសម្រេចលើសំណើសុំដោះលែងបន្ទាន់របស់ នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ, ថ្ងៃទី១៦ កុម្ភៈ ២០១១, លេខERN 00644864-78 ត្រង់កថាខណ្ឌទី ២៣-២៧ ។ សូមមើលផងដែរ *Khudoyorov ទល់នឹង ប្រទេសរុស្ស៊ី,* សំណើលេខ ៦៨៤៧/០២, សាលក្រម (តុលាការសិទ្ធិមនុស្សអឺរ៉ុប), ថ្ងៃទី៨ វិច្ឆិកា ២០០៥ ត្រង់កថាខណ្ឌទី ១២៥, ១៣១, ១៣៥-១៣៦, ១៤៦ ។ *Stasaitis ទល់នឹង ប្រទេសលីទុយអានី,* សំណើលេខ ៤៧៦៧៩/៩៩, (តុលាការសិទ្ធិមនុស្សអឺរ៉ុប) សាលក្រម, ថ្ងៃទី២១ មីនា ២០០២ ត្រង់កថាខណ្ឌទី ៦៧ ។

[38] **D171**, សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរលើកទីបីរបស់លោក អៀង សារី, ថ្ងៃទី២១ ឧសភា ២០០៩, លេខERN 00330795-818 ។

[39] **D171/4**, កំណត់ហេតុចុះបណ្តឹងឧទ្ធរណ៍, ថ្ងៃទី១៩ តុលា ២០០៩, លេខERN 00390105 ។

[40] **D171/5**, លិខិតជូនក្រុមមេធាវីការពារក្តី អៀង សារី, នួន ជា និង ខៀវ សំផន, ថ្ងៃទី១១ ធ្នូ ២០០៩, លេខERN 00414038-49 ។

២៩. ដោយសារមូលហេតុទាំងនេះ សហព្រះរាជអាជ្ញាអន្តរជាតិសូមសន្និដ្ឋានថា ការបដិសេធចោលលើសំណើសុំនានាដោយឈរលើមូលដ្ឋាននៃ ការរង់ចាំការសម្រេចលើបណ្តឹងឧទ្ធរណ៍ មិនសមហេតុផលឡើយ គឺមានតម្លៃស្មើនឹងការបំពានឆន្ទានុសិទ្ធិតុលាការ និងបានបំពេញតាមបទដ្ឋានស្តីពីការពិនិត្យឡើងវិញលើបណ្តឹងឧទ្ធរណ៍ដោយអង្គបុរេជំនុំជម្រះ ។

## គ. ការបដិសេធសំណើដោយផ្អែកលើមូលដ្ឋាននៃភាពមិនទាន់ពេលវេលាគឺជាការបំពេញទៅតាមលក្ខខណ្ឌតម្រូវនៃបទដ្ឋានស្តីពីការពិនិត្យឡើងវិញលើបណ្តឹងឧទ្ធរណ៍

### *i. ដីកាសំរេចបានផ្អែកយ៉ាងជាក់ស្តែងទៅលើសេចក្តីសន្និដ្ឋានខាងអង្គហេតុដែលមិនត្រឹមត្រូវ*

៣០. សំណើនានាដែលត្រូវបានដាក់ជូនជាថ្មីឡើងវិញដើម្បីសុំឱ្យ សចស ពិនិត្យពិចារណា កាលពីថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០១១ គឺចំនួនបីថ្ងៃគិតតាមប្រក្រតីទិន បន្ទាប់ពីការបដិសេធលើកទីមួយ ។ ក្នុងដីកាសំរេចនោះថ្លែងថា សចស មិនអាចអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនបានតាមវិធាន៣៩.៤ នៃវិធានផ្ទៃក្នុង ដើម្បីទទួលស្គាល់អំពីសុពលភាពនៃសំណើសុំដែលបានដាក់ជាថ្មីឡើងវិញនោះទេ ពីព្រោះសហព្រះរាជអាជ្ញាអន្តរជាតិ "បានមានពេលវេលារហូតដល់ទៅជិតមួយឆ្នាំពេញដើម្បីធ្វើការសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរផ្សេងៗ ប៉ុន្តែ*បានសំរេចចិត្តថាមិនធ្វើសំណើសុំដូចនេះទេ*រហូតមកទល់ពេលដែល សចស បិទកិច្ចស៊ើបសួរអនុលោមតាមវិធាន៦៦.១ នៃវិធានផ្ទៃក្នុង[41]" ។ សចស សូមស្នើយោបល់ថា សហព្រះរាអាជ្ញាអន្តរជាតិដែលបានអនុវត្តនូវជម្រើសមួយមិនដាក់ជូននូវសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរនានា ដោយសារ "ការស៊ើបសួរក្នុងសំណុំរឿងលេខ០០៣បានកំពុងតែបន្តធ្វើយ៉ាងហោចណាស់ក៏ចាប់តាំងពីពេលចេញដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១០មកដែរ"[42]។ ការរកឃើញនេះ បានផ្អែកលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានខុសខាងអង្គហេតុយ៉ាងជាក់ស្តែង ។

---

[41] **D26**, ដីកាសម្រេច, កំណត់សម្គាល់*ខាងដើម*លេខ២ ត្រង់កថាខណ្ឌទី ៦.ខ (សង្កត់ន័យបន្ថែមដោយ*អក្សរទ្រេត*) ។

[42] *ដដែលដូចមុន*, ត្រង់កថាខណ្ឌទី ៦.ខ ។

៣១. ដូចដែលបានលើកនៅក្នុងផ្នែកទី “២. ប្រវត្តិនៃនីតិវិធី” ខាងលើ សហព្រះរាជអាជ្ញាអន្តរជាតិបានទទួលសេចក្តីជូនដំណឹងអំពីសកម្មភាពនៃការស៊ើបសួរដែលបាននឹងកំពុងតែអនុវត្តដោយ សចស នៅមុនថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១។ សហចៅក្រមស៊ើបអង្កេតបានផ្សព្វផ្សាយភស្តុតាងមួយចំនួនរបស់ខ្លួនដែលនៅក្នុងសំណុំរឿងនៅក្នុងថ្ងៃនោះ បានផ្តល់នូវសេចក្តីជូនដំណឹងមួយបន្ថែមទៀតនៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០១១ និងបានធ្វើការបិទផ្សាយជាច្រើននៅចន្លោះថ្ងៃទី២២ និងថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១១។ ការជូនដំណឹងចុងក្រោយនេះដែលបានចាប់ផ្តើមកាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១នោះ រួមមានរបាយការណ៍នានាស្តីពីការចុះស៊ើបអង្កេតដល់ទីកន្លែង ដែលក្នុងនោះពួកមន្ត្រីអ្នកស៊ើបអង្កេតដល់មូលដ្ឋានបានស្គាល់អត្តសញ្ញាណនៃសាក្សីសំខាន់ៗ ដែលពួកគាត់មិនត្រូវបានអនុញ្ញាតឱ្យធ្វើសម្ភាសន៍ឡើយ[43]។ ដីកាចាត់ឱ្យស៊ើបសួរជំនួសមួយដែលជាដីកាចាត់ឱ្យស៊ើបសួរជំនួសតែមួយគត់ដែលបានចេញដោយ សចស នៅក្នុងសំណុំរឿងលេខ០០៣ មិនត្រូវបានជូនដំណឹងឱ្យសហព្រះរាជអាជ្ញាបានដឹងទេ រហូតមកទល់នឹងថ្ងៃទី១០ ខែមេសា ឆ្នាំ២០១១ គឺរយៈពេល៣៣៥ថ្ងៃគិតតាមប្រក្រតីទិន បន្ទាប់ពីការចេញដីកានេះ ។ ការប្រកាសផ្សាយឱ្យដឹងអំពីដីកាចាត់ឱ្យស៊ើបសួរជំនួសនេះបានបញ្ជាក់ថា ពួកមន្ត្រីអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតមិនទាំងបានបំពេញចប់សព្វគ្រប់នូវការស៊ើបសួរដែលមានកំរិត ដែលលោកចៅក្រម Lemonde បានចាត់ឱ្យពួកគេទទួលបន្ទុកធ្វើកាលពីដំបូងទីនោះផងទេ[44]។ តារាងនៃការវិភាគមួយស្តីពីការយឺតយ៉ាវក្នុងការធ្វើសេចក្តីជូនដំណឹងដោយ សចស អំពីការដាក់ជូននូវឯកសារ និងសេចក្តីសំរេចនានាដែលជាគន្លឹះទាក់ទងនឹងសំណុំរឿងលេខ ០០៣ ត្រូវបានផ្តល់ជូននៅក្នុងឧបម្ព័ន្ធ ១។

៣២. ជាលទ្ធផល អំពីការខកខានមិនបានជូនដំណឹងរបស់ សចស ដល់សហព្រះរាជអាជ្ញា អំពីការស៊ើបសួរដែលខ្លួនបានបើកធ្វើ រហូតទល់ជិតដល់ពេលត្រូវធ្វើសេចក្តីជូនដំណឹងរបស់ខ្លួនអនុលោមតាមវិធាន ៦៦.១ នៃវិធានផ្ទៃក្នុងនោះ សហព្រះរាជអាជ្ញាអន្តរជាតិបានមានលទ្ធភាពអាចក្នុងការតាម

[43] **D2/22**, ថ្ងៃទី២៩ ធ្នូ ២០១០, លេខERN 00634138-76 ត្រង់លេខERN 00634139 និង **D2/23**, ថ្ងៃទី៣០ ធ្នូ ២០១០, លេខERN 00644146-84 ត្រង់លេខERN 00644148, 154 ។

[44] **D2**, ដីកាចាត់ឱ្យស៊ើបសួរជំនួស, កំណត់សម្គាល់*ខាងលើ* លេខ៦ (ស្នើសុំឱ្យអ្នកស៊ើបអង្កេតរបស់ កសចស ស្តាប់ចម្លើយ “សាក្សីណាក៏ដោយដែលអាចផ្តល់ព័ត៌មានពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មនានាដែលនៅក្រោមការស៊ើបសួរ”) ។

ដានកិច្ចស៊ើបសួរដូចដែលបានដំណើរការរួចមកហើយ ហើយនិង ក្នុងការធ្វើសេចក្តីសំរេចមួយដែលមានបញ្ជាក់មូលហេតុអំពីភាពចាំបាច់ត្រូវធ្វើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរជាបន្ថែមទៀត នៅមុនសេចក្តីជូនដំណឹងថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ របស់ សចស ថាខ្លួនបានពិនិត្យពិចារណាថាកិច្ចស៊ើបសួរត្រូវបានបិទ ។ នៅពេលនោះ សហព្រះរាជអាជ្ញាអន្តរជាតិបានចាត់វិធានការជាបន្ទាន់ដើម្បីធ្វើការវាយតម្លៃអំពីកិច្ចស៊ើបសួរតើធ្វើបានដល់ណាហើយ ដោយអនុលោមតាមការទទួលខុសត្រូវរបស់ខ្លួនផ្អែកតាមវិធាន៥៥.១០ និង៦៦.១ នៃវិធានផ្ទៃក្នុង ហើយបានណែនាំថាសំណើសុំនានាត្រូវតែបានត្រៀមរៀបចំ និងបានដាក់ជូនរួចជាស្រេច ។ សំណើទាំងនោះត្រូវបានដាក់ទៅ កសចស ទាន់ពេលវេលាកាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ គ្រាន់តែក្នុងរយៈពេល៨ថ្ងៃតាមប្រក្រតីទិនបន្ទាប់ពីការបង្ហាញជូនរបស់ សចស ដល់សហព្រះរាជអាជ្ញាអន្តរជាតិ នូវដីកាចាត់ឱ្យស៊ើបសួរជំនួសតែមួយគត់ប៉ុណ្ណោះដែលបានចេញនៅក្នុងសំណុំរឿងលេខ០០៣។ ហេតុនេះ គឺដីកានេះបានពោលអះអាងដោយមិនត្រឹមត្រូវច្បាស់ក្រឡែតដែលថាសហព្រះរាជអាជ្ញាអន្តរជាតិ "បានមានពេលរហូតដល់ជិតមួយឆ្នាំពេញសំរាប់ធ្វើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ"[45]។

៣៣. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាអន្តរជាតិសូមគោរពជូនថា ការបដិសេធសំណើទាំងនេះដោយផ្អែកលើមូលដ្ឋាននៃការកំណត់ពេលវេលារបស់ពួកគេ គឺជាសេក្តីសន្និដ្ឋានដោយមិនត្រឹមត្រូវយ៉ាងជាក់ស្តែងលើអង្គហេតុដែលបំពេញគ្រាប់តាមបទដ្ឋាន ស្តីពីការពិនិត្យឡើងវិញលើបណ្តឹងឧទ្ធរណ៍ដោយអង្គបុរេជំនុំជម្រះ ។

*ii. ដីកាសំរេចនេះគឺមិនត្រឹមត្រូវ ហើយទុកដូចជាការរំលោភលើឆន្ទានុសិទ្ធិរបស់តុលាការ*

៣៤. ការបដិសេធលើសំណើដោយផ្អែកលើមូលដ្ឋានថា សំណើទាំងនេះត្រូវបានដាក់ជូនក្រៅពីរយៈពេល១៥ថ្ងៃដែលបានចែងកំណត់ដោយវិធាន៦៦.១ នៃវិធានផ្ទៃក្នុង[46] គឺមិនត្រឹមត្រូវតាមនីតិវិធីទេ។ អង្គបុរេជំនុំជម្រះបានទទួលស្គាល់ថា ភាគីនានាមានសិទ្ធិទទួលបាននូវភាពប្រាកដប្រជានៅក្នុង

---

[45] **D26**, ដីកាសម្រេច, កំណត់សម្គាល់*ខាងលើ* លេខ២ ត្រង់កថាខណ្ឌទី ៦.ខ ។

[46] *ដដែលដូចមុន*, ត្រង់កថាខណ្ឌទី ៦.ក ។

"ការរំពឹងទុកថាបញ្ហាណាមួយនឹងត្រូវបានដោះស្រាយតាមរបៀបដែលអាចឲ្យព្យាករណ៍ទុកជាមុនបានដោយត្រឹមត្រូវ និងមានការកំណត់ច្បាស់លាស់[47] ។ សហព្រះរាជអាជ្ញាមានការរំពឹងទុកដោយស្របច្បាប់ថា ដោយបានចាត់វិធានការណ៍ក្នុងការបញ្ជូនទៅដើម្បីឲ្យកែតម្រូវលើកង្វះខាតផ្នែកបច្ចេកទេសកំរិតខ្ពស់ដែលអាចឲ្យធ្វើការតវ៉ាបាននៅក្នុងសំណើទាំងនេះ បន្ទាប់ពីការបដិសេធលើកទី១" សចស គួរតែបានអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីពន្យារពេលបន្ថែមពីលើពេលកំណត់ជាធរមានចំនួន១៥ថ្ងៃ ដូចដែលមានចែងនៅក្នុងវិធាន៦៦.១ នៃវិធានផ្ទៃក្នុង។ ការរំពឹងទុកនេះត្រូវបានជួយពង្រឹងដោយការជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិដល់ សចស អំពីចេតនារបស់ខ្លួនដែលចង់ប្តឹងឧទ្ធរណ៍ចំពោះការបកស្រាយច្បាប់ផ្ទាល់តែម្តង ដែលជាលទ្ធផល គឺបណ្តាលឲ្យសហព្រះរាជអាជ្ញាន្តរជាតិមិនអាចមានលទ្ធភាពអនុវត្តតាមរយៈពេល១៥ថ្ងៃនេះបាន។

៣៥. សហព្រះរាជអាជ្ញាអន្តរជាតិ សូមលើកឡើងជាយោបល់ថា ការខកខានរបស់ដីកាសំរេចក្នុងការបំពេញបានទៅតាមការរំពឹងទុកដែលស្របតាមច្បាប់នេះ តាមនីតិវិធីគឺវាមិនត្រឹមត្រូវទេ ហើយចាត់ទុកដូចជាការរំលោភលើឆន្ទានុសិទ្ធិរបស់តុលាការ ក្នុងការបំពេញទៅតាមបទដ្ឋាន ស្តីពីការពិនិត្យឡើងវិញលើបណ្តឹងឧទ្ធរណ៍ដោយអង្គបុរេជំនុំជម្រះ។

### *iii. ដីកាសម្រេចគឺមិនសមហេតុសមផល ហើយទុកដូចជាការរំលោភលើឆន្ទានុសិទ្ធិរបស់តុលាការ*

៣៦. ការបដិសេធលើសំណើនានា ដោយផ្អែកលើមូលដ្ឋានដែលចង់ឲ្យដំណើរការនិតិវិធីបានឆាប់រហ័សនោះ[48] គឺជាការមិនសមហេតុផលឡើយ ។ ក្នុងដីកាសំរេចបានបញ្ជាក់ថា ការអនុញ្ញាតឲ្យមានភាពបត់បែននៅក្នុងការកំណត់ពេល១៥ថ្ងៃ ដែលចែងនៅក្នុងវិធាន៦៦.១នោះ គឺជាការ "រំលោភទៅលើ

[47] **D250/3/2/1/5**, សាលដីកាលើបណ្តឹងឧទ្ធរណ៍លើដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតលេខ D250/3/3 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ និងដីកាសម្រេចលេខ D250/3/2 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ លើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, លេខERN 00507519-67 ត្រង់កថាខណ្ឌទី ១៣ ។

[48] **D26**, ដីកាសម្រេច, កំណត់សម្គាល់*ខាងលើ* លេខ២ ត្រង់កថាខណ្ឌទី ៦.ក ។

គោលការណ៍ជាមូលដ្ឋាន ស្តីពីដំណើរការនីតិវិធី"[49] ដែលទាក់ទងនឹងការចាំបាច់ឲ្យមានភាពឆាប់រហ័ស ដូចមានចែងនៅក្នុងវិធាន២១.៤ នៃវិធានផ្ទៃក្នុង។សូមជូនដោយគោរពថាការវែកញែកហេតុផលនេះ គឺពោលអះអាងអំពីការជំរុញទៅមុខនូវគោលការណ៍ជាមូលដ្ឋានមួយស្តីពីដំណើរការនីតិវិធី នៅក្នុងពេលដែលដីកាសំរេចទាំងមូលដែលមានការចោទសួរដេញដោល បានមានផលប៉ះពាល់ដ៏មានគ្រោះថ្នាក់ទៅដល់គោលការណ៍នានាជារួមដែលតម្រូវឲ្យមាន ដែលបានដំកល់ទុកនៅក្នុងវិធាន២១ និងនៅក្នុង អនុវិធាន២១.(ក)-(ឃ) នៃវិធានផ្ទៃក្នុង ។ ផលប្រយោជន៍របស់ជនសង្ស័យខ្លួនឯងផ្ទាល់របស់ជនរងគ្រោះ របស់អនាគតដើមបណ្តឹងរដ្ឋប្បវេណីយនានា ហើយនិងរបស់អយ្យការ ត្រូវបានខូចខាតយ៉ាងខ្លាំងដោយសារការស៊ើបសួរមួយដែលជាក់ស្តែងមិនត្រូវបានបំពេញចប់សព្វគ្រប់នេះ។ ដោយការយល់ឃើញនៅក្នុងបរិបទនៃកិច្ចស៊ើបសួរមួយដែលមានរយៈពេលជាង១៤ខែ លើមូលដ្ឋានឧក្រិដ្ឋកម្មមួយដែលមានលក្ខណៈស្មុគស្មាញ ដែលមានការកំហិតឲ្យអនុវត្តតាមឲ្យបានក្នុងរយៈពេល១៥ថ្ងៃ មិនអាចត្រូវបានយល់ឃើញដោយសមហេតុសមផលថាគឺជាការប៉ះទង្គិចដ៏ធ្ងន់ធ្ងរដល់ភាពឆាប់រហ័សនៃដំណើរការនីតិវិធីនោះឡើយ។ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បញ្ចូលនៅក្នុងឯកសាររបស់ខ្លួន ដែលបានដាក់ជូនកាលពីមុនៗមកដោយយោងទៅលើរឿងនេះ[50]។ ដីកាសំរេចមិនបានពិចារណា ឬមួយក៏ព្យាយាមដើម្បីធ្វើការថ្លឹងថ្លែងនូវគោលការណ៍ទាំងនេះ ក្នុងការបដិសេធលើសំណើនានាដោយសារមូលហេតុមិនទាន់ពេលវេលានោះដែរ។

៣៧. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាអន្តរជាតិសូមគោរពជូនថា ការបដិសេធលើសំណើទាំងនេះដោយផ្អែកលើមូលហេតុពេលវេលា គឺជាការមិនសមហេតុសមផលឡើយ ហើយដែលចាត់ទុកដូចជាការរំលោភមួយទៅលើឆន្ទានុសិទ្ធិរបស់តុលាការ ដែលបំពេញគ្រប់ទៅតាមលក្ខខណ្ឌតម្រូវនៃបទដ្ឋានស្តីពីការពិនិត្យឡើងវិញលើបណ្តឹងឧទ្ធរណ៍ដោយអង្គបុរេជំនុំជម្រះ។

[49] *ដដែលដូចមុន* ។

[50] **D20/4/1**, បណ្តឹងឧទ្ធរណ៍ទីមួយ, កំណត់សម្គាល់*ខាងលើ* លេខ៣ ត្រង់កថាខណ្ឌទី ៣៩-៧៤ ។

## ឃ. ការបដិសេធសំណើសុំដោយសារមិនមានយុត្តាធិការចំពោះបុគ្គលស្របទៅនឹងបទដ្ឋានសម្រាប់ពិនិត្យលើបណ្តឹងឧទ្ធរណ៍

៣៨. មូលដ្ឋានទីបួន និងទីប្រាំសម្រាប់ការបដិសេធសំណើសុំនោះទាក់ទិននឹងយុត្តិសាស្ត្រចំពោះបុគ្គលនៃ អ.វ.ត.ក។ ដីកាសម្រេចនោះបានអះអាងថា៖

> *"វានៅមិនទាន់មានភាពច្បាស់លាស់ទេថា សហព្រះរាជអាជ្ញាអន្តរជាតិបានធ្វើការពិចារណាល្អិតល្អន់គ្រប់គ្រាន់អំពីយុត្តាធិការជាមូលដ្ឋាន ដែលបញ្ញត្តិនៅក្នុងមាត្រា ២ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក គឺចំពោះលក្ខខណ្ឌដែលថា ជនសង្ស័យនៅក្នុងសំណុំរឿង ០០៣ ត្រូវតែជា "មេដឹកនាំជាន់ខ្ពស់" នៃរបបកម្ពុជាប្រជាធិបតេយ្យ ឬជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងសម័យនោះ"*[51]

៣៩. ដើម្បីជាការធ្វើយុត្តិកម្មចំពោះការបដិសេធសំណើសុំដោយផ្អែកលើមូលដ្ឋាននៃយុត្តាធិការចំពោះបុគ្គលនោះ ស.ច.ស បានអះអាងថា ការចាត់ទុកជនសង្ស័យ មាស មុត និង ស៊ូ ម៉េត ជាមេដឹកនាំជាន់ខ្ពស់នោះជា "ការលើកឡើងដោយមិនសមហេតុសមផលច្បាស់លាស់"[52]។ នៅក្នុងករណីនេះ ស.ច.ស ទំនងជាបានកំណត់នូវសំអាងហេតុមួយស្តីពីវិសាលភាពនៃយុត្តាធិការចំពោះបុគ្គល "បន្ទាប់ពីបានធ្វើការវិភាគយ៉ាងលម្អិតលើភស្តុតាងដែលមាន"[53] តែបានផ្តល់អត្ថន័យសំខាន់តែពីរបន្ទាត់ប៉ុណ្ណោះទាក់ទិននឹងសេចក្តីសន្និដ្ឋានបែបទូលំទូលាយនេះ ដោយផ្អែកលើអង្គហេតុដែលថាជនសង្ស័យគឺជាមេបញ្ជាការកងពលធំដែល "ចំនួនកងពលធំមិនតិចជាង ៩ (បន្ថែម កងវរសេនាធំស្វយ័តចំនួន ៣)"[54]។

៤០. ដោយសារសម្ភារៈឯកសារស៊ើបអង្កេតមិនមានក្នុងសំណុំរឿង និង ដោយពិចារណាទៅលើដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ សហព្រះរាជអាជ្ញាអន្តរជាតិយល់ឃើញថា វាជាការឆាប់រហ័សពេកដែលត្រូវធ្វើសេចក្តីសន្និដ្ឋានពេញលេញ ទៅលើបញ្ហានេះថាតើជនសង្ស័យមានគុណវុឌ្ឍិ ជា

---

[51] ឯកសារលេខ **D26** ដីកាសំរេច , កំណត់សំគាល់លេខ២ *ខាងលើ* ត្រង់កថាខណ្ឌទី៦(គ)។

[52] *ដូចគ្នានឹងខាងលើ*។

[53] *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី៦(ឃ)។

[54] ឯកសារលេខ **D26** ដីកាសំរេច , កំណត់សំគាល់លេខ២ *ខាងលើ* ត្រង់កថាខណ្ឌទី៦(ឃ)។

មេដឹកនាំជាន់ខ្ពស់ ឬអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះ "ឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក"[55]។ ផ្ទុយទៅវិញ សហព្រះរាជអាជ្ញាអន្តរជាតិនឹងបង្ហាញថា ការបដិសេធសំណើសុំដោយសំអាងថាមិនមានយុត្តាធិការចំពោះបុគ្គលគឺការមិនសមហេតុផលទេ និងដើម្បីឲ្យកាន់តែច្បាស់គឺថា យុត្តាធិការចំពោះបុគ្គលនេះទំនងជាផ្អែកលើកំហុសឆ្គងផ្នែកច្បាប់ និង សំអាងហេតុដែលមានកំហុសឆ្គងច្បាស់លាស់។ ផ្ទុយទៅវិញ គួរមានការពិចារណាលើចំពោះទាំងនេះផង។

*i. ដីកាសម្រេចគឺមិនយុត្តិធម៌ និងមានភាពមិនសមហេតុផលផង និង ជាការរំលោភបំពានលើអំណាចឆន្ទានុសិទ្ធិរបស់តុលាការផង*

៤១. ដីកាសម្រេចបានបង្ហាញពីភាពស្រពិចស្រពិលនូវវិធីសាស្ត្រដែល ក.ស.ច.ស យកមកប្រើដើម្បីកំណត់អត្ថន័យនៃពាក្យថា "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដោយផ្អែកលើសេចក្តីសម្រេចជាសារវ័ន្តស្តីពីសេចក្តីណែនាំក្នុងការកិច្ចស៊ើបសួរ និងការប្រើប្រាស់ធនធានតុលាការសម្រាប់កិច្ចស៊ើបសួរដែលសមរម្យដោយមិនបានដល់សំអាងច្បាស់លាស់[56]។ ជាពិសេស ដីកាសម្រេចអះអាងថា ការបន្តការបំពេញកិច្ចស៊ើបសួរបន្ថែមតាមសំណើសុំទាំងនោះ "នឹងមិនធ្វើឲ្យមានការផ្លាស់ប្តូរការវិភាគរបស់យើងអំពីបញ្ហានោះទេ ប៉ុន្តែវានឹងបណ្តាលឲ្យមានការប្រើប្រាស់ធនធានតុលាការក្នុងលក្ខណៈដែលមិនចាំបាច់ និងមិនទទួលខុសត្រូវ"[57]។ ការអះអាងបែបនេះបានបង្ហាញថា ក.ស.ច.ស បានធ្វើការសន្និដ្ឋានមួយរួចទៅហើយ ដោយផ្អែកលើ "បញ្ហាយុត្តាធិការជាមូលដ្ឋាន" ក្នុងសំណុំរឿង ០០៣ ដោយមិនបាន (ក).បើកកិច្ចស៊ើបសួរដោយប្រុងប្រយ័ត្នចំពោះឋានានុក្រម ឬ ឋានៈរបស់ជនសង្ស័យ ឬ កេរ្តិ៍ឈ្មោះអាក្រក់ ឬ ភាពធ្ងន់ធ្ងរ នៃការប្រព្រឹត្តឧក្រិដ្ឋកម្មដែលពួកគេត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនោះទេ[58] (សូមមើលពីកថាខណ្ឌ ៦៩ ដល់

---

[55] វិធាន៥៥.១ នៃវិធានផ្ទៃក្នុង។

[56] ឯកសារលេខ **D26** ដីកាសំរេច , កំណត់សំគាល់លេខ២ *ខាងលើ* ត្រង់កថាខណ្ឌទី៦(ឃ)។

[57] *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី៦(ឃ)។

[58] សហព្រះរាជអជ្ញាអន្តរជាតិបានឡើកឡើងរួចហើយកាលពីមុនដោយលំអិតអំពីការព្រួយបារម្ភនេះជូន សចស ៖ *សូមអាន* ឯកសារ លេខ **D17** សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរលើកទី១, កំណត់សំគាល់លេខ១៦ *ខាងលើ,* ត្រង់កថាខណ្ឌទី៤-៥)។

កថាខណ្ឌ ៨០ ខាងក្រោម) ឬ (ខ).ចេញសេចក្ដីសម្រេចដែលមានសំអាងហេតុត្រឹមត្រូវ ទាក់ទិននឹងយុត្តាធិការប្រឆាំងនឹងអ្វីដែលជនត្រូវចោទអាចអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការប្ដឹងឧទ្ធរណ៍ អនុលោមតាមវិធាន ៧៤(៣)(ក) ឬ អ្វីដែលសហព្រះរាជអាជ្ញាអាចនឹងប្ដឹងឧទ្ធរណ៍បានតាមវិធាន ៧៤(២) នោះទេ។

៤២. អ.ប.ជ ធ្លាប់បានចេញសេចក្ដីសម្រេចពីមុនរួចមកហើយគឺថា បញ្ហាយុត្តាធិការជាបញ្ហាសារវ័ន្ត[59]។ សហព្រះរាជអាជ្ញាអន្តរជាតិធ្លាប់បានជូនដំណឹងដល់ ក.ស.ច.ស រួចមកហើយគឺថា សេចក្ដីសម្រេចទាំងឡាយណាដែលច្រានចោលសំណើសុំបើកកិច្ចស៊ើបសួរ ឬ បញ្ចប់កិច្ចស៊ើបសួរដោយផ្អែកលើសេចក្ដីសន្និដ្ឋានទាក់ទិននឹងបញ្ហាយុត្តាធិការនោះ ត្រូវតែជូនដំណឹង នឹង ផ្ដល់ឱកាសឱ្យសហព្រះរាជអាជ្ញាអន្តរជាតិក្នុងការដាក់ជូននូវសារណាពិស្ដារបាន[60]។ នៅក្នុងបទសម្ភាសន៍សារព័ត៌មានជាលាយលក្ខណ៍អក្សរមួយទៅកាន់សារព័ត៌មានកាលពីថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១១ ចៅក្រម Siegfiend Blunk បានថ្លែងថា ការិយាល័យរបស់គាត់បាន “ធ្វើការវិភាគស៊ីជម្រៅចំពោះប្រភពដើម និងអត្ថន័យនៃពាក្យថា “មេដឹកនាំជាន់ខ្ពស់” និង បានបង្កើតនូវលក្ខណៈវិនិច្ឆ័យមួយចំនួន ដោយផ្អែកលើច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ ...”[61]។ ចៅក្រម Blunk បន្ថែមទៀតថា លក្ខណៈវិនិច្ឆ័យទាំងនោះនឹងមិនអាចផ្សព្វផ្សាយជាសាធារណៈមុនពេលចេញដីកាដំណោះស្រាយបានទេ[62]។ សេចក្ដីថ្លែងការណ៍នេះបញ្ជាក់ថា ស.ច.ស បានចេញសេចក្ដីសម្រេចតាមការសន្មតមួយទៅលើយុត្តាធិការចំពោះបុគ្គលរួចទៅហើយ ដោយមិនបានផ្ដល់មូលហេតុសម្រាប់សេចក្ដីសម្រេចនោះដល់សហព្រះរាជអាជ្ញាអន្តរជាតិទេ ទោះបីជាលក្ខណៈសម្ងាត់ក៏ដោយ ឬក៏មិនបានផ្ដល់ឱកាសដល់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងការដាក់ជូននូវសារណាជាលាយលក្ខណ៍អក្សរដែរ។

---

[59] ឯកសារលេខ **D427/3/15** សំណុំរឿងលេខ០០២: សាលដីកាសំរេចលើបណ្ដឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី១៥ កុម្ភៈ ២០១១, ERN 00644462-571 ត្រង់ទំព័រ៣២ ។

[60] ឯកសារលេខ **D17** សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរលើកទី១, កំណត់សំគាល់លេខ១៦ *ខាងលើ* ត្រង់កថាខណ្ឌទី៩។

[61] “ចៅក្រមតុលាការខ្មែរក្រហម និយាយអំពីភាពចំរូងចម្រះនៅក្នុងតុលាការ”, កាសែតភ្នំពេញប៉ុស្ដិ៍, ចុះថ្ងៃទី១៨ សីហា ២០១១, ត្រង់ទំព័រ ៦។

[62] *ដូចគ្នានឹងខាងលើ*។

៤៣. ផ្អែកលើមូលដ្ឋាននេះ សហព្រះរាជអាជ្ញាអន្តរជាតិសូមសន្និដ្ឋានថា ដីកាសម្រេចមិនអាចត្រូវបានចាត់ទុកថាបានផ្តល់នូវសំអាងហេតុគ្រប់គ្រាន់តាមការតម្រូវរបស់វិធាន ៥៥(១០) ហើយដីកានេះក៏មិនបានផ្តល់សិទ្ធិដល់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងផ្តល់សំអាងហេតុតបវិញទេ។ អ.ប.ជ ធ្លាប់បានសម្រេចរួចមកហើយនូវការខកខានរបស់ ស.ច.ស មិនបានផ្តល់នូវ*សំអាងហេតុ* ថាជាកំហុសឆ្គងផ្នែកច្បាប់ដែលអាចពិនិត្យឡើងវិញបាន[63]។ សហព្រះរាជអាជ្ញាអន្តរជាតិសូមសន្និដ្ឋានថា ការខកខានរបស់ ស.ច.ស មិនបានផ្តល់*សំអាងហេតុគ្រប់គ្រាន់* ចំពោះសេចក្តីសម្រាប់បែបសន្ធតរបស់ខ្លួនទៅលើយុត្តាធិការចំពោះមនុស្សនៅក្នុងដីកាសម្រេចនេះ ត្រូវបានចាត់ទុកយ៉ាងត្រឹមត្រូវថាមិនមានហេតុផលសមរម្យទេ និងជាការរំលោភបំពានដល់អំណាចឆន្ទានុសិទ្ធិទៀតផង។ ការខកខានមិនបានផ្តល់សិទ្ធិដល់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងការបញ្ចេញយោបល់ជាភាពអយុត្តិធម៌ផ្នែកនីតិវិធី ហើយក៏ត្រូវបានចាត់ទុកថាជាការរំលោភបំពានដល់អំណាចឆន្ទានុសិទ្ធិរបស់តុលាការដែរ។ ហេតុនេះ ដីកាសម្រេចនេះស្របនឹងបទដ្ឋានស្តីពីការពិនិត្យលើបណ្តឹងឧទ្ធរណ៍ដោយអង្គបុរេជំនុំជម្រះ។

*ii. ដីកាសម្រេចទំនងជាផ្អែកលើការបកស្រាយមិនត្រឹមត្រូវទៅច្បាប់ដែលពាក់ព័ន្ធ*

៤៤. ដើម្បីឱ្យកាន់តែច្បាស់គឺថា សេចក្តីសម្រេចតាមការសន្មតរបស់ ក.ស.ច.ស ទៅលើយុត្តាធិការចំពោះបុគ្គល ទំនងជាផ្អែកលើការបកស្រាយមិនបានត្រឹមត្រូវទៅលើបញ្ញត្តិដែលពាក់ព័ន្ធ ជាពិសេសគឺកិច្ចព្រមព្រៀង (ដែលជាសន្ធិសញ្ញាអន្តរជាតិ) និងលិខិតុបករណ៍មួយដែលត្រូវបានអនុម័តដោយភាគីមួយក្នុងចំណោមភាគីនៃសន្ធិសញ្ញានោះគឺ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ សហព្រះរាជអាជ្ញាអន្តរជាតិសូមសន្និដ្ឋានថា កំហុសឆ្គងផ្នែកច្បាប់ទាំងនេះគឺជាភស្តុតាងដែលបង្ហាញថា ដីកាសម្រេច (ក).ជំទាស់ដោយមិនត្រឹមត្រូវចំពោះដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដោយខកខានមិនបានបញ្ជាក់ឱ្យច្បាស់ពីពាក្យពីរ ("មេដឹកនាំជាន់ខ្ពស់" ឬ "អ្នកទទួលខុសត្រូវខ្ពស់

[63] ឯកសារលេខ **D365/2/10** សាលដីកាសំរេចលើបណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសំរេចរបស់ **សចស លើ** សំណើសុំដាក់បញ្ចូលសំភារៈភស្តុតាងនៅក្នុងសំណុំរឿង ដែលនឹងជួយបង្ហាញសក្ខីកម្មអំពីការដឹងរបស់ជនត្រូវចោទអំពីឧក្រិដ្ឋកម្មនានា, ចុះថ្ងៃទី១៥ មិថុនា ២០១១, ERN 00526872–82 ត្រង់កថាខណ្ឌទី២៦។

បំផុត") ដែលគួរយកមកអនុវត្តចំពោះជនសង្ស័យ[64] (ខ).អនុវត្តដោយមិនត្រឹមត្រូវនូវវិធាន ៥៥ (១) ដោយបដិសេធសំណើសុំ[65] និង (គ). ពិចារណាមិនត្រឹមត្រូវ នូវឋានានុក្រម និង ឋានៈ ឬកេរ្តិ៍ឈ្មោះអាក្រក់ ឬ ភាពធ្ងន់ធ្ងរ នៃការប្រព្រឹត្តឧក្រិដ្ឋកម្មដែលចោទប្រកាន់ ដោយរំលោភដល់ច្បាប់ជាធរមាន និង បទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធ[66]។

<u>ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមិនអាចត្រូវបានជំទាស់ដោយផ្អែកលើមូលដ្ឋានថា ដីកានេះខកខានមិនបានកំណត់ឱ្យបានច្បាស់លាស់ថាតើ ជនសង្ស័យជា "មេដឹកនាំជាន់ខ្ពស់" ឬ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នោះទេ</u>

៤៥. វិធាន ៥៣(១) មិនបានតម្រូវឱ្យសហព្រះរាជអាជ្ញា "ធ្វើការសម្រេចចិត្ត"[67] ជាផ្នែកមួយនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះទេ។ ចំណុចនេះស៊ីសង្វាក់ទៅនឹងបញ្ញត្តិទាក់ទិននឹងយុត្តាធិការចំពោះបុគ្គលនៅក្នុងច្បាប់ជាធរមាន ដែលអនុម័តយកពាក្យពីរដែលមានន័យដាច់ស្រឡះពីគ្នា ("មេដឹកនាំជាន់ខ្ពស់" ឬ "អ្នកទទួលខុសត្រូវខ្ពស់បំផុត")។ ការសម្រេចចិត្តពីរបៀបដែលបុគ្គលម្នាក់ដែលបានបញ្ចេញឈ្មោះអាចស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ជាបញ្ហាមួយសម្រាប់អំណាចឆន្ទានុសិទ្ធិផ្នែកតុលាការដែលមានរចនាសម្ព័ន្ធរបស់ ស.ច.ស ត្រូវបានអនុវត្តទៅតាមច្បាប់ជាធរមាន ដោយផ្អែកលើមូលដ្ឋាននៃកិច្ចស៊ើបសួរពេញលេញ និង ដោយមិនលម្អៀង និងបានកំណត់ឱ្យមានការសម្រេចចិត្តជាចុងក្រោយដោយអង្គជំនុំជម្រះសាលាដំបូង ទៅតាមវិធានដែលអនុម័តចំពោះអញ្ញត្រកម្ម[68]។

[64] ឯកសារលេខ **D26** ដីកាសំរេច , កំណត់សំគាល់លេខ២ *ខាងលើ* ត្រង់កថាខណ្ឌទី៦(គ)។

[65] *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី៦(ឃ)។

[66] *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី៦(គ)។

[67] *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី៦(គ)។

[68] វិធាន៨៩ ១ នៃវិធានផ្ទៃក្នុង។

<u>វិធាន ៥៥(១) បានកំណត់កាតព្វកិច្ចដល់ ក.ស.ច.ស ក្នុងការបើកកិច្ចស៊ើបសួរទៅលើឧក្រិដ្ឋកម្ម នៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក។ វិធាននេះមិនបានកំហិតពីវិសាលភាពនៃកិច្ចស៊ើបសួរទៅលើ បុគ្គលដោយឡែកណាម្នាក់ទេ</u>

៤៦. ដីកាសម្រេចបានដកស្រង់វិធាន ៥៥(១) *ដែលអនុញ្ញាត*ឱ្យមានការស៊ើបអង្កេតត្រឹមតែ "នៅក្នុង យុត្តាធិការរបស់ អ.វ.ត.ក" ប៉ុណ្ណោះ[69]។ សហព្រះរាជអាជ្ញាអន្តរជាតិសូមសន្និដ្ឋានថា នេះជាការ អនុវត្តខុសចំពោះវិធាន ៥៥(១) ដែលមិនបានអនុញ្ញាតទេ តែ*បង្គាប់*ក.ស.ច.ស ឱ្យបើកកិច្ចស៊ើប សួរទៅលើ "*ឧក្រិដ្ឋកម្ម*ដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក"។ ដោយផ្អែកលើកិច្ចស៊ើបសួរ ចំពោះឧក្រិដ្ឋកម្មនេះ កិច្ចស៊ើបសួរទាំងនេះអាចដំណើរការចោទប្រកាន់ទាំងចំពោះជនសង្ស័យដែល មានបង្ហាញឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរផង ទាំងចំពោះអ្នកដទៃទៀតផង "ដែលប្រឆាំងនឹងអ្នកទាំងនោះ ដោយមានភស្តុតាងច្បាស់លាស់ និង ស៊ីសង្វាក់គ្នា" ដោយបង្ហាញ ថាបុគ្គលបែបនោះអាចមានការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មដែលមាននៅក្នុង ដីកា សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ ប្រការដែលច្បាស់ នោះគឺថា គោលបំណងនៃវិធាន ៥៥(១) គឺបង្គាប់ឱ្យបើកកិច្ចស៊ើបសួរទៅដល់មូលដ្ឋានបទឧក្រិដ្ឋ ដែលបានកំណត់ដោយសហព្រះរាជអាជ្ញា តែមិនមានបំណងដាក់កំហិតដោយមានសំអាងហេតុមិន គ្រប់គ្រាន់នៃវិសាលភាពនៃកិច្ចស៊ើបសួរចំពោះអំពើរបស់បុគ្គលណាម្នាក់ជាក់លាក់នោះទេ។

<u>អត្ថន័យនៃពាក្យថា "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ត្រូវតែបកស្រាយឱ្យ ស្របទៅតាមគោលការណ៍នៃការបកស្រាយសន្ធិសញ្ញាដែលមានជាធរមាន</u>

៤៧. មាត្រា ១ នៃកិច្ចព្រមព្រៀង និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[70] បានចែងជាពាក្យពេចន៍ដូចគ្នា បេះបិទថា គោលបំណងនៃលិខិតុបករណ៍ទាំងពីរនេះគឺ

---

[69] ឯកសារលេខ **D26** ដីកាសំរេច , កំណត់សំគាល់លេខ២ *ខាងលើ* ត្រង់កថាខណ្ឌទី៦(គ)។

[70] កិច្ចព្រមព្រៀងរវាង អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់ក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបាន ប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ចុះថ្ងៃទី៦ មិថុនា២០០៣។

> *វិនិច្ឆ័យទោស មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ៦ មករា ១៩៧៩*[71] ។

៤៨. មាត្រា ២(២) នៃកិច្ចព្រមព្រៀងបានចែងថា "កិច្ចព្រមព្រៀងនេះត្រូវអនុវត្តក្នុងប្រទេសកម្ពុជា តាមរយៈច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ"[72]។ អាស្រ័យហេតុនេះ មាត្រា ២ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក បានផ្ដល់យុត្តាធិការដល់តុលាការទៅលើ "មេដឹកនាំជាន់ខ្ពស់" និង អ្នក "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងពេលដូចគ្នានេះ[73]។

៤៩. កិច្ចព្រមព្រៀង និង ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក មិនបានកំណត់និយមន័យនៃពាក្យថា "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ទេ។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាអន្តរជាតិសូមសន្និដ្ឋានថា ដំបូង អ.ប.ជ គួរតែអនុវត្តតាមវិធីសាស្ត្រនៃការបកស្រាយដែលមានចែងពីមាត្រា ៣១ ដល់មាត្រា ៣៣ នៃ *អនុសញ្ញាទីក្រុងវីយែនស្ដីពីច្បាប់សន្ធិសញ្ញា* ("VCLT")[74]។ មាត្រា ២(២) នៃកិច្ចព្រមព្រៀងបានអះអាងជាក់ស្ដែងថា *អនុសញ្ញាទីក្រុងវីយែនស្ដីពីច្បាប់សន្ធិសញ្ញា* ("VCLT") យកមកអនុវត្តចំពោះកិច្ចព្រមព្រៀង[75]។ តុលាការយុត្តិធម៌

---

[71] ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ដោយរួមបញ្ចូលនូវការធ្វើវិសោធនកម្មមួយចំនួន ដែលត្រូវបានប្រកាសឲ្យប្រើកាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤, មាត្រា១ ("ច្បាប់ អវតក")។ កិច្ចព្រមព្រៀងរវាង អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់ក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ចុះថ្ងៃទី៦ មិថុនា២០០៣, មាត្រា១ ("កិច្ចព្រមព្រៀង")។

[72] កិច្ចព្រមព្រៀង, កំណត់សំគាល់លេខ៧០ *ខាងលើ*, មាត្រា២.២។

[73] ច្បាប់ អវតក, កំណត់សំគាល់លេខ៧១ *ខាងលើ*, មាត្រា២។

[74] អនុសញ្ញាទីក្រុងវីយែនស្ដីពីច្បាប់សន្ធិសញ្ញា, ចុះថ្ងៃទី២៣ ឧសភា ១៩៦៩, ឯកសារលេខ 115 UNTS 331 ("VCLT")។

[75] កិច្ចព្រមព្រៀង, កំណត់សំគាល់លេខ៧១ *ខាងលើ*, មាត្រា២.២។

អន្តរជាតិបានអះអាងជាក់ស្តែងថា វិធាននៃការបកស្រាយពីមាត្រា ៣១ ដល់មាត្រា ៣៣ នៃអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញាបានឆ្លុះបញ្ចាំងពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ[76]។

៥០. ក្នុងការអនុវត្តវិធាននៃអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញានោះ កិច្ចព្រមព្រៀងគួរតែត្រូវបានបកស្រាយដោយមាន "ភាពសុទ្ធចិត្ត" និងអនុលោមតាម "អត្ថន័យធម្មតារបស់វា ... នៅក្នុងបរិបទ និង ទៅតាមវត្ថុបំណង និង គោលបំណងនៃវិធានទាំងនោះ"[77]។ ដោយឡែក នៅក្នុងករណីនេះ បរិបទនៃកិច្ចព្រមព្រៀងបានបញ្ចូលសេចក្តីអធិប្បាយក្នុងកថាខណ្ឌទីបី ទៅក្នុងបុព្វកថារបស់វា និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលពិតជា "លិខិតុបករណ៍មួយដែលត្រូវបានបង្កើតឡើងដោយភាគីមួយ ឬ ច្រើន ដែលមានទំនាក់ទំនងទៅនឹងសេចក្តីសន្និដ្ឋានចុងក្រោយនៃសន្ធិសញ្ញានោះ និង ដែលត្រូវបានទទួលយកដោយភាគីផ្សេងទៀតថាជាលិខិតុបករណ៍ទាក់ទិននឹងសន្ធិសញ្ញានេះ"[78]។ វិធាននៃអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញាក៏បានពឹងផ្អែកលើឯកសារព្រាង និង កាលៈទេសៈនានានៃសេចក្តីសន្និដ្ឋានចុងក្រោយនៃសន្ធិសញ្ញា ដើម្បីពន្យល់អត្ថន័យធម្មតានៃពាក្យពេចន៍ដែលមិនច្បាស់លាស់ ឬ ស្រពិចស្រពិលដូចជាសំណុំរឿងពេលបច្ចុប្បន្ន[79]។

៥១. សហព្រះរាជអាជ្ញាអន្តរជាតិសូមសន្និដ្ឋានថា កាលៈទេសៈនៃការសន្និដ្ឋានចុងក្រោយនៃកិច្ចព្រមព្រៀងនោះបានបង្ហាញយ៉ាងច្បាស់ថា សេចក្តីសម្រេចតាមការសន្មតរបស់ ស.ច.ស ទៅលើយុត្តាធិការចំពោះបុគ្គលបានបង្ហាញឲ្យឃើញពីកំហុសឆ្គងផ្នែកច្បាប់ ក្នុងការបកស្រាយរបស់ខ្លួនចំពោះពាក្យថា "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នៅក្នុងមាត្រា ១ និង

---

[76] ជម្លោះអំពីបញ្ហាទឹកដី (Arab Jamahariyya នៃប្រទេសលីប៊ី/ប្រទេសឆាត), សាលក្រម, (ឆ្នាំ១៩៩៤) របាយការណ៍លេខ៦ របស់តុលាការយុត្តិធម៌អន្តរជាតិ (ICJ Reports) , ត្រង់កថាខណ្ឌទី៤១ ។ ការកំណត់ខ្សែព្រំដែនសមុទ្ទ និងបញ្ហាទឹកដីរវាងប្រទេសកាតា (Qatar) និងប្រទេស បាហ៊ែន (Bahrain) (ឆ្នាំ១០៥៥) របាយការណ៍លេខ៦ របស់តុលាការយុត្តិធម៌អន្តរជាតិ (ICJ Reports), ត្រង់កថាខណ្ឌទី៣៣។

[77] អនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា(VCLT), កំណត់សំគាល់លេខ៧៤ *ខាងលើ*, មាត្រា៣១.១។ អនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា(VCLT) រវាងរដ្ឋនានា នឹងបណ្តាអង្គការអន្តរជាតិ ឬរវាងអង្គការអន្តរជាតិនានា, ចុះថ្ងៃទី២១ មីនា ១៩៨៦, ត្រង់មាត្រា៣១.១ ("VCLTIO") ។

[78] VCLT, កំណត់សំគាល់លេខ៧៤ *ខាងលើ*, មាត្រា៣១.២ (ខ)។ VCLTIO កំណត់សំគាល់លេខ៧៧ *ខាងលើ*, មាត្រា៣២(ក)។

[79] VCLT, កំណត់សំគាល់លេខ៧៤ *ខាងលើ*, មាត្រា៣១.២ (ខ)។ VCLTIO កំណត់សំគាល់លេខ៧៧ *ខាងលើ*, មាត្រា៣២(ក)។

មាត្រា ២(១) នៃកិច្ចព្រមព្រៀង និងបានឆ្លុះបញ្ចាំងក្នុងមាត្រា ២ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

៥២. សំណើដំបូងកាលពីឆ្នាំ ១៩៩៧ ដែលប្រទេសកម្ពុជាបានស្នើដើម្បីសុំជំនួយពីអង្គការសហប្រជាជាតិ ដែលបានបង្កើតជាមូលដ្ឋាននៃការចរចាគ្នាជាបន្តបន្ទាប់ឆ្ពោះទៅរកការបង្កើត អ.វ.ត.ក នោះ បាន យោងត្រឹមតែថា "វិនិច្ឆ័យទោសអ្នកទទួលខុសត្រូវ" ប៉ុណ្ណោះ ដោយលុបចោលនូវលក្ខខណ្ឌ គុណវុឌ្ឍិនានាដែលនឹងកំហិតវិសាលភាពនៃការទទួលខុសត្រូវនោះ[80]។

៥៣. បន្ទាប់ពីមានសំណើនេះមក មហាសន្និបាតបានអំពាវនាវឲ្យអគ្គលេខាធិការបង្កើត "ក្រុមអ្នក ជំនាញ" ដើម្បីឆ្លើយតបទៅនឹងសំណើសុំជំនួយរបស់រដ្ឋាភិបាល[81]។ របាយការណ៍នេះគឺជាផ្នែក មួយយ៉ាងសំខាន់ក្នុងការចរចារវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា ("RGC") ដែលផ្តល់ជាមូលដ្ឋានសម្រាប់ការពិភាក្សាដេញដោលផ្នែកនីតិបញ្ញត្តិ ដែលជាចុងក្រោយនាំឲ្យមាន ការអនុម័តច្បាប់ស្តីពីការបង្កើត អ.វ.ត.ក នេះឡើង។

៥៤. របាយការណ៍របស់ក្រុមអ្នកជំនាញបានសង្កត់ធ្ងន់ថា យុត្តាធិការចំពោះបុគ្គលរបស់តុលាការនេះមិន គួរត្រូវបានកំហិតដោយមិនត្រឹមត្រូវនោះទេ។ ទីមួយ របាយការណ៍នេះបានអះអាងថា ការកាត់ ទោសមិនគួរកំហិតដោយដកចេញនូវបុគ្គល "ដែលបានចុះចូលជាមួយរដ្ឋាភិបាល ឬ វិលត្រឡប់ទៅ ជីវភាពជាមនុស្សសាមញ្ញ" នោះទេ[82]។ ជាងនេះទៀត របាយការណ៍នេះកត់សម្គាល់ថា យុត្តាធិការ

[80] ឯកសាររបស់អង្គការសហប្រជាជាតិ ដែលមានចំណងជើងថា លិខិតដូចគ្នាបេះបិទ ចុះថ្ងៃទី២៣ មិថុនា ១៩៩៧ ពីលោកអគ្គលេខាធិការនៃ អសប ផ្ញើជូនលើកប្រធាននៃមហាសន្និបាត អសប និងប្រធានក្រុមប្រឹក្សាសន្តិសុខ អសប, ឯកសារ អសប លេខ A51/930 and S/1997/488, ចុះថ្ងៃទី ២៤ មិថុនា ១៩៩៧ (ដែលមានលិខិតមួយពីសហនាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា ព្រះអង្គម្ចាស់ នរោត្តមរណ្ណឫទ្ធិ និងលោក ហ៊ុន សែន ដែលផ្ញើជូនលោកអគ្គលេខាធិការ ជូនភ្ជាប់មកជាមួយផង)។

[81] សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ៥២/១៣៥ ដែលមានចំណងជើងថា *ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា,* U.N. Doc. No. A/RES/52/135, ថ្ងៃទី២៧ កុម្ភៈ ១៩៩៨ ត្រង់កថាខណ្ឌទី ១៦ ។

[82] របាយការណ៍របស់ក្រុមអ្នកជំនាញសម្រាប់កម្ពុជា បង្កើតឡើងតាមសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិលេខ ៥២/១៣៥, UN Doc. Nos. A/53/850 និង S/1999/231, ថ្ងៃទី១៦ មីនា ១៩៩៩ ត្រង់កថាខណ្ឌទី ១០៧ ("របាយការណ៍របស់ក្រុមអ្នកជំនាញ") ។

ចំពោះបុគ្គលរបស់តុលាការនេះពុំចាំបាច់មានទំនាក់ទំនងដោយផ្ទាល់ដល់មេដឹកនាំជាន់ខ្ពស់ក្នុងជួររដ្ឋាភិបាល ដែល "អាចនឹងមិនស៊ីសង្វាក់ទៅនឹងបញ្ជីឈ្មោះបុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្ស ដែលនៅក្នុងនោះមេដឹកនាំជាន់ខ្ពស់ក្នុងជួររដ្ឋាភិបាលអាចនឹងត្រូវបានដកចេញពីការយល់ដឹង និង ការសម្រេចចិត្ត ហើយ*អ្នកដទៃទៀតដែលមិនស្ថិតនៅក្នុងចំណោមមេដឹកនាំជាន់ខ្ពស់ អាចធ្លាប់បានដើរតួនាទីយ៉ាងសំខាន់ក្នុងអំពើឃោរឃៅទាំងនោះ*"[83]។ "មេដឹកនាំមួយចំនួននៅថ្នាក់ភូមិភាគ" ត្រូវបានចាត់ទុកថា ធ្លាប់បានដើរតួនាទីយ៉ាងសំខាន់ក្នុងអំពើឃោរឃៅ[84]។

៥៥. ក្រុមអ្នកជំនាញបានអះអាងបន្តទៀតថា "អ្នក*ទទួលខុសត្រូវខ្ពស់បំផុត* ... នឹងបញ្ចូលមេដឹកនាំជាន់ខ្ពស់ដែលមានការទទួលខុសត្រូវចំពោះការបំពានអំណាច *រួមទាំងអ្នកនៅថ្នាក់ក្រោមដែលត្រូវបានគេឆ្លើយដាក់ដោយផ្ទាល់ចំពោះអំពើឃោរឃៅធ្ងន់ធ្ងរបំផុត*"[85]។ ក្នុងការបង្ហាញបន្ថែមទៀតពីវិសាលភាពនៃការទទួលខុសត្រូវ របាយការណ៍នោះបានបង្ហាញថា "ចំនួនបុគ្គលដែលអាចយកមកវិនិច្ឆ័យទោសបានមានចំនួនពី ២០ នាក់ ទៅ ៣០ នាក់"[86]។

៥៦. នៅឆ្នាំ ២០០១ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តសំណៅដំបូងនៃ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលបានបញ្ចូលទម្រង់ "មេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ និង អ្នកទទួលខុសត្រូវខ្ពស់បំផុត"[87]។ ច្បាប់ឆ្នាំ ២០០១ អនុលោមទៅតាមសំណើនានានៅក្នុងរបាយការណ៍របស់ក្រុមអ្នកជំនាញ ដែលច្បាប់សំដៅដល់ឋានន្តរស័ក្តិរបស់បុគ្គលនោះផង (មេដឹកនាំជាន់ខ្ពស់) និងតួនាទីជាក់

[83] *ដដែលដូចមុន,* កថាខណ្ឌទី ១០៩ (សង្កត់ន័យបន្ថែមដោយ*អក្សរទ្រេត*) ។

[84] *ដដែលដូចមុន,* កថាខណ្ឌទី ១០៩ (សង្កត់ន័យបន្ថែមដោយ*អក្សរទ្រេត*) ។

[85] *ដដែលដូចមុន,* កថាខណ្ឌទី ១១០ ។

[86] របាយការណ៍របស់ក្រុមអ្នកជំនាញ, កំណត់សម្គាល់*ខាងលើ* លេខ៨២ ត្រង់កថាខណ្ឌទី ១១០ ។

[87] ព្រះរាជក្រមលេខ នស/រកម/០៨០១/១២, ថ្ងៃទី១០ សីហា ២០០១ (ប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ) ។ ច្បាប់ឆ្នាំ ២០០១ ក្រោយមក ត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី២៧ តុលា ២០០៤ ដើម្បីបង្កើតបានជាច្បាប់ អវតក សព្វថ្ងៃ ។ *សូមមើល* ព្រះរាជក្រមលេខ នស/រកម/ ១០០៤/០០៦ ។

ស្តែងរបស់ជននោះនៅក្នុងអំពើឧក្រិដ្ឋកម្មផង (ទទួលខុសត្រូវខ្ពស់បំផុត)។ ក្រោយមកទម្រង់នេះត្រូវបានអនុម័តយល់ព្រមដោយមហាសន្និបាទ[88]។

៥៧. ក្នុងអំឡុងការពិភាក្សាដេញដោលក្នុងរដ្ឋសភាទៅលើច្បាប់ស្តីពីការបង្កើត អ.វ.ត.ក កាលពីខែ តុលា ឆ្នាំ ២០០៤[89] ក្នុងការឆ្លើយតបទៅនឹងសំណួរមួយដែលស្វែងរកការបញ្ជាក់ឲ្យបានច្បាស់ពីវិសាលភាពរបស់បុគ្គលដែលនឹងត្រូវយកមកផ្តន្ទាទោសនោះ មានការលើកឡើងក្នុងនាមរាជរដ្ឋាភិបាលកម្ពុជាថា មាត្រា ២ នៃសេចក្តីស្នើច្បាប់នោះមានគោលបំណងអនុញ្ញាតឲ្យមានការវិនិច្ឆ័យទោសទៅលើ "បុគ្គលពីរប្រភេទ"គឺ៖ (១)."មេដឹកនាំជាន់ខ្ពស់" ដោយផ្តុយពីបុគ្គលដែលមាន "តំណែងធម្មតា" និង (២)."បុគ្គលដែលមិនមែនជាមេដឹកនាំជាន់ខ្ពស់ ប៉ុន្តែអ្នកដែលបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរដូចមេដឹកនាំជាន់ខ្ពស់ដែរ" [90]។ ក្នុងការឆ្លើយតបទៅនឹងសំណើសុំឲ្យបញ្ជាក់ពីការយល់ដឹងរបស់រដ្ឋាភិបាលចំពោះការគ្រប់គ្រងនៅថ្នាក់មូលដ្ឋាន ("ថ្នាក់តំបន់ ស្រុក ឃុំ និងសហករណ៍") ប្រយោគដែលត្រូវបានចាត់ទុកថាជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" រាជរដ្ឋាភិបាលកម្ពុជាបានអះអាងយ៉ាងច្បាស់ថា "ទាំងខាងភាគីអង្គការសហប្រជាជាតិ ទាំងក្រុមការងាររាជរដ្ឋាភិបាលកម្ពុជាមិនអាចផ្តល់ចម្លើយ" ទៅនឹងសំណួរថា "តើបុគ្គលណាខ្លះនឹងត្រូវយកមកវិនិច្ឆ័យទោស" បានទេ ដោយសារថា "នេះជាភារកិច្ចរបស់ ... អង្គជំនុំជម្រះវិសាមញ្ញ"។ រាជរដ្ឋាភិបាលកម្ពុជាក៏បានបញ្ជាក់ផងដែរនៅក្នុងការពិភាក្សាដេញដោលក្នុងរដ្ឋសភាថា ចំណុចទាំងអម្បាលម៉ាណខាងក្រោមនេះត្រូវបានអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជាព្រមព្រៀងគ្នាជាឯកច្ឆ័ន្ទហើយ៖

(ក) មានបុគ្គលពីរប្រភេទគឺ៖ បុគ្គលដែលជាមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត។

(ខ) មេដឹកនាំជាន់ខ្ពស់នឹងមិនមានចំនួនលើសពីចំនួន ១០ រូបទេ។ និង

---

[88] សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ៥៧/២២៨ ដែលមានចំណងជើងថា *ការកាត់សេចក្តីពួកខ្មែរក្រហម,* U.N. Doc. No. A/RES/57/228, ថ្ងៃទី២៧ កុម្ភៈ ២០០៣, ត្រង់កថាខណ្ឌទី ៣ ។

[89] ៤-៥ តុលា ២០០៤, លេខ ERN 00315486-515 ("កិច្ចពិភាក្សាដេញដោលរបស់សភាជាតិ") ។ [ឯកសារលេខ...] ។

[90] កិច្ចពិភាក្សាដេញដោលរបស់សភាជាតិ, ត្រង់លេខERN 00336417 ។

(គ) ប្រភេទទីពីរនៃអ្នកទទួលខុសត្រូវខ្ពស់បំផុតគឺសំដៅដល់បុគ្គលដែលមិនមែនជាមេដឹកនាំជាន់ខ្ពស់ តែអ្នកដែលមានប្រព្រឹត្តអំពើឃោរឃៅ ហើយមិនមានចំនួនជាក់លាក់ចំពោះបុគ្គលដែលស្ថិតក្នុងប្រភេទទីពីរនេះទេ[91]។

៥៨. លោកស្រី Helen Jarvis ដែលជាទីប្រឹក្សាក្រុមការងារបង្កើតសាលាជម្រះក្តីបានសរសេរក្នុងឆ្នាំ ២០០៤ រៀបរាប់ពីបញ្ជីឈ្មោះជនសង្ស័យរហូតដល់ឈ្មោះ ស៊ូ ម៉េត និង មាស មុត ថាជា "ជាកម្មាភិបាលខ្មែរក្រហមសំខាន់ ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរ"[92]។ ទោះបីការចាត់ទុកបែបនេះមិនប៉ះពាល់ការវាយតម្លៃឯករាជ្យរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលនាំឱ្យមានការកំណត់ជាទម្រង់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ តែកំណត់ហេតុស្តីពីការពិភាក្សាដេញដោល និង សេចក្តីថ្លែងការណ៍ខាងលើបានបង្ហាញពីការយល់ដឹងរបស់រដ្ឋាភិបាលកម្ពុជា និង ពីបុគ្គលដែលមានចូលរួមយ៉ាងជិតស្និទ្ធក្នុងការចរចា សេចក្តីសន្និដ្ឋានចុងក្រោយ និងការអនុវត្តកិច្ចព្រមព្រៀងតាមរយៈច្បាប់ស្តីពីការបង្កើត អ.វ.ត.ក នេះ។

៥៩. លោក David Scheffer ដែលជាអ្នកចូលរួមដោយផ្ទាល់ម្នាក់ទៀតនៅក្នុងការចរចាដែលនាំឱ្យមានការបង្កើត អ.វ.ត.ក បានធ្វើការប្រមូលចងក្រងឯកសារនានាជាលក្ខណៈបុគ្គលនោះ បានផ្តល់ការសង្កេតពាក់ព័ន្ធនឹងបញ្ហានេះដូចខាងក្រោម៖

> *ដើម្បីផ្តល់ជាយោបល់នាពេលនេះថា របៀបដែលអាជ្ញាធរកម្ពុជាបានបកស្រាយពាក្យពេចន៍ដែលទាក់ទិននឹងយុត្តាធិការចំពោះបុគ្គល ដើម្បីកំហិតចំនួនជនសង្ស័យ មកត្រឹមតែបុគ្គលប្រាំរូបនោះគឺពុំមានជំនឿទុកចិត្តទេ ជាពិសេស ទាក់ទិននឹងពេលវេលាជាច្រើនឆ្នាំនៃការចរចា និង គម្លាតគ្នាយ៉ាងឆ្ងាយរវាងយុត្តាធិការទៅលើបុគ្គលដែលថា ប្រជាជនកម្ពុជាបានគាំទ្រជិតមួយទសវត្សរ៍ឆ្នាំ ២០០០ នោះ[93]។*

---

[91] កិច្ចពិភាក្សាដេញដោលរបស់សភាជាតិ, កំណត់សម្គាល់*ខាងលើ* លេខ៨៩ ត្រង់លេខERN 00315508 ។

[92] Tim Fawthrop និង Helen Jarvis, តើគេចរួចផុតពីការផ្តន្ទាទោសពីអំពើប្រល័យពូជសាសន៍ ឬ? ។ យុត្តិធម៌ដែលពិបាកយល់ និង សាលាក្តីខ្មែរក្រហម (ឆ្នាំ២០០៤) ត្រង់ទំព័រទី ២៦៩ ។

[93] David Scheffer, *ការចរចាពីប្រវត្តិយុត្តាធិការបុគ្គលរបស់ អវតក*, ("Scheffer") ត្រង់ទំព័រទី ១០, គេហទំព័រ៖ http://www.cambodiatribunal.org/blog/2011/05/negotiating-history-eccc%E2%80%99s-personal-jurisdiction ។

៦០. បន្ទាប់ពីមានការធ្វើវិភាគទៅលើដំណើរប្រវត្តិនៃការរៀបចំសេចក្តីព្រាងកិច្ចព្រមព្រៀងនោះ លោក Steven Heder បានធ្វើការសន្និដ្ឋានចំពោះការបកស្រាយទៅលើពាក្យពេចន៍ទាំងនេះថា៖

> *ពាក្យថា[...] "មេដឹកនាំជាន់ខ្ពស់" ត្រូវបានយោងទៅដល់សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ប.ក.ក និងគណៈកម្មាធិការមជ្ឈិម និង អាចសំដៅដល់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យផងដែរ រីឯពាក្យថា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" វិញ គឺសំដៅដល់មេដឹកនាំនយោបាយ និង យោធានៅថ្នាក់កណ្តាល ដែលរួមមានរដ្ឋមន្ត្រីនៅក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬ ប្រហែលជាបុគ្គលដែលត្រូវបានចាត់ថ្នាក់នៅក្នុងប្រភេទនេះផង និង សំដៅដល់មេដឹកនាំថ្នាក់កណ្តាលដែររួមទាំង ឌុច ផង ដែលសំអាងថា មានភស្តុតាងគ្រប់គ្រាន់ប្រឆាំងនឹងបុគ្គលនោះ។ ម្យ៉ាងវិញទៀត "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដទៃទៀត មិនបានគ្របដណ្តប់ទៅលើថ្នាក់ក្រោមនៃពួកខ្មែរក្រហម ពោលគឺមិនសំដៅដល់ចារីធម្មតាជាជនដែលដល់ទេ ទោះបីពួកគេជាកម្មាភិបាល ប.ក.ក ដែលមានអំណាចខ្លះទៅលើសមាជិក ប.ក.ក ក៏ដោយ*[94] ។

អត្ថន័យនៃឃ្លាថា "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" អាចត្រូវបានបញ្ជាក់បន្ថែម តាមរយៈសេចក្តីយោងនៅលើច្បាប់លក្ខន្តិកៈ សេចក្តីសម្រេច និងគោលនយោបាយនានារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការព្រហ្មទណ្ឌអន្តរតួបនីយកម្មដទៃទៀត ។

៦១. យុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់យូហ្គោស្លាវី ("ICTY") និងតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ("SCSL") និងគោលការណ៍ស៊ើបសួររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") លើកឡើងថា គួរត្រូវបានបកស្រាយឱ្យកាន់តែទូលំទូលាយទៅលើពាក្យថា មេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ជាពិសេស នៅក្នុងដំណាក់កាលនៃកិច្ចស៊ើបសួរតែម្តង។

[94] Steven Heder, "ការពិនិត្យឡើងវិញពីការចរចានានារវាង កម្ពុជា, អសប និង សរអា ស្តីពីយុត្តាធិការបុគ្គលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា", ថ្ងៃទី១ សីហា ២០១១, អាចរកបាននៅតាមគេហទំព័រ៖ http://www.cambodiatribunal.org/sites/default/files/A%20Review%20of%20the%20Negotiations%20Leading%20to%20the%20Establishment%20of%20the%20Personal%20Jurisdiction%20of%20the%20ECCC.pdf ត្រង់ទំព័រទី ៣៨ ។

៦២. ទោះបីជាវិសាលភាពនៃយុត្តាធិការបុគ្គលរបស់តុលាការ ICTY ត្រូវបានបង្កើតឡើងទូលំទូលាយជាងវិសាលភាពរបស់ អ.វ.ត.ក ក្តី[95] ក៏នាពេលបន្ទាប់មក តុលាការ ICTY បានផ្តោតទៅលើការចោទប្រកាន់ "មេដឹកនាំជាន់ខ្ពស់បំផុតដែលជាប់សង្ស័យថា ជាអ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះបទល្មើសដែលស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួន[96] និងផ្ទេរសំណុំរឿងទាំងឡាយណាដែលពុំបំពេញតាមលក្ខខណ្ឌនេះទៅឲ្យតុលាការជាតិ[97]។ នៅក្នុងការវាយតម្លៃថាតើបុគ្គលណាម្នាក់ជាមេដឹកនាំជាន់ខ្ពស់បំផុតដែលជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ចៅក្រមទទួលបន្ទុកផ្ទេរសំណុំរឿងនៃតុលាការ ICTY (ICTY Referral Bench) បានពិចារណាទៅលើ (១) ភាពធ្ងន់ធ្ងរនៃបទចោទ និង (២) កម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ[98]។ កត្តាទាំងពីរនេះឆ្លើយតបទៅនឹងការវាយតម្លៃ ថាតើជនជាប់ចោទជា "មេដឹកនាំជាន់ខ្ពស់បំផុត" (កម្រិតនៃការទទួលខុសត្រូវ) និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" (ភាពធ្ងន់ធ្ងរនៃអំពើឧក្រិដ្ឋ)។

៦៣. នៅក្នុងការវាយតម្លៃអំពីកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ ចៅក្រមទទួលបន្ទុកផ្ទេរសំណុំរឿងនៃតុលាការ ICTY បានកត់សម្គាល់ឃើញថា "មេដឹកនាំជាន់ខ្ពស់បំផុត" មិនកម្រិតត្រឹមតែជាជនដែលជា "អ្នកបង្កើតគោលនយោបាយរួម" ដែលបង្កើតបានជាមូលដ្ឋាននៃបទល្មើស

---

[95] លក្ខន្តិកៈនៃតុលាការឧក្រិដ្ឋកម្មសំរាប់អតីតប្រទេសយូហ្គោស្លាវី, ចុះថ្ងៃទី២៥ ឧសភា ១៩៩៣, ដែលបានធ្វើវិសោធន កម្មកាលពី ថ្ងៃទី៧ កក្កដា ២០០៩, មាត្រាទី១។

[96] សេចក្តីសំរេចចិត្ត លេខ១៥៣៤ របស់ក្រុមប្រឹក្សាសន្តិសុខ អសប, ចុះថ្ងៃទី២៦ មិនា ២០០៤ , ត្រង់កថាខណ្ឌទី៥-៦, ឯកសាររបស់ អសប លេខ S/Res/1534 (2004)។ សេចក្តីសំរេចចិត្ត លេខ១៥០៣ របស់ក្រុមប្រឹក្សាសន្តិសុខ អសប, ចុះថ្ងៃទី២៨ សីហា ២០០៣ , ឯកសាររបស់ អសប លេខ S/Res/1503 (200៣)។

[97] វិធានស្តីពីនិទិវិធីនិងភស្តុតាង នៃតុលាការឧក្រិដ្ឋកម្មសំរាប់អតីតប្រទេសយូហ្គោស្លាវី, វិធាន១១*ស្ទួន* (ដែលរៀបរាប់អំពីដំណើរការក្នុងការផ្ទេរបញ្ជូនសំណុំរឿង ទៅឲ្យតុលាការមានសមត្ថកិច្ចនានារបស់ជាតិ)។ វិធាន១១*ស្ទួន* យោងទៅលើសេចក្តីសំរេចចិត្តលេខ ១៥៣៤ របស់ក្រុមប្រឹក្សាសន្តិសុខ អសប ហើយបានចែងថា តុលាការ ICTY នឹងពិនិត្យពិចារណាអំពី "ស្ថានទម្ងន់ទោសនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់" និងអំពី "កំរិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ" នៅក្នុងការធ្វើសេចក្តីសេចអំពីថាតើត្រូវបញ្ជូនសំណុំរឿងដែរឬអត់?។ *សូមអានផងដែរ* ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង *Dragomir Milošević*, សំណុំរឿងលេខ IT-98-29/1-PT, អង្គចៅក្រមបញ្ជូនសំណុំរឿង, សេចក្តីសំរេចស្តីពីការបញ្ជូនសំណុំរឿងអនុលោមតាមវិធាន១១*ស្ទួន*, ចុះថ្ងៃទី៨ កក្កដា ២០០៥, ត្រង់កថាខណ្ឌទី១៣ (ដែលរៀបរាប់រាប់អំពីវិធីដំណើរក្នុងការផ្ទេរបញ្ជូន) ("សេចក្តីសំរេចស្តីពីការបញ្ជូនសំណុំរឿងរបស់ *Milošević*")។

[98] ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង *Lukić*, សំណុំរឿងលេខ IT-98-32/1-PT, តុលាការ ICTY, ចុះថ្ងៃទី៥ មេសា ២០០៧, ត្រង់កថាខណ្ឌទី២៦ (ដែលរៀបរាប់រាប់អំពីវិធីដំណើរក្នុងការផ្ទេរបញ្ជូន) (" សេចក្តីសំរេចស្តីពីការបញ្ជូនសំណុំរឿងរបស់ *Lukić* ")។

ដែលត្រូវបានចោទប្រកាន់នោះទេ[99]។ ផ្ទុយទៅវិញ តាមរយៈតួនាទី និងមុខងារ *ជាក់ស្តែង* និង *ស្របច្បាប់ (de jure* and *de facto* position and function*)* នៅក្នុងឋានានុក្រមដែលពាក់ព័ន្ធ ចៅក្រមទទួលបន្ទុកផ្ទេរសំណុំរឿងនៃតុលាការ ICTY យល់ឃើញថា ជនណាដែលបានរងការចោទប្រកាន់ថាបានអនុវត្តកម្រិតនៃសិទ្ធិអំណាចមួយដែលសមស្រប អាចចាត់ទុកថាជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ជាជាង "អន្តរការី" ទៅវិញ[100]។ កត្តានានាដែលតុលាការបានលើកយកមកពិចារណានៅក្នុងការសម្រេចអំពីកម្រិតនៃសិទ្ធិអំណាចនេះ រួមមាន៖ តួនាទីអចិន្ត្រៃយ៍ និងតួនាទី *បណ្តោះអាសន្ន*[101] វិសាលភាពពេលវេលា[102] ឋានៈរបស់ជនជាប់ចោទនៅក្នុងរចនាសម្ព័ន្ធឋានានុក្រម[103] សិទ្ធិអំណាចក្នុងការចរចា ការចុះហត្ថលេខា ឬការអនុវត្តកិច្ចព្រមព្រៀង[104] ការគ្រប់គ្រងទឹកដី[105] ចំនួនមនុស្សក្រោមបង្គាប់[106] តួនាទីជាក់ស្តែងរបស់ជនជាប់ចោទនៅក្នុងការប្រព្រឹត្តបទល្មើស[107] និងថាតើមនុស្សដែលមានឋានៈខ្ពស់ជាងជនជាប់ចោទ ត្រូវបានផ្តន្ទាទោសចំពោះតួនាទីរបស់ពួកគេហើយឬនៅ[108]។

៦៤. ដោយការអនុវត្តកត្តាទាំងនេះ ចៅក្រមទទួលបន្ទុកផ្ទេរសំណុំរឿងរបស់តុលាការ ICTY បាន

---

99 សេចក្តីសំរេចស្តីពីការបញ្ជូនសំណុំរឿងរបស់ *Milošević,* កំណត់សំគាល់លេខ៩៧ *ខាងលើ* ត្រង់កថាខណ្ឌ២៨។ សេចក្តីសំរេចស្តីពីការបញ្ជូនសំណុំរឿងរបស់ *Lukić,* ត្រង់កថាខណ្ឌ២៨។

100 *ដូចគ្នានឹងខាងលើ។*

101 សេចក្តីសំរេចស្តីពីការបញ្ជូនសំណុំរឿងរបស់ *Milošević,* កំណត់សំគាល់លេខ៩៧ *ខាងលើ* ត្រង់កថាខណ្ឌ២៣។

102 *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌ២៣។

103 ករណីរឿងក្តីរបស់ *រដ្ឋអាជ្ញា ទល់នឹង* *Ademi*, សំណុំរឿងលេខ IT-04-78-PT, តុលាការ ICTY, ចុះថ្ងៃទី១៤ កញ្ញា ២០០៥, ត្រង់កថាខណ្ឌទី២៩ (" សេចក្តីសំរេចស្តីពីការបញ្ជូនសំណុំរឿងរបស់ Ademi")។ ករណីរឿងក្តីរបស់ *រដ្ឋអាជ្ញា ទល់នឹង* *Kovačević*, សំណុំរឿងលេខ IT-01-42/2-I, តុលាការ ICTY, ចុះថ្ងៃទី១៤ កញ្ញា ២០០៥, ត្រង់កថាខណ្ឌទី២០ (" សេចក្តីសំរេចស្តីពីការបញ្ជូនសំណុំរឿងរបស់ *Kovačević*")។ សេចក្តីសំរេចស្តីពីការបញ្ជូនសំណុំរឿងរបស់ *Milošević* ត្រង់កថាខណ្ឌ២៣។ សេចក្តីសំរេចស្តីពីការបញ្ជូនសំណុំរឿងរបស់ *Lukić,* កំណត់សំគាល់លេខ៩៨ *ខាងលើ* ត្រង់កថាខណ្ឌ២៨។

104 សេចក្តីសំរេចស្តីពីការបញ្ជូនសំណុំរឿងរបស់ *Milošević,* កំណត់សំគាល់លេខ៩៧ *ខាងលើ* ត្រង់កថាខណ្ឌ២៣។ សេចក្តីសំរេចស្តីពីការបញ្ជូនសំណុំរឿងរបស់ *Ademi*, *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌ២៩។

105 សេចក្តីសំរេចស្តីពីការបញ្ជូនសំណុំរឿងរបស់ *Milošević,* កំណត់សំគាល់លេខ៩៧ *ខាងលើ* ត្រង់កថាខណ្ឌ២៣។

106 *ដូចគ្នានឹងខាងលើ។*

107 សេចក្តីសំរេចស្តីពីការបញ្ជូនសំណុំរឿងរបស់ *Ademi*, *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌ២៩។ សេចក្តីសំរេចស្តីពីការបញ្ជូនសំណុំរឿងរបស់ *Lukić,* កំណត់សំគាល់លេខ១០៧ *ខាងលើ* ត្រង់កថាខណ្ឌ២៨។

108 សេចក្តីសំរេចស្តីពីការបញ្ជូនសំណុំរឿងរបស់ *Kovačević,* កំណត់សំគាល់លេខ១០៧ *ខាងលើ* ត្រង់កថាខណ្ឌ២០។

សន្និដ្ឋានថា មេបញ្ជាការយោធាម្នាក់ដែលគ្រប់គ្រងចំនួនដប់កងពលតូច និងកូនទាហាន ១៨.០០០ នាក់ ដែលបានរាយការណ៍ជូនមេបញ្ជាការយោធាថ្នាក់លើបំផុត ហើយដែលត្រូវបានចោទប្រកាន់ពីការបាញ់ផ្លោង និងការពួនស្នាក់បាញ់រះទៅលើទីក្រុងសារ៉ាយេវ៉ូ (Sarajevo) អស់រយៈពេលដប់ប្រាំខែ ព្រមទាំងការសម្លាប់ និងការបង្ករបួសស្នាមលើជនស៊ីវិលរាប់ពាន់នាក់ ត្រូវបានចាត់ទុកថាជា "មេដឹកនាំជាន់ខ្ពស់បំផុតម្នាក់ ក្នុងចំណោមមេដឹកនាំជាន់ខ្ពស់ជាច្រើនទៀត ដែលត្រូវបានសង្ស័យថា ជាអ្នកទទួលខុសត្រូវខ្ពស់ធំបុត"[109]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានសម្រេចថា មេបញ្ជាការកងសេនាជន (paramilitary leader) ជាន់ខ្ពស់បំផុតម្នាក់ ដែលត្រូវបានចោទប្រកាន់ ចំពោះការសម្របសម្រួលឱ្យមានឧប្បត្តិហេតុជាច្រើននៃការសម្លាប់ទ្រង់ទ្រាយធំដែលបានបណ្តាលឱ្យប្រជាជនជាង ១៥០ នាក់ស្លាប់ ត្រូវតែពិចារណាថាជា "មេដឹកនាំជាន់ខ្ពស់បំផុត" និងត្រូវបានជំនុំជម្រះដោយតុលាការនេះតែម្តង[110]។

៦៥. ជនទាំងឡាយណាដែលកម្រិតតួនាទី និងការទទួលខុសត្រូវ ត្រូវបានពិចារណាថាស្ថិតនៅក្នុងកម្រិតទាប និងមានលក្ខណៈសមស្របសម្រាប់ឱ្យតុលាការ ICTY ផ្ទេរការផ្ទេរទៅឱ្យតុលាការជាតិជំនុំជម្រះរួមមាន៖ មេបញ្ជាការកងសេនាជន មេបញ្ជាការរងប៉េអឹម (military police) ដែលសិទ្ធិអំណាចរបស់ខ្លួនត្រូវបានកម្រិតត្រឹមតែ "ថ្នាក់មូលដ្ឋាន" (ទីក្រុង Foča)[111] ជំនួយការមន្ត្រីពន្ធនាគារ ដែលការចោទប្រកាន់ត្រូវបានកម្រិតចំពោះតែតំបន់ជាក់លាក់ណាមួយ[112] មេបញ្ជាការកងពលតូច និងមេបញ្ជាការយោធាស្រុកស្តីទី ដែលត្រូវបានចោទប្រកាន់ចំពោះការស្លាប់ប្រជាជនចំនួន ៣៤ នាក់នៅក្នុងប្រតិបត្តិការយោធាតែមួយលើក[113] និងមេបញ្ជាការកងវរៈសេនាតូច ដែលត្រូវបានចោទប្រកាន់ចំពោះការចូលរួមនៅក្នុងយុទ្ធនាការយោធារយៈពេល

[109] សេចក្តីសំរេចស្តីពីការបញ្ជូនសំណុំរឿងរបស់ *Milošević,* កំណត់សំគាល់លេខ ៩៧ *ខាងលើ* ត្រង់កថាខណ្ឌទី៨-១០, ១៩, ២១-២៤។

[110] ICTY, *រដ្ឋអាជ្ញា ទល់នឹង Lukić*, សំណុំរឿងលេខ: Case No. IT-98-32/1-AR11ស្ទួន1, ១១ កក្កដា ២០០៧, កថាខ័ណ្ឌទី២១-២២, ២៥ (ការកែប្រែសេចក្តីសម្រេចរបស់អង្គចៅក្រមបញ្ជូនរឿង) ។

[111] *រដ្ឋអាជ្ញា ទល់នឹង Janković*, សំណុំរឿងលេខ: IT-96-23-2-AR11 ស្ទួន 2, សាលដីកាលើវិធាន១១ ស្ទួន ស្តីពីការបញ្ជូនរឿង (អង្គជំនុំជម្រះសាលាឧទ្ធរណ៍), ១៥ វិច្ឆិកា ២០០៥, កថាខ័ណ្ឌទី៤, ១៩-២២ ។

[112] *រដ្ឋអាជ្ញា ទល់នឹង Rasević*, សំណុំរឿងលេខ: IT-97-25/1-PT, សេចក្តីសម្រេចស្តីពីការបញ្ជូនសំណុំរឿងតាមវិធាន១១ស្ទួន, (អង្គចៅក្រមបញ្ជូនរឿង), ៨ កក្កដា ២០០៥, កថាខ័ណ្ឌទី១៣, ១៦, ២១-២២, ២៥ ។

[113] សេចក្តីសម្រេចបញ្ជូន *Ademi*, កំណត់សំគាល់*ខាងដើមលេខ០១៧* ត្រង់ កថាខ័ណ្ឌទី១៥-១៨, ២៨-៣១ ។

មួយខែ ដើម្បីបាញ់ផ្លោងដាក់ទីក្រុងឌូប្រូវនិក (Dubrovnik) ដែលបានធ្វើឱ្យរបួស ឬស្លាប់ប្រជាជនចំនួនប្រាំនាក់[114]។

៦៦. ភាសាដែលមានន័យដូចគ្នា នៅក្នុងលក្ខន្តិកៈតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន (SCSL Statute) គ្របដណ្តប់តែទៅលើជនទាំងឡាយណាដែលមានការទទួលខុសត្រូវ "ខ្ពស់បំផុត" តែប៉ុណ្ណោះ។ ហេតុដូច្នេះ វាមានលក្ខណៈចង្អៀតជាងពាក្យពេចន៍ប្រើប្រាស់នៅក្នុងកិច្ចព្រមព្រៀង និងច្បាប់ស្តីពី ការបង្កើត អ.វ.ត.ក[115]។ តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូនបានបកស្រាយពាក្យថា "ការទទួលខុសត្រូវខ្ពស់បំផុត" ដោយរាប់បញ្ចូលនូវ "លំដាប់លំដោយនៃបុគ្គលទាំងឡាយគិតចាប់ពីមេដឹកនាំយោធា និងមេដឹកនាំនយោបាយ រហូតដល់បុគ្គលដែលមានវ័យត្រឹម ១៥ ឆ្នាំ"[116] និងអ្នកដែល "ជាប់ពាក់ព័ន្ធនៅក្នុងឧក្រិដ្ឋកម្មធ្ងន់ធ្ងរ" ដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការនេះ[117]។

៦៧. គោលនយោបាយរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) គឺផ្តោត "ការស៊ើបអង្កេត"របស់ខ្លួនទៅលើជនទាំងឡាយណាដែលមាន "ការទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មអន្តរជាតិ

[114] សេចក្តីសម្រេចបញ្ជូន *Kovačević*, កំណត់សំគាល់*ខាងដើមលេខ០១៨* ត្រង់កថាខ័ណ្ឌទី១២-១៣, ២០ ។

[115] ច្បាប់លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន, ១៦ មករា ២០០២, កថាខ័ណ្ឌទី១ ។

[116] សូមអាន *រដ្ឋអាជ្ញា ទល់នឹង Brima និងគូកន,* សំណុំរឿងលេខ: SCSL-04-16-T, សាលក្រម, (អង្គជំនុំជម្រះសាលាដំបូង), ២០ មិថុនា ២០០៧, កថាខ័ណ្ឌទី៦៥៨-៥៩ (កត់សំគាល់ថា ឃ្លា "ការទទួលខុសត្រូវធំធេង" ត្រូវតែបកស្រាយឱ្យបានទូលំទូលាយគ្រប់គ្រាន់ ដើម្បីរាប់បញ្ចូលទាំងកុមារផងដែរ ហើយឃ្លានេះទៀតសោតគ្របដណ្តប់លើ "វិសាលភាពធំធេងនៃបុគ្គលម្នាក់ៗមកពីខាងមេដឹកនាំយោធា និងនយោបាយ រហូតដល់បុគ្គលម្នាក់ៗដែលទើបមានអាយុ១៥ឆ្នាំ" ។ *សូមអានផងដែរ រដ្ឋអាជ្ញា ទល់នឹង v Brima និងគូកន,* សំណុំរឿងលេខ: SCSL-04-16-T សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីស្នើឱ្យមានសាលក្រមដោះលែង អនុលោមតាមវិធាន៩៨, (អង្គជំនុំជម្រះសាលាដំបូង II), ៣១ មីនា ២០០៦, កថាខ័ណ្ឌទី៣៤, ៣៦-៣៧, ៣៩ ។ តុលាការពិសេសនេះថែមទាំងបានបញ្ជាក់ថា កុមារដែលមានអាយុចន្លោះពី១៥ ទៅ១៨ ឆ្នាំ អាចជា "បុគ្គលមានការទទួលខុសត្រូវធំធេង" ចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅសៀរ៉ាឡេអូន ។ ("ហេតុដូច្នេះ ទោះបីកុមារដែលជាប់ចោទពីបទឧក្រិដ្ឋធ្ងន់ធ្ងរអាច ស្ថិតក្នុងជំពូកមនុស្សដែលមាន "ការទទួលខុសត្រូវធំធេង" យ៉ាងណាក៏ដោយ ក៏ប្រហែលជានឹងស្ថិតក្នុងកំរិតទាបជាងគេបំផុតនៃវិសាលគម") ។ អង្គជំនុំជម្រះសាលាដំបូង II ក៏បានឱ្យដឹងដែរថា យុត្តាធិការរបស់តុលាការទៅលើជនជាប់ចោទរូបនោះមិនត្រូវទទួលរង ការប៉ះពាល់ឡើយ បើទោះបីជាគេមានភស្តុតាងបញ្ជាក់អំពីបុគ្គលបន្ថែមទៀតក៏មានការទទួលខុសត្រូវធំធេងផងដែរនោះ ។

[117] *ក្នុងឯកសារដដែលដូចខាងលើ,* ត្រង់កថាខ័ណ្ឌទី៣៨ ។

សំខាន់ៗ[118]។ ឯកសារគោលនយោបាយពាក់ព័ន្ធរបស់ការិយាល័យរដ្ឋអាជ្ញាកំណត់ថា នៅក្នុងការវាយតម្លៃពីកម្រិតនៃការទទួលខុសត្រូវ នោះកត្តានានាដែលត្រូវយកមកពិចារណារួមមាន "ឋានៈដែលត្រូវបានចោទប្រកាន់ ឬកម្រិតតាមឋានានុក្រមរបស់ជនជាប់ចោទ *ឬ* ការជាប់ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មដែលធ្ងន់ធ្ងរ ឬសាហាវបំផុត"[119]។ វាច្បាស់ហើយថា ផ្តើមចេញពីភាសាពាក់ព័ន្ធដាច់ដោយឡែក ("ឬ") ដែលក្របខ័ណ្ឌច្បាប់របស់តុលាការ ICC អាចរាប់រួមមានទាំងមេដឹកនាំជាន់ខ្ពស់ និងអ្នកដែលជាប់ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មដែលធ្ងន់ធ្ងរ ឬសាហាវបំផុត" ថាជា "ការទទួលខុសត្រូវខ្ពស់បំផុត"។

៦៨. ដោយយោងទៅលើសម្អាងហេតុទាំងអស់នេះហើយ សហព្រះរាជអាជ្ញាអន្តរជាតិសូមលើកឡើងដោយគោរពថា ដីកាសម្រេចសម្អាងតែទៅលើសេចក្តីសម្រេចស្មានៗ ចំពោះយុត្តាធិការបុគ្គលដែលបានយោងទៅលើការបកស្រាយច្បាប់មិនបានត្រឹមត្រូវ និងតម្រូវឱ្យមានបទដ្ឋាននៃការពិនិត្យឡើងវិញពីសំណាក់ អ.ប.ជ។

### *iii. ដីកាសម្រេចបានសម្អាងទៅលើសេចក្តីសន្និដ្ឋានដែលមិនត្រឹមត្រូវទាល់តែសោះ ទាក់ទងទៅនឹងតួនាទីតាមឋានានុក្រម និងឋានៈរបស់ជនសង្ស័យ និងភាពជាក់ស្តែង ឬភាពធ្ងន់ធ្ងរនៃអំពើព្រហ្មទណ្ឌរបស់ពួកគេ ដែលត្រូវបានចោទប្រកាន់នេះ*

៦៩. ដីកាសម្រេចលើកឡើងថា ជនសង្ស័យគឺជាមេបញ្ជាការកងពលធំ ដែលមានចំនួនមិនតិចជាង ៩ កងពលធំ (បន្ថែមកងវរៈសេនាធំស្វ័យតចំនួន ៣)"[120]។ ដោយយោងទៅលើមូលដ្ឋាននេះ សហចៅក្រមស៊ើបអង្កេតសន្និដ្ឋានថា "វាមិនសមហេតុសមផលទាល់តែសោះ" ដើម្បីឱ្យសហព្រះរាជអាជ្ញាអន្តរជាតិពិចារណាថា ជនសង្ស័យជាមេដឹកនាំជនខ្ពស់នោះទេ[121]។ ដីកាសម្រេចក៏ហាក់បីដូចជាបដិសេធលទ្ធភាពដែលថា ជនសង្ស័យគឺស្ថិតនៅក្នុងចំណោម "អ្នកដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មទាំងនោះ។

---

[118] ឯកសារគោលនយោបាយស្តីពីអត្ថប្រយោជន៍នៃយុត្តិធម៌, កញ្ញា ២០០៧, online: www.icc-cpi.int, ទំព័រទី៧ ។

[119] *ក្នុងឯកសារដដែលដូចខាងលើ,* ត្រង់កថាខ័ណ្ឌទី៧ (សង្កត់ន័យត្រង់អក្សរទ្រេត) ។

[120] **D26** ដីកាសម្រេច, កំណត់សំគាល់*ខាងដើមលេខ២* ត្រង់កថាខ័ណ្ឌទី៦ (គ) ។

[121] *ដូចគ្នានឹងខាងលើ*។

៧០. ទីមួយ ដីកាសម្រេចនេះមានកំហុសដោយការផ្តោតតែទៅលើតួនាទីរបស់ជនសង្ស័យក្នុងឋានៈជាមេបញ្ជាការកងទ័ពតែមួយមុខ ហើយមិនបានយកចិត្តទុកដាក់ទៅលើតួនាទី និងការទទួលខុសត្រូវដទៃទៀតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដូចជា តួនាទីរបស់ពួកគេនៅក្នុងគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ជាដើម។ មាត្រា ៧.១ និងមាត្រា ២៣ នៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាចែងថា គណៈកម្មាធិការមជ្ឈិមបក្សគឺជា "អង្គភាពប្រតិបត្តិខ្ពស់បំផុតនៅទូទាំងប្រទេសកម្ពុជា" ដែលទទួលខុសត្រូវអនុវត្តមាគ៌ានយោបាយរបស់បក្ស" ណែនាំភូមិភាគ និងតំបន់ព្រមទាំងគ្រប់គ្រង "កម្មាភិបាល និងសមាជិកបក្សទាំងអស់"[122]។ វាច្បាស់ហើយថា សេចក្តីព្រាងជាប្រវត្តិសាស្ត្រនៃកិច្ចព្រមព្រៀងបង្កើត អ.វ.ត.ក ដូចបានលើកឡើងខាងរួចមកហើយ ពាក្យថា "មេដឹកនាំជាន់ខ្ពស់" គឺមិនមែនកម្រិតត្រឹមតែសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែ ក៏មានបំណងគ្របដណ្តប់ទៅលើសមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្សផងដែរ ដូចជា ខៀវ សំផន កែ ពក និងជនសង្ស័យនៅក្នុងសំណុំរឿង ០០៣[123]។

៧១. ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ច បំពេញកិច្ចស៊ើបសួរប្រកបដោយហេតុផលដើម្បីពិចារណាទៅលើសមាជិកនានានៃគណៈកម្មាធិការមជ្ឈិមបក្ស ដែលត្រូវបានតែងតាំងនៅក្នុងមហាសន្និបាតបក្សលើកទី ៤ ក្នុងខែមករា ឆ្នាំ ១៩៧៦ និងមហាសន្និបាតបក្សលើកទី ៥ ក្នុងខែតុលា ឆ្នាំ ១៩៧៨[124]។ ខៀវ សំផន ដែលជាសមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្ត

[122] ឯកសារលេខ **D1.3.22.1** ឯកសារច្បាប់របស់ បកក ដែលមានចំណងជើងថា "លក្ខន្តិកៈនៃបក្សកុម្មុយនីស្តកម្ពុជា", ចុះកាលបរិច្ឆេទខែមករា ១៩៧៦, ត្រង់លេខ ERN 00184038, 00184045។ ឯកសារលេខ **D427** ដីកាដំណោះស្រាយ, ចុះថ្ងៃទី១៥ កញ្ញា ២០១០, ERN 00604508-5246, កថាខណ្ឌទី៣៧ ("ដីកាដំណោះស្រាយនៃសំណុំរឿងលេខ០០២")។

[123] កិច្ចពិភាក្សារបស់រដ្ឋសភា, កំណត់សំគាល់លេខ៨៩ ខាងលើ ត្រង់ ERN 00315508 (ដែលយោងទៅលើការយល់ថា "មេដឹកនាំជាន់ខ្ពស់" នឹងរួមមានចំនួនរហូតទៅដល់១០នាក់ ហើយដែលមិនកំរិតត្រឹមតែ "សមាជិកនានានៃគណៈកម្មាធិការអចិន្ត្រៃយ៍" នោះឡើយ)។ លោក Heder, កំណត់សំគាល់លេខ ៩៤ ខាងលើ ត្រង់កថាខណ្ឌទី ២៣-២៤,២៧, ៣៧-៣៨។

[124] ឯកសារលេខ **D1.3.22.1** ឯកសារច្បាប់របស់ បកក ដែលមានចំណងជើងថា "លក្ខន្តិកៈនៃបក្សកុម្មុយនីស្តកម្ពុជា", ចុះកាលបរិច្ឆេទខែមករា ១៩៧៦, លេខ ERN 00184022-47 ត្រង់លេខ ERN 00184044-45 [ដែលចែងថា៖ "មហាសន្និបាត" ឬសមាជរបស់បក្ស ត្រូវធ្វើឡើងយ៉ាងហោចណាស់រៀងរាល់បួនឆ្នាំម្តងដើម្បីធ្វើការចាត់តាំងសមាជិករបស់មជ្ឈិមបក្ស]។ ឯកសារលេខ **D4.1.871** ទស្សនាវដ្តីទង់បដិវត្តន៍ការចេញផ្សាយរបស់ បកក, ប្រចាំខែកញ្ញា ឆ្នាំ១៩៧៨, ERN 00488614-40 ត្រង់លេខ ERN 00488633 (ដែលយោងទៅលើសមាជរបស់បក្សក្នុងខែមករា ឆ្នាំ១៩៧៦)។ ឯកសារ **D1.3.33.15** កំណត់ហេតុសួរចម្លើយ ខៀវ

កម្ពុជាតែម្នាក់គត់ ដែលបានផ្តល់សក្ខីកម្មជូន អ.វ.ត.ក ក្នុងការកំណត់អត្តសញ្ញាណរបស់សមាជិកដទៃទៀតនោះ បានលើកឡើងថា មាស មុត គឺជាសមាជិកម្នាក់ ក្នុងចំណោមសមាជិកពេញសិទ្ធិចំនួន ៣០ នាក់របស់គណៈកម្មាធិការមជ្ឈិមបក្ស[125]។ គាត់ក៏បាននិយាយផងដែរថា គណៈកម្មាធិការមជ្ឈិមបក្ស រួមមានជាចម្បង លេខាភូមិភាគ លេខាតំបន់ និងអង្គភាពកងទ័ព[126]។ សហចៅក្រមស៊ើបអង្កេត បានបដិសេធសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលបានស្នើសុំឱ្យសម្ភាសន៍ ខៀវ សំផន នៅក្នុងសំណុំរឿង ០០៣[127] ដែលមិនទាន់បានសួរ ខៀវ សំផន ឱ្យដឹងនៅឡើយថាតើ ស៊ូ មេត គឺជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្សដែរឬអត់នៅឡើយទេ។

៧២. ទោះបីជាយ៉ាងណាក៏ដោយ តួនាទីរបស់ ស៊ូ មេត អាចសន្និដ្ឋានយកចេញពីចម្លើយរបស់ កាំង ហ្កេក អ៊ាវ ហៅ ឌុច ដែលត្រូវបានគេប្រាប់គាត់នៅក្នុងឆ្នាំ ១៩៧៥ ថា ស៊ូ មេត និង មាស មុត ត្រូវបានជ្រើសរើសឱ្យធ្វើជា "ជំនួយការ" ឱ្យគណៈកម្មាធិការមជ្ឈិមបក្ស[128]។ ដោយសារតែជាងពាក់កណ្តាលនៃគណៈកម្មាធិការមជ្ឈិមបក្ស ត្រូវបានចាប់ខ្លួន និងសម្លាប់ចោលនៅចន្លោះពីឆ្នាំ

---

សំផន, ចុះថ្ងៃទី១៣ ធ្នូ ឆ្នាំ២០០៧, ERN 00156741-51 ត្រង់លេខ ERN 00156750-51។ ឯកសារលេខ **D1.3.30.29** ការធ្វើសម្ភាសន៍ពួកជនភៀសខ្លួនកម្ពុជានៅតាមព្រំដែនកម្ពុជា-ថៃ ក្នុងខែកុម្ភៈ-មិនា ឆ្នាំ១៩៨០, ERN 00170692-773 ត្រង់លេខ ERN 00170749-50 [ការធ្វើសម្ភាសន៍ឈ្មោះ ចាប ឡុញ (Chap Lonh), ដែលជាអ្នកចូលរួមម្នាក់ក្នុងចំណោម ៦០នាក់ នៅក្នុងអង្គសមាជរបស់បក្សលើកទី៥ នៅក្នុងឆ្នាំ១៩៧៨]។

[125] ឯកសារ **D1.3.33.15** កំណត់ហេតុសួរចម្លើយ ខៀវ សំផន, ចុះថ្ងៃទី១៣ ធ្នូ ឆ្នាំ២០០៧, ERN 00156741-51 ត្រង់លេខ ERN 00156751។

[126] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ **4.23 ខៀវ សំផន** , *ប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាក្នុងពេលថ្មីៗនេះ និងអំពីមូលហេតុដែលស្ថិតនៅពីក្រោយសេចក្តីសំរេចដែលខ្ញុំបានធ្វើ Cambodia's Recent History and the Reasons Behind the Decisions I Made*, ERN0010371-801 at ERN 00103785។ ដូចគ្នានឹងខាងលើ ត្រង់លេខ ERN 00156750។ សូមអានផងដែរ ឯកសារលេខ **D427** ដីកាដំណោះស្រាយនៃសំណុំរឿងលេខ០០២, កំណត់សំគាល់លេខ១២២ *ខាងលើ* ត្រង់កថាខណ្ឌទី៣៨ (" លេខាភូមិភាគផ្សេងៗទៀត និងយ៉ាងហោចណាស់ក៏មានលេខាតំបន់មួយចំនួនជាសមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្សដែរ ព្រមជាមួយនឹងកម្មាភិបាលយោធាមួយចំនួនបន្ថែមទៀត")។

[127] ឯកសារលេខ **D18** សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមលើកទី២, កំណត់សំគាល់លេខ១៧ ត្រង់កថាខណ្ឌទី១៥។

[128] ឯកសារលេខ **D1.3.33.10** កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច, ចុះថ្ងៃទី២ មិថុនា ២០០៨, ERN 00195571-00195579 ត្រង់លេខ ERN 00195577 (ដែលក្នុងនោះនិយាយថា ឌុច បានទទួលពត៌មាននេះពីឈ្មោះ អ៊ិន លន *ហៅ* ណាត (In Lorn *alias* Nat ) នៅចុងឆ្នាំ១៩៧៥)។ ឯកសារលេខ **D12** កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច, ចុះថ្ងៃទី២៧ មេសា ២០១១, ERN 00680795-99 ត្រង់លេខ ERN 00680796។

១៩៧៦ និង ១៩៧៨[129] នោះវាទំនងជាថា ស៊ូ មេត (ក៏ដូចជា មាស មុត) ត្រូវបានតម្លើងឋានៈជាសមាជិកពេញសិទ្ធិនៅក្នុងមហាសន្និបាតបក្សកាលពីដើមឆ្នាំ ១៩៧៦ ឬ ១៩៧៨[130]។ តួនាទីរបស់ ស៊ូ មេត នៅក្នុងគណៈកម្មាធិការមជ្ឈិមបក្ស ក៏ត្រូវបានបង្ហាញឱ្យដឹងផងដែរ តាមរយៈការចូលរួមរបស់គាត់នៅក្នុងកិច្ចប្រជុំមួយចំនួនជាមួយប្រធានាធិបតីប្រទេសភូមា នៅក្នុងខែវិច្ឆិកា ឆ្នាំ ១៩៧៧ ដែលជាផ្នែកមួយនៃក្រុមមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ ដែលក្នុងនោះរួមមាន នួន ជា អៀង សារី ខៀវ សំផន វន វេត សុន សេន និង អៀង ធីរិទ្ធ[131]។

៧៣. បន្ថែមទៅលើតួនាទីរបស់គាត់ជាមេបញ្ជាការកងពលធំលេខ ១៦៤ និងជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស មាស មុត ក៏ជាលេខានៃគណៈកម្មាធិការក្រុងកំពង់សោម[132]។ នៅក្នុងឆ្នាំ ១៩៧៧ ឬ ១៩៧៨ មាស មុត ត្រូវបានផ្លាស់ប្តូរមកកាន់ទីក្រុងភ្នំពេញ និងមានការទទួលខុសត្រូវ

---

[129] ឯកសារលេខ **D427** ដីកាដំណោះស្រាយនៃសំណុំរឿងលេខ០០២, កំណត់សំគាល់លេខ១២២ ខាងលើ, ត្រង់កថាខណ្ឌលេខ៣៨។ ឯកសារលេខ **D4.1.950** បញ្ជីឈ្មោះអ្នកទោសស-២១ ដែលត្រូវបានពិនិត្យឡើងវិញ, ចុះថ្ងៃទី១៩ ឧសភា ២០០៩, ERN 00329596-00330129 ត្រង់លេខ ERN 00329602 ( បួន ណាន *ហៅ* យី Baun Nan *alias* Yi), ERN 00329605 (ប៊ូ ផាត *ហៅ* ហាង់ Bou Phat *alias* Hâng), 00329617 (ចាន់ សម *ហៅ* កង ចាប *ហៅ* សែ Chan Sam *alias* Kang Chap *alias* Sè), 00329661 ( ជូ ជេត *ហៅ* ស៊ី Chou Chet *alias* Sy), 00329775 (កុយ ធួន Koy Thuon), 00329819 (ម៉ែន សាន *ហៅ* យ៉ា Mèn San *alias* Ya), 00329902 (ប៉ា ផល *ហៅ* សូត Pa Phâl *alias* Sot), 00329928 (សុខ សុផុន *ហៅ* ភួង Sok Sophon *alias* Phuong), 00329987 (សៀត ឆែ *ហៅ* ទុំ Seat Chhae *alias* Tum), 00330011 (ស៊ឿ វ៉ាស៊ី *ហៅ* ឌឿន Seua Vasi *alias* Doeun), 00330039 ( សួសនៅ *ហៅ* ឈូក Suos Nov *alias* Chhouk)។ ឯកសារលេខ **D10.1.5** S-21 ចម្លើយសារភាពរបស់ មូល សម្បត្តិ *ហៅ* រស់ ញឹម Muol Sambath *alias* Ros Nhim, ចុះថ្ងៃទី១៤ មិថុនា ១៩៧៨។

[130] ឯកសារលេខ **D4.1.4** អត្ថបទរបស់លោក Timothy Carney, *អង្គការនៃអំណាច The Organisation of Power*, នៅក្នុងសៀវភៅរបស់លោក Karl D. Jackson, ដែលមានចំណងជើងថា ប្រទេសកម្ពុជាពីឆ្នាំ១៩៧៥-១៩៧៨៖ ការណាត់ជួបជាមួយសេចក្តីមរណៈ, ឆ្នាំ១៩៨៩, ERN 00105126-156 ត្រង់លេខ ERN00105152។ កំណត់សំគាល់លេខ ៩៣ *ខាងលើ*, ទំព័រ ១៤ ។ ឯកសារលេខ **D1.3.17.6** លោក Stephen Heder និងលោក Brian Tittemore, សៀវភៅដែលមានចំណងជើថា *បេក្ខជនចំនួនល្បូបសំរាប់ធ្វើការកាត់ទោស៖ ការទទួលខុសត្រូវរបស់ពួកខ្មែរក្រហមចំពោះឧក្រិដ្ឋកម្ម (Seven Candidates for Prosecution: Accountability for the Crimes of the Khmer Rouge)*, ឆ្នាំ២០០៤, ត្រង់លេខ ERN 00393603-04។

[131] ឯកសារលេខ **D262.36**, របាយការណ៍របស់អង្គការផ្សាយព័ត៌មាននៃកម្ពុជាប្រជាធិបតេយ្យសំរាប់ខែវិច្ឆិកា ឆ្នាំ១៩៧៧ (FBIS), ERN 00168544-610 ត្រង់លេខ ERN 00168599-605។

[132] ឯកសារលេខ **D196.12**, របាយការណ៍របស់អង្គការផ្សាយព័ត៌មាននៃកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា "ទស្សនកិច្ចរបស់គណៈប្រតិភូចិននៅតំបន់កំពង់សោម," ចុះថ្ងៃទី១៣ ធ្នូ ១៩៧៧, ERN 00168307-399 ត្រង់លេខ ERN 00168349។

ដោយផ្ទាល់ជាមួយគណៈកម្មាធិការមជ្ឈិមបក្ស[133]។ នៅចុងឆ្នាំ ១៩៧៨ ប្រហែលវាជាផ្នែកមួយនៃការទទួលខុសត្រូវរបស់គាត់នៅក្នុងគណៈកម្មាធិការមជ្ឈិមបក្សក្នុងការ "គ្រប់គ្រង និងចាត់ចែងកម្មាភិបាល" មាស មុត បានសម្របសម្រួលដល់ការដាក់ជំនួយលេខាស្រុក និងលេខាតំបន់ដែលត្រូវបានបោសសម្អាតនៅខេត្តក្រចេះ (តំបន់ ៥០៥)[134]។

៧៤. ក្នុងករណីណាក៏ដោយ បើទោះបីជាពួកគេជាសមាជិកពេញសិទ្ធិ ជាសមាជិកត្រៀម ឬជាសមាជិកជំនួយការក្តី ក៏យ៉ាងហោចណាស់ មាស មុត និង ស៊ូ មេត មានឋានៈខ្ពស់នៅក្នុងឋានានុក្រមបក្សកុម្មុយនីស្តកម្ពុជាដូច អៀង ធីរិទ្ធ ដែលមិនមានតួនាទីច្បាស់លាស់នៅក្នុងគណៈកម្មាធិការមជ្ឈិមបក្ស ដែលជារដ្ឋមន្ត្រីម្នាក់ ក្នុងចំណោមរដ្ឋមន្ត្រីមិនតិចជាងប្រាំបួននាក់ ដែលត្រូវបានចាត់ទុកថាជា "មេដឹកនាំជាន់ខ្ពស់" ដោយសហចៅក្រមស៊ើបអង្កេតនៅក្នុសំណុំរឿង ០០២[135]។

៧៥. សហចៅក្រមស៊ើបអង្កេតមានកំហុសបន្ថែមទៀត ដោយការខកខានមិនបានពិចារណាថា អំណាច និងការទទួលខុសត្រូវរបស់ មាស មុត និង ស៊ូ មេត បានកើនឡើងនៅក្នុងអំឡុងនៃកម្ពុជាប្រជាធិបតេយ្យ ដែលក្នុងនោះមេបញ្ជាការកងពលធំចំនួន ៩ ទៀត ត្រូវបានបោសសំអាត ហើយកងពលរបស់ពួកគេត្រូវបានច្របាច់បញ្ចូលចេញពីកងពលដែលមានស្រាប់។ លេខាកងពលធំលេខ ១៧០, ៣១០ និង ៤៥០ ត្រូវបានចាប់ខ្លួន និងសម្លាប់ចោលទាំងអស់នៅក្នុងឆ្នាំ ១៩៧៦ ឬ

[133] ឯកសារលេខ **D2/23** របាយការណ៍របស់ កសចស ស្តីពីការកំណត់អត្តសញ្ញាណនៃទីតាំងកន្លែងយកថ្មនៅស្ទឹងហាវ, ចុះថ្ងៃទី៣០ ធ្នូ ២០១០, ERN 00644146-84 នៅត្រង់ ERN 00644147-48 (លេខ ៤)។ ឯកសារលេខ **D2/22** របាយការណ៍របស់ កសចស ស្តីពីការកំណត់អត្តញ្ញាណនៃទីតាំងមន្ទីរសន្តិសុខវត្តឥន្ទញាណ, ចុះថ្ងៃទី២៩ ធ្នូ ២០១០, ERN 00634138-76 ត្រង់លេខ ERN 006341-42 [ដែលក្នុងនោះនិយាយថា មុត ត្រូវបានចាត់តាំងសារជាថ្មីឱ្យទៅទីក្រុងភ្នំពេញនៅក្នុងឆ្នាំ ១៩៧៨]។ ឯកសារលេខ **ERF 979** ចម្លើយរបស់ មាស មុត, ចុះថ្ងៃទី៥ ធ្នូ ២០០១, ERN 00249692-700 ត្រង់លេខ 00249695 [ដែលនិយាយថា គាត់បានគេ "បញ្ជូនឱ្យទៅទីក្រុងភ្នំពេញ" នៅក្នុងឆ្នាំ១៩៧៧], ដែលត្រូវបានដាក់ជូនជាឯកសារលេខ ១៨១ នៅក្នុងឯកសារលេខ **D17.2**, ERN 00698725។

[134] ឯកសារលេខ **D4.1.810** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ សេង សឿន( Seng Soeun), ចុះថ្ងៃទី១១ វិច្ឆិកា ២០០៩, ERN 00412176-87 ត្រង់លេខ ERN 00412180-81។

[135] ឯកសារលេខ **D427** ដីកាដំណោះស្រាយក្នុងសំណុំរឿងលេខ០០២, កំណត់សំគាល់លេខ១២២ ត្រង់កថាខណ្ឌលេខ ១៣២៧។

១៩៧៧[136]។ ដូចដែលបានទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០២ "កងពលធំមជ្ឈិមទាំងអស់ត្រូវបានបោសសម្អាតយ៉ាងធ្ងន់ធ្ងរ ដែលនាំឱ្យមានការចាត់តាំងពួកគេឡើងវិញជាបន្តបន្ទាប់ ឬដាក់បញ្ចូលគ្នាជាមួយនឹងកងពលដទៃទៀត"[137]។ ជាឧទាហរណ៍ ការទទួលខុសត្រូវ និងអំណាចពាក់ព័ន្ធរបស់ ស៊ូ មេត បានកើនឡើងយ៉ាងខ្លាំងនៅពេលដែលកងពលធំលេខ ៦០៥ និង ៧០៣ ត្រូវបានរំលាយចោល (ក្រោយពីមេៗរបស់ពួកគេត្រូវបានចាប់ខ្លួន) ហើយត្រូវបានច្របាច់បញ្ចូលទៅក្នុងកងពលធំលេខ ៥០២[138]។ អតីតកម្មាភិបាលកងពលធំលេខ ៥០២ បានរៀបរាប់ថា ស៊ូ មេត មាន*ឋានៈជាក់ស្តែង*លេខ ២ បន្ទាប់ពី សុន សេន" ហើយគាត់មានវត្តមានជាញឹកញាប់នៅឯអគ្គសេនាធិការការរដ្ឋានក្នុងទីក្រុងភ្នំពេញ[139]។

៧៦. នៅពេលដែលលក្ខខណ្ឌតម្រូវទៅលើ "មេដឹកនាំជាន់ខ្ពស់" ត្រូវបានចរចារ និងយល់ថា អនុញ្ញាតឱ្យមានការចោទប្រកាន់រហូតដល់ ១០ នាក់ នោះ មាស មុត និង ស៊ូ មេត គឺ ធ្លាប់ និងនៅតែជាមេដឹកនាំកងទ័ពបដិវត្តន៍កម្ពុជាដែលនៅរស់រានមានជីវិត។ មេដឹកនាំកងទ័ពបដិវត្តន៍កម្ពុជាដែលមានឋានៈខ្ពស់ជាងជនសង្ស័យទាំងនេះ គឺ សុន សេន ថ្នាក់លើផ្ទាល់របស់ពួកគេ ដែលជា

[136] **D4.1.950**, បញ្ជីឈ្មោះអ្នកទោសទួលស្លែង-២១ ដែលបានពិនិត្យឡើងវិញ របស់ កសត, លេខERN 00329596-00330129 ត្រង់លេខ ERN 00329613, 00329627, 00329986 [លេខ 416, 714 និង 8967] ។ **D4.1.22**, ចម្លើយសារភាពទួលស្លែង-២១ របស់ ចាន់ ចក្រី *ហៅ* នៅ មាន (Chan Chakrey *alias* Nov Mean), ថ្ងៃទី១ មិថុនា ១៩៧៦ [ចាប់ខ្លួន ថ្ងៃទី១៩ ឧសភា ១៩៧៦] លេខERN 00183019-85 ។ **D4.1.651**, ចម្លើយសារភាពទួលស្លែង-២១ របស់ ចាន់ ចក្រី *ហៅ* នៅ មាន (Chan Chakrey *alias* Nov Mean), ថ្ងៃទី៣០ សីហា ១៩៧៦, លេខERN 00030985-00032842 ។ **ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 5.89**, ចម្លើយសារភាពទួលស្លែង-២១ របស់ ស្បូវ ហ៊ីម *ហៅ* អឿន (Sbauv Him *alias* Euan) ។ **D4.1.32**, ចម្លើយសារភាពទួលស្លែង-២១ របស់ ជា ណុន *ហៅ* សួង (Chea Non *alias* Suong), ថ្ងៃទី២៣ មីនា ១៩៧៧, លេខERN 00096949-93 ។

[137] **D427**, ដីកាដំណោះស្រាយលើសំណុំរឿងលេខ ០០២, កំណត់សម្គាល់*ខាងលើ* លេខ១២២ ត្រង់កថាខណ្ឌទី ១៣១ ។

[138] **D2/18**, កំណត់ហេតុនៃការស្តាប់ចម្លើយរបស់ ស្រេង ធី (Sreng Thi), ថ្ងៃទី១ ធ្នូ ២០១០, លេខ ERN 00630429–36 ត្រង់លេខ ERN 00630434-35 ។

[139] **D1.3.13.7**, SOAS/HRW សម្ភាសឈ្មោះ ប៊ិច ដារី *ហៅ* រី (Pech Dari *alias* Ri), ថ្ងៃទី២៧ កក្កដា ២០០៥, លេខERN 00207714-15 ។ **D4.1.845**, កំណត់ហេតុនៃការស្តាប់ចម្លើយរបស់ ឡុញ ដុស (Lonh Dos), ថ្ងៃទី២០ វិច្ឆិកា ២០០៩, ត្រង់លេខERN 00407792 ។

នាយអគ្គសេនាធិការ[140]។ ក្នុងឋានៈជាមេបញ្ជាការកងទ័ពជើងអាកាស និងជាលេខាកងពលធំលេខ ៥០២[141] ស៊ូ មេត យ៉ាងហោចណាស់ក៏បានគ្រប់គ្រង ១២ កងវរៈសេនាតូច ដែលមានកងទ័ពសរុបចំនួនរវាង ៥.០០០ នាក់ និង ៦.០០០ នាក់ដែរ[142]។ ក្នុងឋានៈជាមេបញ្ជាការកងទ័ពជើងទឹក និងជាលេខាកងពលធំលេខ ១៦៤[143] មាស មុត បានគ្រប់គ្រងយ៉ាងហោចណាស់ក៏ ១២ កងវរៈសេនាតូច ដែលមានកងទ័ពសរុបចំនួនចន្លោះពី ៨.៥០០ នាក់ ទៅ ១០.០០០ នាក់ដែរ[144]។

៧៧. កងទ័ពបដិវត្តន៍កម្ពុជាមានតួនាទីចម្បងនៅក្នុងឧក្រិដ្ឋកម្មដ៏ធំធេង ដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ។ ក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០២ សហចៅក្រមស៊ើប

---

[140] **D427**, ដីកាដំណោះស្រាយលើសំណុំរឿងលេខ ០០២, កំណត់សម្គាល់*ខាងលើ* លេខ១២២ ត្រង់កថាខណ្ឌទី ៣៨៦ ។ **D4.1.855**, កំណត់ហេតុនៃការស្តាប់ចម្លើយរបស់ ឡុញ ដុស (Lonh Dos), ត្រង់លេខERN 00364071 ។ **D4.1.845**, កំណត់ហេតុនៃការស្តាប់ ចម្លើយរបស់ ឡុញ ដុស (Lonh Dos), ត្រង់លេខERN 00407792 ។

[141] **D427**, ដីកាដំណោះស្រាយលើសំណុំរឿងលេខ ០០២, កំណត់សម្គាល់*ខាងលើ* លេខ១២២ ត្រង់កថាខណ្ឌទី ៣៨៦ ។ **D4.1.841**, កំណត់ហេតុនៃការស្តាប់ចម្លើយរបស់ សុខ ឆាយ (Sokh Chhay), ត្រង់លេខERN 00404291 ។ **D4.1.837**, កំណត់ហេតុនៃការស្តាប់ ចម្លើយរបស់ ហេន សុផល (Hen Sophal), ត្រង់លេខERN 00374046 ។ **D4.1.601**, កំណត់ហេតុនៃការស្តាប់ចម្លើយរបស់ សេង ម៉ុន (Seng Mon), ត្រង់លេខERN 00288621 ។

[142] **D1.3.5.18**, របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា *បញ្ជីកម្លាំងយោធាប្រចាំខែឧសភា ឆ្នាំ១៩៧៦*, ថ្ងៃទី៥ មិថុនា ១៩៧៦, ត្រង់លេខERN 00509700 (សរុប 5,684 នាក់) ។ **D1.3.5.21**, របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ដែលមាន ចំណងជើងថា *បញ្ជីកងកម្លាំងប្រចាំខែតុលា ឆ្នាំ១៩៧៦*, ថ្ងៃទី២៥ តុលា ១៩៧៦, ត្រង់លេខERN 00233924 [សរុប 5,599 នាក់] ។ **D1.3.30.5**, របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា *បញ្ជីស្ថិតិស្តីពីគួរៀនសូត្រលើកទីមួយនៅអគ្គសេនា - Table of Statistics on Students Studying at the First General Staff Study Session*, ថ្ងៃទី២០ តុលា ១៩៧៦, ត្រង់លេខERN 00095532-43 ។ **D4.1.396**, របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា *វគ្គរៀនសូត្រលើកទីពីរនៅអគ្គសេនា - Second General Staff Study Session*, ថ្ងៃទី២៣ វិច្ឆិកា ១៩៧៦, ត្រង់លេខERN 00195326-27 ។

[143] **D2/9**, កំណត់ហេតុនៃការស្តាប់ចម្លើយរបស់ សយ ប៊ិន, ត្រង់លេខERN 00613021 ។ **D2/16**, កំណត់ហេតុនៃការស្តាប់ចម្លើយរបស់ ទូច សឿលី, ត្រង់លេខERN 00629463 ។

[144] **D1.3.5.3**, របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា *បញ្ជីកម្លាំងប្រចាំថ្ងៃទី២៧ តុលា ១០៧៦ - Daily List of Forces 27 October 1976*, ថ្ងៃទី២៧ តុលា ១៩៧៦, ត្រង់លេខERN 00233989 (បានកំណត់អត្តសញ្ញាណកងវរសេនាធំចំនួន ៤កង និង កងវរសេនាតូចចំនួន ៦កង សរុបចំនួន 8,611 នាក់) ។ **D1.3.11.3**, *បញ្ជីឈ្មោះអ្នកត្រូវចាប់ខ្លួនក្នុងកងពលធំលេខ ១៦៤ របស់ កសព - OCP List of Arrestees from Division 164*, ថ្ងៃទី២៥ មករា ២០០៨, លេខERN 00196162-78 ។ **D1.3.33.16**, ចម្លើយរបស់ មាស មុត, ថ្ងៃទី២០ កក្កដា ២០០១, ត្រង់លេខERN 00089661 (ដោយបានថ្លែងថាមាន "ប្រហែលជាង ១០.០០០ នាក់" នៅក្នុងកងពល របស់គាត់) ។

អង្កេតបានរកឃើញយ៉ាងច្បាស់ថា កងទ័ពបដិវត្តន៍កម្ពុជាគឺជា "ស្ថាប័នស្នូល" នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារ "គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាបានសម្ពាងយ៉ាងខ្លាំងទៅលើការអនុវត្តទិសដៅរបស់ខ្លួន តាមមធ្យោបាយបង្ខិតបង្ខំ"[145] ហើយសមាជិកទាំងឡាយនៃសហឧក្រិដ្ឋកម្មរួម រួមមាន "មេដឹកនាំកងពលនៃកងទ័ពមជ្ឈិមបក្ស" ក៏ដូចជា គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មាធិការមជ្ឈិមបក្ស លេខាភូមិភាគ និងលេខាតំបន់ស្វ័យតផងដែរ"[146]។ សហចៅក្រមស៊ើបអង្កេតក៏បានសន្និដ្ឋានផងដែរថា វាជា "ការចូលរួមដោយផ្ទាល់របស់ជនជាប់ចោទនៅក្នុងការអនុវត្ត" សហឧក្រិដ្ឋកម្មរួមនេះ ដែលនាំឲ្យពួកគេក្លាយជាផ្នែកមួយនៃ "ប្រភេទនៃអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភធ្ងន់ធ្ងរ ដែលបានប្រព្រឹត្តឡើងនៅចន្លោះពីថ្ងៃទី ១៧ មេសា ១៩៧៥ ដល់ថ្ងៃទី ៦ មករា ១៩៧៩" [147]។

៧៨. នៅក្នុងករណីនេះ មានឯកសារនានាជាច្រើននាសម័យនោះដែលបានបង្ហាញពីការចូលរួមរបស់ មាស មុត[148] និង ស៊ូ ម៉េត[149] នៅក្នុងសហឧក្រិដ្ឋកម្មរួមនោះរួមមាន៖ ការប្តេជ្ញាចិត្តរបស់ មាស មុត ផ្ញើជូនមន្ទីរ ៨៧០ (គណៈកម្មាធិការអចិន្ត្រៃយ៍) ដើម្បី "បោសសំអាតគ្មានស្ទាក់ស្ទើរសមាសភាពបង្កប់របស់ខ្មាំង ជាយួននិងខ្មាំងដទៃទៀត"[150] និង សេចក្តីថ្លែងការណ៍របស់ ស៊ូ ម៉េត ផ្ញើជូន សុន សេន និងមេបញ្ជាការកងពលធំដទៃៗទៀតដែលជំរុញថា "ដាច់ខាតត្រូវចាត់វិធានការបន្ថែម" ដើម្បីកម្ទេចខ្មាំង ប.ក.ក[151]។ ជនសង្ស័យទាំងពីររូបបានចូលរួមជាទៀងទាត់ក្នុងការ

[145] **D427**, ដីកាដំណោះស្រាយលើសំណុំរឿងលេខ ០០២, កំណត់សម្គាល់*ខាងលើ* លេខ១២២ ត្រង់កថាខណ្ឌទី ១១៣ និង ១៩៧ (បានរកឃើញផងដែរថា ការទទួលខុសត្រូវរបស់កងទ័ពបដិវត្តកម្ពុជា គឺការពារប្រទេសពី "ពួកខ្មាំងផ្ទៃក្នុង" និង "បន្តុកទេច") ។

[146] *ដដែលដូចមុន,* កថាខណ្ឌទី ១៥៩, ១៥២៩ ។

[147] *ដដែលដូចមុន,* កថាខណ្ឌទី ១៣២៨ ។

[148] សូមមើលឯកសារនានាដែលបានកំណត់អត្តសញ្ញាណនៅក្នុងកំណត់សម្គាល់ជើងទំព័រទី ៦៤ នៃ **D19**, សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរលើកទីបី, កំណត់សម្គាល់*ខាងលើ* លេខ១៨ ។

[149] សូមមើលឯកសារនានាដែលបានកំណត់អត្តសញ្ញាណនៅក្នុងកំណត់សម្គាល់ជើងទំព័រទី ៩-១០ និង ៣៥-៣៨ នៃ **D18**, សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរលើកទីពីរ, កំណត់សម្គាល់*ខាងលើ* លេខ១៧ ។

[150] **D1.3.34.60**, សារទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យ ពី មុត ផ្ញើទៅ ម-៨៧០, ថ្ងៃទី៣១ ធ្នូ ១៩៧៧, លេខERN 00184995 ។

[151] **D1.3.27.20**, កំណត់ហេតុនៃការប្រជុំ លេខា និងអនុលេខាកងពលធំ និងកងវរៈសេនាធំឯករាជ, ថ្ងៃទី៩ តុលា ១៩៧៦, ត្រង់លេខERN 00183990 (បានកត់ត្រាផងដែរពី មាស មុត បាន "ឯកភាពទាំងស្រុង" ជាមួយបក្ស ហើយបានរំលឹកថា "គ្មានសមាសភាពមិនល្អ ឬសមាសភាពខ្មាំង នៅតែលាក់ខ្លួន និងជ្រៀតចូលក្នុងជួរទេ") ។

ប្រជុំនៅអគ្គសេនាធិការ ដែលពិភាក្សាពីការកម្ទេចខ្មាំង[152] និងបានដាក់ជូនរបាយការណ៍ស្តីពីការខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការកំណត់អត្តសញ្ញាណ និង សម្រិតសម្រាំងខ្មាំងក្នុងជួរ[153]។ ចម្លើយសារភាពនៅមន្ទីរ ស២១ ត្រូវបានផ្ញើជូនទៅ ស៊្វ ម៉េត[154] និង មាស មុត[155] ដែលពេលនោះ ពួកគេបានធ្វើការយ៉ាងជិតស្និទ្ធជាមួយ សុន សេន និង នួន ជា ដើម្បីសម្រេចថាតើកម្មាភិបាលនៅកងពលធំ១៦៤ និង ៥០២ ដែលត្រូវបានគេឆ្លើយដាក់រូបណាខ្លះដែលត្រូវចាប់ខ្លួន និង បញ្ជូនទៅមន្ទីរ

---

[152] **D1.3.27.8**, កំណត់ហេតុនៃការប្រជុំរបស់លេខា និងសេដ្ឋកិច្ចកងពលធំ, ថ្ងៃទី១៦ ឧសភា ១៩៧៦, ត្រង់លេខERN 00184820 ។ **D1.3.27.13**, កំណត់ហេតុនៃការប្រជុំរបស់លេខា និងអនុលេខាកងពលធំ និងកងវរៈសេនាធំឯករាជ, ថ្ងៃទី៣០ សីហា ១៩៧៦, ត្រង់លេខ ERN 00183966-68 ("ដាច់ខាតបោសសម្អាតពួកសមាសភាពមិនល្អបន្ថែមទៀត") ។ **D1.3.8.4**, កំណត់ហេតុនៃការប្រជុំរបស់សមមិត្ត ១៦៤, ថ្ងៃទី៩ កញ្ញា ១៩៧៦, លេខ ERN 00657354-56 ។ **D1.3.27.16**, កំណត់ហេតុនៃការប្រជុំរបស់លេខា អនុលេខាកងពលធំ និងកងវរៈសេនាធំឯករាជ, ថ្ងៃទី១៦ ឧសភា ១៩៧៦, ត្រង់លេខERN 00184339-40 ។ **D1.3.27.18,** កំណត់ហេតុនៃការប្រជុំរបស់លេខា និងប្រធាន ភស្តុភារកងពលធំ និងកងវរៈសេនាធំ, ថ្ងៃទី១៩ កញ្ញា ១៩៧៦, ត្រង់លេខERN 00195340-41 ។ **D1.3.27.19**, កំណត់ហេតុ នៃការប្រជុំស្តីពីការងារផលិតកម្ម, ថ្ងៃទី៣០ កញ្ញា ១៩៧៦, ត្រង់ លេខERN 00184821 ។ **D1.3.27.23**, កំណត់ហេតុនៃការ ប្រជុំរបស់លេខា និងប្រធានភស្តុភារកងពលធំ និងកងវរៈសេនាធំឯករាជ, ថ្ងៃទី១៥ ធ្នូ ១៩៧៦, ត្រង់លេខERN 00233711-12 ។ **D1.3.27.26**, កំណត់ហេតុនៃការប្រជុំរបស់លេខា និងអនុលេខាកងពលធំ និងកង វរៈសេនាធំឯករាជ, ថ្ងៃទី១ មីនា ១៩៧៧, ត្រង់លេខERN 00183949 (ថ្លែងដោយ ស៊្វ មេត ថា "សមាសភាពមិនល្អជាង ៥០នាក់" ត្រូវបាន បញ្ជូនទៅស-២១ និងបានស្នើ ដកលេខាកងអនុសេនាតូច ៥នាក់ ហើយនិងថ្លែងដោយ មាស មុត ថា កងអនុសេនាតូចមួយកងត្រូវបានបោស សម្អាត) ។ *សូមមើលផងដែរ,* **D1.3.8.3**, កំណត់ហេតុនៃ ការប្រជុំស្តីពីកិច្ចការយោធានៅកំពង់សោម, ថ្ងៃទី៣ សីហា ១៩៧៦, លេខERN 0234012-16 (មាស មុត ប្រជុំជាមួយ ប៉ុល ពត, វន វ៉េត និង សុន សេន ពិភាក្សាអំពីស្ថានភាពខ្មាំង) ។

[153] **D366/7.1.476**, របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពី មុត ជូនបង ៨៩, ២០ កុម្ភៈ ១៩៧៦, ERN 00525783; **D1.3.12.6** របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពី ម៉េត (កងពលធំ៥០២), ១ សីហា ១៩៧៦, ត្រង់ ERN 00234035; **D1.3.12.9** របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពី ម៉េត (គណៈកងពលធំ៥០២), ១ កញ្ញា ១៩៧៦, ERN 00233902; **D1.3.34.11** សារទូរលេខកម្ពុជាប្រជាធិបតេយ្យ ពី ឌឹម ទៅ មុត, ២៤ កញ្ញា ១៩៧៦, ERN 00233660 (ចម្លងជូន នួន ជា និង សុន សេន); **D1.3.34.13** សារទូរលេខកម្ពុជាប្រជាធិបតេយ្យ ពី ឌឹម ទៅ មុត, ៦ តុលា ១៩៧៦, ERN 00233657 (ចម្លងជូន នួន ជា និង សុន សេន) ។

[154] **D1.3.1.10** S-21 ចម្លើយសារភាពរបស់ ស្រី សារឿន, ១៩ តុលា ១៩៧៧, ERN 00161882; **D1.3.1.12** ចម្លើយសារភាពនៅស-២១ របស់ អ៊ុក វ៉ាន់ ហៅ វិន, ២៤ កញ្ញា ១៩៧៧, ERN 00233907; **D1.3.1.5** ចម្លើយសារភាពនៅស-២១ របស់ ណយ ចាប, ២៧ សីហា ១៩៧៧, ERN 00162395-427; **D1.3.1.11** ចម្លើយសារភាពនៅស-២១ របស់ ស៊្វង ហឿង (Suon Heuang), ២៩ សីហា ១៩៧៧, ERN 00233937; **D288/6.2.23** ចម្លើយសារភាពនៅស-២១ របស់ ដៀង ភីកា, ៦ តុលា ១៩៧៦ [ដាក់ជូនដោយសហព្រះរាជអាជ្ញាអន្តរជាតិ តាមឯកសារលេខ ១៩ នៅក្នុងឯកសារលេខ **D17.1**, ERN 00698686] ។

[155] **D1.3.18.1** ចម្លើយសារភាពនៅស-២១ របស់ ហង់ ឌឿន ហៅ ឌឹម, ៤ ឧសភា ១៩៧៧, ERN 00187721; **D1.3.18.3** ចម្លើយសារភាពនៅស-២១ របស់ គុណ ឌឹម, ១០ កញ្ញា ១៩៧៧, ERN 00242033; **D1.3.1.7** ចម្លើយសារភាពនៅស-២១ របស់ ប៉ែន ហាំ (PEN Ham), ៣ មិថុនា ១៩៧៧, ERN 00233933 ។

សម២១[156]។ ដូចដែលបានសម្រេចដោយ ស.ច.ស នៅក្នុងសំណុំរឿង ០០២ រួចមកហើយគឺថា កម្មាភិបាលកងទ័ពបដិវត្តន៍កម្ពុជា (RAK) គឺជាក្រុមអ្នកទោសដែលមានចំនួនច្រើនជាងគេនៅមន្ទីរ ស២១ ដោយមានចំនួនជាងពាក់កណ្តាលនៃអ្នកទោសដែលមានតួលេខច្បាស់លាស់[157]។

៧៩. អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស និងសាក្សីនានាក៏បានបញ្ជាក់ផងដែរពីការទទួលខុសត្រូវរបស់ ស៊ូ ម៉េត និង មាស មុត សម្រាប់ទីតាំងឧក្រិដ្ឋកម្មដទៃទៀតក្នុងសំណុំរឿង ០០៣។ ក្នុងឋានៈជាលេខាធិការកងពលធំ ៥០២ ស៊ូ ម៉េត ទទួលខុសត្រូវមន្ទីរ ស២២ ដែលជាគុកប្រចាំកងពល និង ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ដែលគាត់បានទៅពិនិត្យជាញឹកញាប់[158]។ ក្នុងឋានៈជាលេខាធិការកង

[156] **D288/4.26.1** ប្រតិចារិកសវនាការសំណុំរឿងលេខ ០០១, ២៧ ឧសភា ២០០៩ (ថ្ងៃលើកទី២២), ERN 00334496-599 (ទំព័រ 3, 9, 17, 29); **D12** កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេចអ៊ាវ ហៅ ឌុច, ២៧ មេសា ២០១១, ERN 00680795-99 ត្រង់ ERN 00680799; **D43/IV ឧបសម្ព័ន្ធ ៥៧** របស់ ហង់ ឌឿន ហៅ ខឹម, ERN 00224085 [ចំណារធ្វើឡើងដោយ សុន សេន អំពីចម្លើយសារភាពរបស់អនុលេខានៃកងពលធំ១៦៤ ដែលនិយាយថា ["ទោះបីខ្លះជាមនុស្សត្រឹមត្រូវក៏ដោយ ប៉ុន្តែពួកអ្នកដែលខ្ញុំស្គាល់ គឺមិនមែនជាមនុស្សត្រឹមត្រូវទេ"] ។ **D1.3.23.3** របាយការណ៍កម្ពុជា ពី ម៉េត ទៅ ឌុច, ១ មេសា ១៩៧៧, ERN 00178065; **D1.3.28.35** របាយការណ៍កម្ពុជា ពី ម៉េត ទៅ ឌុច, ៣០ ឧសភា ១៩៧៧, ERN 00178066; **D4.1.391** របាយការណ៍កម្ពុជា ពី ម៉េត ទៅ ឌុច, ២ មិថុនា ១៩៧៧, ERN 00316309; **D427** ដីកាដំណោះស្រាយនៃសំណុំរឿង០០២, កំណត់សំគាល់*ខាងដើម* លេខ១២២ ត្រង់កថាខ័ណ្ឌទី៦០០, ១០៧៤ (រៀបរាប់អំពី "គោលការណ៍ការងារ" របស់ស-២១ ដែលចម្លើយសារភាពនានាត្រូវគេបញ្ជូនទៅប្រធានអង្គភាពរបស់អ្នកជាប់ឃុំដែលបានគេបានសួរចម្លើយនោះ "ដើម្បីឱ្យអ្នកនោះ រកនឹកទៅដល់ការចាប់ខ្លួនអ្នកផ្សេងទៀតដែលបានភ្ជាប់ឈ្មោះនៅក្នុងចម្លើយសារភាពទាំងនោះ") ។

[157] **D427** ដីកាដំណោះស្រាយនៃសំណុំរឿង០០២, កំណត់សំគាល់*ខាងដើម* លេខ១២២ ត្រង់កថាខ័ណ្ឌទី៤២៤ (រកឃើញថា កម្មាភិបាលនៃកងទ័ពបដិវត្តន៍កម្ពុជា មានចំនួនសារុប៥,៦០៩នាក់ នៃចំនួនសរុបទាំងអស់នៃអ្នកចូលមន្ទីរស-២១ ចំនួន១២,២៧៣នាក់ ដែលមានក្នុងបញ្ជីអ្នកទោស ស-២១]; **D1.3.11.3** បញ្ជីអ្នកដែលគេចាប់ខ្លួនរបស់ កសព ពី កងពលធំ១៦៤, ERN 00196162-78 (កំណត់អត្តសញ្ញាណកម្មាភិបាលកងពលធំ១៦៤ ចំនួន៣៩៦នាក់ ដែលបានបញ្ជូនទៅស-២១); **D9.3** បញ្ជីអ្នកទោសស-២១ របស់ កសចស ពី កងពលធំ១៦៤, ERN 00679641-44 (ចុះបញ្ជីអ្នកទោសស-២១ ចំនួន៥៥នាក់); **D1.3.11.2** បញ្ជីអ្នកដែល គេចាប់ខ្លួនរបស់ កសព ពី កងពលធំ៥០២, ERN 00196179-216 (កំណត់អត្តសញ្ញាណកម្មាភិបាលកងពលធំ៥០២ ចំនួន៨៦៣នាក់ ដែលបានបញ្ជូនទៅស-២១); **D9.2** បញ្ជីអ្នកទោសស-២១ របស់ កសចស ពី កងពលធំ៥០២, ERN 00679626-40 (ចុះបញ្ជីអ្នកទោសស-២១ ចំនួន៣៥៥នាក់) ។ កសចស ក៏បានរកឃើញផងដែរថា "កងពលធំ៥០២ បានចូលរួមយ៉ាងសកម្ម នៅក្នុងការបោសសម្អាតសមាជិកនៃកងទ័ពបដិវត្តន៍កម្ពុជា" ។ **D427** ដីកាដំណោះស្រាយនៃសំណុំរឿង០០២, កំណត់សំគាល់*ខាងដើម* លេខ១២២ ត្រង់កថាខ័ណ្ឌ៣៨៧។

[158] **D2/21** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ កសចស សម្រាប់មន្ទីរសន្តិសុខ ស-២១, ៩ ធ្នូ ២០១០, ERN 00630523-36 ត្រង់ ERN 00630524; **D4.1.780** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ កសចស សម្រាប់ព្រលានយន្តហោះកំពង់ឆ្នាំង, ត្រង់ ERN 00436945-47 [កំណត់អត្តសញ្ញាណ ស៊ូ ម៉េត ថាជាអ្នកគ្រប់គ្រងដែលនៅរស់តែម្នាក់គត់ពីទីកន្លែងនេះ និងថាជា មេដឹកនាំកម្រិតខ្ពស់ម្នាក់" រួមជាមួយនឹង ខៀវ សំផន, អៀង សារី, តា ម៉ុក និង សុន សេន ដែលតែងចុះមក

ពលធំ ១៦៤ មាស មុត ទទួលខុសត្រូវមន្ទីរសន្តិសុខប្រចាំកងពលឈ្មោះ វត្តអង្គតាញៀន (Wat Enta Nhien) ការដ្ឋានធ្វើការងារដោយបង្ខំនៅកន្លែងវាយថ្ម ស្ទឹងហាវ ការចាប់ខ្លួនជនជាតិថៃ ជនជាតិវៀតណាម និង នាវាបរទេសដែលបានចូលមកក្នុងដែនទឹកកម្ពុជា និង ការចាប់ខ្លួន និង ការសម្លាប់ជនបរទេសនៅលើនាវាទាំងនោះ[159] រួមទាំងការចាប់ខ្លួនកងម៉ារីនសហរដ្ឋអាមេរិក ក្នុងអំឡុងពេលមានឧបទ្ទវហេតុចំពោះនាវា *Mayaguez* ដែលកងម៉ារីនទាំងនោះត្រូវបានគេរាយការណ៍ថា បានយកទៅឃុំឃាំង និង សម្លាប់នៅវត្តអង្គតាញៀន[160]។

៨០. ស្ថិតក្រោមកាលៈទេសៈទាំងនេះ ប្រសិនបើ មាស មុត និង ស៊ូ ម៉េត មិនត្រូវបានយកទៅវិនិច្ឆ័យទោសដោយ អ.វ.ត.ក នោះទេ នឹងមិនមានមេដឹកនាំយោធានាណាម្នាក់ត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលកងទ័ពបដិវត្តន៍កម្ពុជាត្រូវទទួលខុសត្រូវក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។ ផ្ទុយទៅវិញ នៅតុលាការ ICTY មានសមាជិកយោធាចំនួន ៧៨ក្នុងចំណោម១៦១រូបត្រូវបានយកទៅវិនិច្ឆ័យទោសដែរ ដែលតំណាងឲ្យ ៤៨% នៃសំណុំរឿងដែលត្រូវបានយកទៅវិនិច្ឆ័យទោសរួចហើយ និងកំពុងវិនិច្ឆ័យទោស[161]។ មិនគួរមានចម្ងល់ទាល់តែសោះនៅក្នុងត្រង់ចំណុចនេះដែលថា ជនសង្ស័យក្នុងសំណុំរឿង ០០៣ ដែលបានបង្ហាញឈ្មោះដោយសហព្រះរាជអាជ្ញា

---

ពិនិត្យទីតាំងនេះជាទៀងទាត់; **D2/18** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្រេង ធី, ត្រង់ ERN 00630432, 00630434-35; **D4.1.837** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេន សុផល, ត្រង់ ERN 00374048 ។ *សូមអានផងដែរ* ឯកសារលេខ **D427** ដីកាដំណោះស្រាយនៃសំណុំរឿង០០២, កថាខ័ណ្ឌ៣៨៧៦ ។

[159] **D2/23** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ កសចស សម្រាប់ការដ្ឋានវាយថ្មស្ទឹងហាវ, ៣០ ធ្នូ ២០១០, ERN 00644146-84 ត្រង់ ERN 00644147-48, 00644152; **D2/22** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ កសចស សម្រាប់មន្ទីរសន្តិសុខ វត្តឥន្ទញាណ, ២៩ ធ្នូ ២០១០, ERN 00634138-76, ត្រង់ ERN 00634141-42; **D2/9** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ិន, ត្រង់ ERN 00613024; **D2/15** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី, ត្រង់ ERN 00628184-85, 00628187-88; **D2/16** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី, ត្រង់ ERN 00629463; **D1.3.8.4** កំណត់ហេតុនៃកិច្ចប្រជុំរបស់សមមិត្ត ១៦៤, ត្រង់ ERN 00657355-56; **D1.3.27.18** កំណត់ហេតុនៃកិច្ចប្រជុំរបស់បណ្តាលេខា និងប្រធានភស្តុភារនៃ កងពលធំ និងកងវរៈសេនាធំ, ត្រង់ ERN 00195340-41; **D1.3.12.20** របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពី មុត, ១២ សីហា ១៩៧៧, ERN 00233972; **D4.1.635** របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពី មុត, ១ មេសា ១៩៧៨, ត្រង់ ERN 00143507 ។

[160] **D2/22** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ កសចស សម្រាប់មន្ទីរសន្តិសុខ វត្តឥន្ទញាណ, ២៩ ធ្នូ ២០១០, ត្រង់ ERN 00634141-43; Ralph Wetterhahn, *សមរភូមិចុងក្រោយ (The Last Battle)*, 2002, ទំព័រ ២៨១-២៨៩ ។

[161] *សូមអាន* ឯកសារព័ត៌មានសំណុំរឿង ត្រង់គេហទំព័រ http://www.icty.org/action/cases/4 ។

អន្តរជាតិគឺពិតជាស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក ក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ ឬ ជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ហើយថា កថាខណ្ឌ ៦(គ) និង កថាខណ្ឌ ៦(ឃ) នៃដីកាសម្រេចរបស់ ក.ស.ច.ស គឺផ្អែកលើការសេចក្តីសន្និដ្ឋានខាងអង្គហេតុមិនបានត្រឹមត្រូវ ហើយវាជាកម្មវត្ថុដែល អ.ប.ជ ត្រូវយកទៅពិនិត្យឡើងវិញ។

## ៥. ដំណោះស្រាយដែលស្នើសុំ

៨១. ដូចមូលហេតុរៀបរាប់ខាងលើ សហព្រះរាជអាជ្ញាអន្តរជាតិសូមស្នើអង្គបុរេជំនុំជម្រះដូចតទៅ៖

(ក) សម្រេចថា ដីកាសម្រេចនេះ អាចពិនិត្យឡើងវិញបានតាមរយៈបណ្តឹងឧទ្ធរណ៍និងគ្មានសុពលភាព នៅលើទឡ្ហីករណ៍ថា ដីកាសម្រេចនេះ (i) បានពឹងផ្អែកលើការបកស្រាយមិនត្រឹមត្រូវទៅលើច្បាប់ជាធរមាន (កថាខ័ណ្ឌ២៣-២៧, ៥៤-៦៨); (ii) បានពឹងផ្អែកលើការសន្និដ្ឋានលើអង្គហេតុមិនត្រឹមត្រូវយ៉ាងជាក់ស្តែង (កថាខ័ណ្ឌ៣០-៣៣, ៦៩-៨០) និង (iii) មិនយុត្តិធម៌ និងមិនមានសំអាងហេតុ បង្កើតបានជាការរំពានបំពានលើឆន្ទានុសិទ្ធិតុលាការ (កថាខ័ណ្ឌ២៨-២៨, ៣៤-៣៧, ៤១-៤៣) ។

(ខ) បង្គាប់ឲ្យ សចស ពិចារណាសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិលើអង្គសេចក្តីជាបន្ទាន់ ។

(គ) ដោយយោងលើផលប្រយោជន៍សាធារណៈនៅក្នុងបញ្ហានេះ ហើយនិងដើម្បីធានាលើការលើកកម្ពស់ភាពជឿជាក់របស់សាធារណជនបន្ថែមទៀត នៅក្នុងការប្រព្រឹត្តទៅរបស់តុលាការប្រកបដោយប្រសិទ្ធិភាព និងឆាប់រហ័ស (i) អនុញ្ញាតឲ្យសំណៅលប់ចេញផ្នែកខ្លះជាសាធារណៈនៃបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានចេញដោយសហព្រះរាជអាជ្ញាក្នុងពេលឥឡូវនេះ និង (ii) ធ្វើសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍នេះជាសាធារណៈ ដែលស្របទៅនឹងការអនុវត្តរបស់អង្គបុរេជំនុំជម្រះរហូតមកដល់សព្វថ្ងៃ; ហើយនិង

(ឃ) ពន្លឿនការពិចារណា និងការសម្រេចរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍នេះ ដោយហេតុថាសារសំខាន់ជាស្នូលនៃបញ្ហានេះជាប់ពាក់ព័ន្ធទៅនឹងបូរណភាព និងកត្តិស័ព្ទជាសាធារណៈរបស់ អ.វ.ត.ក និងនីតិវិធីផ្ទៃក្នុងរបស់ កសព ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១១ | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |